**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 21-Dec-2012, 15:19
CMS/CFO: Uch Arun

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អជសដ/អ.ជ.ត.ក ( )
ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី
ដាក់ជូន: អង្គជំនុំជម្រះតុលាការកំពូល
ភាសាដើម: អង់គ្លេស
កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១២

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ
ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**
ចំណាត់ថ្នាក់ប្រភេទឯកសារ
ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន:
ឈ្មោះមន្ត្រីកត់ត្រា:
ហត្ថលេខា:

---

**បណ្ដឹងសាទុក្ខរបស់ អៀង សារី ជំទាស់នៅនឹងសេចក្ដីសម្រេចផ្ទាល់មាត់របស់អង្គជំនុំជម្រះសាលាដំបូង ដែលបដិសេធសិទ្ធិរបស់គាត់មិនឲ្យមានវត្តមាន នៅក្នុងបន្ទប់សវនាការ និងហាមឃាត់មិនឲ្យថតវីដេអូលើរូបគាត់នៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ**

---

**ដាក់ដោយ៖**

**សហមេធាវី៖**

អាង ឧត្តម
Michael G. KARNAVAS

**អង្គជំនុំជម្រះតុលាការកំពូល៖**

**ចៅក្រម គង់ ស្រ៊ឹម**
**ចៅក្រម សោម សិរីវុឌ្ឍ**
**ចៅក្រម Agnieszka KLONOWIECKA-MILART**
**ចៅក្រម ម៉ុង មុន្នីចរិយា**
**ចៅក្រម Chandra Nihal JAYASINGHE**
**ចៅក្រម យ៉ា ណារិន**

០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក (   )

**ចៅក្រម Florence Ndepele Mwachande MUMBA**

**សហព្រះរាជអាជ្ញា**

ជា លាង

Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**

**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

# មាតិកា

I. សំណួរដែលត្រូវលើកឡើង ..... 5

II. សេចក្តីសង្ខេបនៃនីតិវិធី ..... 6

III. សាវតារ ..... 9

ក. កាលៈទេសៈនានាដែលនាំឲ្យមានសេចក្តីសម្រេចដែលត្រូវបានជំទាស់ ..... 9

ខ. សេចក្តីសម្រេចដែលត្រូវបានជំទាស់ ..... 16

គ. ព្រឹត្តិការណ៍ពាក់ព័ន្ធនានាបន្ទាប់ពីចេញសេចក្តីសម្រេចដែលត្រូវបានជំទាស់ ..... 20

IV. បញ្ហាបឋម ..... 24

ក. ភាពអាចទទួលយកបាននៃបណ្តឹងសាទុក្ខ ..... 24

១. បណ្តឹងសាទុក្ខមានលក្ខណៈអាចឲ្យទទួលយកបាន ដោយអនុលោមតាមវិធាន ១០៤(៤)(ក) ..... 25

២. បណ្តឹងសាទុក្ខមានលក្ខណៈអាចឲ្យទទួលយកបាន ដោយអនុលោមតាមវិធាន ១០៤(៤)(ខ) ..... 26

៣. បណ្តឹងសាទុក្ខមានលក្ខណៈអាចឲ្យទទួលយកបាន ដោយអនុលោមតាមវិធាន ១០៤(៤)(ឃ) ..... 27

៤. ការបកស្រាយវិធាន ១០៤(៤) ក្នុងន័យទូលាយ ត្រូវបានតម្រូវដោយវិធាន ២១ និង ដើម្បីផលប្រយោជន៍នៃយុត្តិធម៌ ..... 28

ខ. សំណើសុំឲ្យមានសវនាការផ្ទាល់មាត់ជាសាធារណៈ ..... 34

V. ច្បាប់ និងនីតិវិធី ..... 34

ក. អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសអង្គច្បាប់ តាមរយៈការបកស្រាយវិធាន ៨១(៥) ក្នុងន័យដើម្បីបង្ខំឲ្យលោក អៀង សារី តាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ជាជាងការមានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការ ....34

១. លោក អៀង សារី មានសិទ្ធិក្នុងការវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការ....34

២. វិធាន ៨១(៥) បានត្រឹមតែអនុញ្ញាតឲ្យមានការរិតត្បិតសិទ្ធិក្នុងការមានវត្តមានដោយផ្ទាល់ នៅក្នុងកាលៈទេសៈមួយចំនួនតូច ដែលពុំត្រូវបានបំពេញ....37

ក. លោក អៀង សារី អាចមានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការ ....38

ខ. គ្មានការពន្យារពេលយ៉ាងយូរ ....39

គ. អង្គជំនុំជម្រះមិនគួរពិចារណាលើផលប្រយោជន៍នៃយុត្តិធម៌ឡើយ....40

ខ. អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គហេតុ និងបានបំពានធន្ទានុសិទ្ធិរបស់ខ្លួនដោយបានអនុវត្តវិធាន ៨១(៥) នៃវិធានផ្ទៃក្នុងដើម្បីចាប់បង្ខំលោក អៀង សារី ឲ្យតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ជាជាងឲ្យលោកមានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការ....40

១. ផលប្រយោជន៍ផ្នែកវេជ្ជសាស្ត្រសម្រាប់លោក អៀង សារី ពុំចាំបាច់តម្រូវឲ្យលោកនៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនោះទេ....41

២. ដំណើរការកិច្ចនីតិវិធីឲ្យបានឆាប់រហ័សពុំចាំបាច់ត្រូវការលោក អៀង សារី....44

គ. អង្គជំនុំជម្រះសាលាដំបូងមានកំហុស ដោយសារបានបំពានធន្ទានុសិទ្ធិរបស់ខ្លួនធ្វើការហាមឃាត់ក្រុមមេធាវីការពារក្តីធ្វើកំណត់ហេតុលើស្ថានភាពរបស់លោក អៀង សារី តាមមធ្យោបាយថតវីដេអូក្នុងខណៈពេលដែលលោកស្ថិតនៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោម ....48

VI. សំណើសុំ....54

លោក អៀង សារី តាមរយៈសហមេធាវីរបស់គាត់ ("មេធាវីការពារក្តី") ដោយអនុលោមតាមវិធាន ១០៤ និង ២១ នៃវិធានផ្ទៃក្នុង អ.វ.ត.ក ("វិធាន") សូមដាក់បណ្តឹងសាទុក្ខជំទាស់នឹងសេចក្តីសម្រេចផ្ទាល់មាត់របស់អង្គជំនុំជម្រះសាលាដំបូងដែលបដិសេធសិទ្ធិរបស់គាត់មិនឲ្យមានវត្តមាន នៅក្នុងបន្ទប់សវនាការ និងហាមឃាត់គាត់មិនឲ្យថតវីដេអូលើរូបគាត់នៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ("សេចក្តីសម្រេចដែលត្រូវបានជំទាស់")[1]។ បណ្តឹងសាទុក្ខនេះធ្វើឡើងជាការចាំបាច់ ដោយសារអង្គជំនុំជម្រះសាលាដំបូងមានកំហុសលើអង្គច្បាប់ និងអង្គហេតុ និងបានបំពានឆន្ទានុសិទ្ធិរបស់ខ្លួន។ លោក អៀង សារី មានសិទ្ធិមានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការ ដែលអាចនឹងត្រូវបានដាក់កំហិតតែក្នុងស្ថានភាពតឹងរ៉ឹង និងមានកម្រិតប៉ុណ្ណោះ។ មេធាវីការពារក្តីសូមដាក់នូវមូលដ្ឋានចំនួន ៣ នៃបណ្តឹងសាទុក្ខនេះ។ អង្គជំនុំជម្រះសាលាដំបូងមានកំហុសលើអង្គច្បាប់ ដោយបានបកស្រាយមិនត្រឹមត្រូវនូវវិធាន ៨១(៥) ដែលចែងពីបែបបទសម្រាប់កំហិតសិទ្ធិរបស់លោក អៀង សារី ក្នុងការមានវត្តមានដោយផ្ទាល់។ អង្គជំនុំជម្រះសាលាដំបូងមានកំហុសលើអង្គហេតុ និងបានបំពានឆន្ទានុសិទ្ធិរបស់ខ្លួនដោយសន្និដ្ឋានថា វត្តមានរបស់លោក អៀង សារី នៅក្នុងបន្ទប់សវនាការបានបណ្តាលឲ្យមានការពន្យារពេលយ៉ាងវែង និងបានបង្គាប់ថា វត្តមានរបស់លោក អៀង សារី នៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ជាការចាំបាច់ដើម្បីប្រយោជន៍យុត្តិធម៌។ អង្គជំនុំជម្រះសាលាដំបូង មានកំហុសដោយបំពានឆន្ទានុសិទ្ធិរបស់ខ្លួន ក្នុងការបដិសេធមិនអនុញ្ញាតឲ្យថតវីដេអូលើរូបលោក អៀង សារី ក្នុងពេលសវនាការ ដោយរំលោភទៅដល់សិទ្ធិជាសារវ័ន្តរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ ដើម្បីរៀបចំការការពារខ្លួន ដែលរួមបញ្ចូលទាំងការអាចថតវីដេអូលើរូបគាត់សម្រាប់ធ្វើជាកំណត់ហេតុផង។ សេចក្តីសម្រេចដែលត្រូវបានជំទាស់អាចត្រូវបានប្តឹងសាទុក្ខភ្លាមៗ អនុលោមតាមវិធាន ១០៤(៤)(ក), ១០៤(៤)(ខ) និង ១០៤(៤)(ឃ)។

## I. សំណួរដែលត្រូវលើកឡើង

**ក.** *លោក អៀង សារី មានសិទ្ធិជាសារវ័ន្តដែលត្រូវបានធានាដោយរដ្ឋធម្មនុញ្ញកម្ពុជា ក្របខណ្ឌច្បាប់នៅ អ.វ.ត.ក និងច្បាប់អន្តរជាតិ ក្នុងការមានវត្តមានក្នុងអំឡុងពេលកិច្ចដំណើរការនីតិវិធីប្រឆាំងរូបគាត់។ លោក អៀង សារី បានបង្ហាញនូវចេតនាចង់អនុវត្តសិទ្ធិរបស់គាត់ដោយផ្ទាល់ ដោយ*

---

[1] ប្រតិចារឹក, ថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០១២, ឯកសារ E1/147.1, ទំព័រ ១៧ ដល់ ១៩ (ភាសាអង់គ្លេស)។

*មានវត្តមានក្នុងបន្ទប់សវនាការ តែអាចត្រូវបានកំហិតតែក្នុងកាលៈទេសៈដែលត្រូវបានកម្រិតអនុលោមតាមវិធាន ៨១(៥) ប៉ុណ្ណោះ។ តើអង្គជំនុំជម្រះសាលាដំបូងមានកំហុសលើអង្គច្បាប់ឬទេ នៅពេលបកស្រាយវិធាន ៨១(៥) តាមវិធីនេះដើម្បីបង្ខំឲ្យលោក អៀង សារី តាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ជាជាងមានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនោះ?*

ខ. *វិធាន ៨១(៥) អនុញ្ញាតឲ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់ឲ្យមានការចូលរួមក្នុងកិច្ចដំណើរការនីតិវិធីតាមរយៈប្រព័ន្ធសោតទស្សន៍បាន ប្រសិនបើជនជាប់ចោទមិនអាចមានវត្តមានបាន ប្រសិនបើមានការពន្យារពេលយ៉ាងវែង និងប្រសិនបើការចូលរួមបែបនេះជាប្រយោជន៍យុត្តិធម៌។ លោក អៀង សារី អាចមានវត្តមាននៅក្នុងបន្ទប់សវនាការបាន និងមិនមានការពន្យារពេលយ៉ាងវែងនៅក្នុងកិច្ចដំណើរការនីតិវិធីទេ។ តើអង្គជំនុំជម្រះសាលាដំបូងសាលាដំបូងមានកំហុសលើអង្គហេតុ និង បានបំពានឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការអនុវត្តវិធាន ៨១(៥) ដើម្បីបង្ខំលោក អៀង សារី ឲ្យតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ជាជាងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនោះ?*

គ. *លោក អៀង សារី មានសិទ្ធិជាសារវ័ន្ត ដែលត្រូវបានធានាដោយរដ្ឋធម្មនុញ្ញកម្ពុជា ក្របខណ្ឌច្បាប់នៅ អ.វ.ត.ក និងច្បាប់អន្តរជាតិ ដើម្បីរៀបចំការការពារខ្លួន។ ផ្នែកសំខាន់នៃការរៀបចំការការពារខ្លួន និងកាតព្វកិច្ចបំពេញការងារប្រកបដោយការយកចិត្តទុកដាក់របស់សហមេធាវី ដើម្បីការពារសិទ្ធិរបស់លោក អៀង សារី ក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ គឺការធ្វើកំណត់ហេតុចំពោះសេចក្តីសម្រេចដែលអង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះលើបណ្តឹងសាទុក្ខដែលអាចមាន។ តើអង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយបំពានឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការហាមឃាត់មេធាវីការពារក្តីមិនឲ្យធ្វើកំណត់ហេតុពីស្ថានភាពរបស់លោក អៀង សារី តាមការថតជាវីដេអូលើរូបគាត់ ខណៈដែលគាត់កំពុងស្ថិតក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការឬទេ?*

## II. សេចក្តីសង្ខេបនៃឧទ្ធរណ៍

1. អនុលោមតាមរដ្ឋធម្មនុញ្ញកម្ពុជា ក្របខណ្ឌច្បាប់ អ.វ.ត.ក និង យុត្តិសាស្ត្រអន្តរជាតិ លោក អៀង សារី មានសិទ្ធិជាសារវ័ន្តក្នុងការមានវត្តមានដោយផ្ទាល់នៅពេលសវនាការ។ វិធាន ៨១(៥) ទទួលស្គាល់សិទ្ធិជាសារវ័ន្តនេះ និងបានកំណត់លក្ខណៈវិនិច្ឆ័យដែលអង្គជំនុំជម្រះសាលាដំបូងអាចបង្គាប់ឲ្យលោក អៀង សារី ចូលរួមក្នុងកិច្ចដំណើរការនីតិវិធីតាមរយៈប្រព័ន្ធសោតទស្សន៍៖ **ក.** នៅពេលជនជាប់ចោទអាចចូលរួមដោយផ្ទាល់បាន **ខ.** នៅពេលមានការពន្យារពេលយ៉ាងវែងក្នុងកិច្ចដំណើរការនីតិវិធី និង **គ.** ប្រសិនបើការចូលរួមតាមរយៈប្រព័ន្ធសោតទស្សន៍ជាប្រយោជន៍យុត្តិធម៌។ នៅទីនេះ លោក អៀង សារី អាចចូលរួមកិច្ចដំណើរការនីតិវិធីដោយផ្ទាល់បាន និងមានបំណងចូលរួមដោយផ្ទាល់ដែរ។ ជាងនេះទៀត ពុំមានការពន្យារពេលយ៉ាងវែងនៅក្នុងកិច្ចដំណើរការនីតិវិធីទេ។ ដោយសារលក្ខខណ្ឌតម្រូវទាំងពីរពុំត្រូវបានបំពេញនោះ អង្គជំនុំជម្រះសាលាដំបូងមិនគួរពិចារណាថា ដើម្បីប្រយោជន៍យុត្តិធម៌ត្រូវប្រកែកមិនទទួលយកសិទ្ធិរបស់លោក អៀង សារី ក្នុងការចូលរួមដោយផ្ទាល់ទៅក្នុងកិច្ចដំណើរការនីតិវិធីជំនុំជម្រះ ដោយមានវត្តមាននៅក្នុងបន្ទប់សវនាការទេ ហើយផ្ទុយទៅវិញ បែរជាបង្គាប់ឲ្យគាត់ស្ថិតក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។ អង្គជំនុំជម្រះគួរអនុញ្ញាតឲ្យលោក អៀង សារី មានវត្តមាននៅក្នុងបន្ទប់សវនាការ។

2. ស្ថានភាពវេជ្ជសាស្ត្ររបស់លោក អៀង សារី មិនតម្រូវឲ្យគាត់ចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការទេ ហើយវាក៏មិនមែនជាការពន្លឿនកិច្ចដំណើរការនីតិវិធីអ្វីដែរដែលត្រូវទុកលោក អៀង សារី នៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនោះ។ សេចក្តីត្រូវការចាំបាច់ទាំងអស់សម្រាប់ផ្នែកវេជ្ជសាស្ត្ររបស់លោក អៀង សារី ត្រូវបានផ្តល់ជូននៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ក៏អាចផ្តល់ជូនក្នុងបន្ទប់សវនាការបានដែរ។ ជាងនេះទៀត នៅក្នុងបន្ទប់សវនាការ អង្គជំនុំជម្រះសាលាដំបូង មេធាវីការពារក្តី និង វេជ្ជបណ្ឌិតនៅ អ.វ.ត.ក ក៏អាចពិនិត្យតាមដានស្ថានភាពរបស់លោក អៀង សារី ជាប្រចាំ និងអាចឆ្លើយតបបានភ្លាមៗនៅពេលស្ថានភាពគាត់មានការប្រែប្រួលដែរ។ បើសិនជាលោក អៀង សារី នៅក្នុងបន្ទប់សវនាការវិញទើបអាចធានាថា កំណត់ហេតុស្តីពីស្ថានភាពរបស់គាត់អាចរក្សាបានក្នុងពេលដំណាលគ្នានឹងសវនាការដែរ។

3. លោក អៀង សារី មានសិទ្ធិជាសារវ័ន្តដើម្បីរៀបចំការការពារខ្លួន។ ផ្នែកសំខាន់នៃការរៀបចំការការពារខ្លួនគឺធ្វើកំណត់ហេតុពីការប្តឹងសាទុក្ខទៅអង្គជំនុំជម្រះតុលាការកំពូល ប្រសិនបើចាំបាច់។

ប្រសិនបើលោក អៀង សារី មិននៅក្នុងបន្ទប់សវនាការទេនោះ សហមេធាវីមិនអាចតាមដានស្ថានភាពរបស់គាត់បាន ឬមិនអាចធានាថា គាត់កំពុងតែតាមដានកិច្ចដំណើរការនីតិវិធីនោះដែរ។ ប្រសិនបើមេធាវីការពារមិនអាចទទួលការអនុញ្ញាតឲ្យថតវីដេអូលោក អៀង សារី នៅពេលគាត់កំពុងស្ថិតក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនោះ សហមេធាវីក៏មិនអាចតាមដានស្ថានភាពរបស់គាត់បាន ឬមិនអាចធានាស្រដៀងគ្នាដែរថា គាត់កំពុងតាមដានកិច្ចដំណើរការនីតិវិធីដែរ។ ការថតជាវីដេអូលោក អៀង សារី ជាវិធានការមួយដែលមិនអាចរំលោភបានទេ។ វិធានការនេះនឹងមិនបង្អាក់កិច្ចដំណើរការនីតិវិធី ឬនាំឲ្យប៉ះពាល់ប្រយោជន៍ភាគីណាមួយឡើយ។ ការថតវីដេអូលោក អៀង សារី នឹងជួយឲ្យសហមេធាវីអាចបំពេញភារកិច្ចរបស់ខ្លួន ដើម្បីការពារលោក អៀង សារី បាន ដោយសារវាអនុញ្ញាតឲ្យសហមេធាវីអាចរក្សាបាននូវកំណត់ហេតុស្តីពីស្ថានភាពរបស់គាត់ក្នុងពេលដំណាលគ្នានឹងសវនាការដែរ។ កំណត់ហេតុដែលមានដំណាលគ្នានឹងសវនាការ មានលក្ខណៈសត្យានុម័ត និងអាចផ្ទៀងផ្ទាត់បានគឺជាការចាំបាច់ ដើម្បីធានាថា មេធាវីការពារក្តីនៅមានសិទ្ធិប្តឹងសាទុក្ខចំពោះកំហុសឆ្គងនានារបស់អង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធនឹងសុខភាព និងសម្បទារបស់លោក អៀង សារី ក្នុងការចូលរួមសវនាការ និងលទ្ធភាពជាក់ស្តែងដើម្បីចូលរួមកិច្ចដំណើរការនីតិវិធីឲ្យមានន័យ និងប្រើប្រាស់សិទ្ធិទាំងអស់របស់គាត់ក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌។

4. អង្គជំនុំជម្រះសាលាដំបូងមានកំហុសលើអង្គច្បាប់ និងលើអង្គហេតុ និងបានបំពានឆន្ទានុសិទ្ធិរបស់ខ្លួនដោយហាមឃាត់មិនឲ្យលោក អៀង សារី មានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការ និងបានហាមឃាត់មេធាវីការពារក្តីមិនឲ្យធ្វើកំណត់ហេតុដោយថតជាវីដេអូលោក អៀង សារី នៅពេលគាត់កំពុងនៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ដែលរារាំងមិនឲ្យមានកំណត់ហេតុស្តីពីស្ថានភាពរបស់គាត់ក្នុងពេលដំណាលគ្នានឹងសវនាការ និងរក្សាទុកកំហុសសម្រាប់ឲ្យពិនិត្យលើបណ្តឹងសាទុក្ខ។ ក្នុងការធ្វើបែបនេះ អង្គជំនុំជម្រះសាលាដំបូង បានរំលោភដល់សិទ្ធិជាសារវ័ន្តរបស់លោក អៀង សារី ក្នុងការមានវត្តមាននៅក្នុងបន្ទប់សវនាការ និងការរៀបចំសម្រាប់ការការពារខ្លួន។ អង្គជំនុំជម្រះតុលាការកំពូលគួរតែទទួលយកបណ្តឹងសាទុក្ខនេះ មោឃៈសេចក្តីសម្រេចដែលត្រូវបានជំទាស់ និងបង្គាប់ឲ្យអង្គជំនុំជម្រះសាលាដំបូងអនុញ្ញាតឲ្យលោក អៀង សារី មានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការ។ ប្រសិនបើអង្គជំនុំជម្រះតុលាការកំពូលខក

ខានមិនបានអនុញ្ញាតឲ្យលោក អៀង សារី មានវត្តមាននៅក្នុងបន្ទប់សវនាការវិញ អង្គជំនុំជម្រះគួរតែបង្គាប់ទៅអង្គជំនុំជម្រះសាលាដំបូង៖ **ក.** បង្ហាញរូបលោក អៀង សារី នៅលើអេក្រង់ទូរទស្សន៍ក្នុងបន្ទប់សវនាការ ប្រសិនបើគាត់ត្រូវបានបង្គាប់ឲ្យស្ថិតនៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការទៀត ឬ **ខ.** អនុញ្ញាតឲ្យមេធាវីការពារក្តីថតជាវីដេអូ លោក អៀង សារី ខណៈពេលដែលនៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ប្រសិនបើគាត់ត្រូវបានបង្គាប់ឲ្យស្ថិតនៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការទៀត និងបង្គាប់ឲ្យអង្គជំនុំជម្រះសាលាដំបូងទទួលយកការដាក់កាសែតវីដេអូទាំងនេះ ដែលអាចនឹងត្រូវបញ្ចូលក្នុងសំណុំរឿងផងដែរ។

## III. សាវតារ

### ក. កាលៈទេសៈនានាដែលនាំឲ្យមានសេចក្តីសម្រេចដែលត្រូវបានជំទាស់

5. លោក អៀង សារី មានអាយុ ៨៧ ឆ្នាំ។ គាត់ខ្សោយកម្លាំងកាយ និងមានប្រវត្តិថា គាត់មានបញ្ហាបេះដូង មានបញ្ហាប្រព័ន្ធទឹកនោម និងរលាកសន្លាក់ឆ្អឹង[2]។

6. កាលពីថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០១២ លោក អៀង សារី បានចូលសម្រាកព្យាបាលនៅមន្ទីរពេទ្យដោយមានអាការៈអស់កម្លាំង និងល្ហិតល្ហៃយ៉ាងខ្លាំង[3]។ លោក អៀង សារី បន្តសម្រាកព្យាបាលនៅមន្ទីរពេទ្យអស់រយៈពេលជាងពីរខែ រហូតដល់ពេលដែលគាត់ត្រូវបានបញ្ជូនត្រឡប់មកមន្ទីរឃុំឃាំង អ.វ.ត.ក វិញកាលពីថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ២០១២[4]។ ក្នុងអំឡុងពេលសម្រាកព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត និងក្រោយពីនោះមក លោក អៀង សារី មានអាការៈវិលមុខ

---

[2] *សូមមើល ឧទាហរណ៍* របាយការណ៍អ្នកជំនាញស្តីអំពីលោក អៀង សារី ដែលត្រូវបានរៀបចំឡើងដើម្បីឆ្លើយតបទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារលេខ E238), ចុះថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ ២០១២, ឯកសារ E238/4, កថាខណ្ឌ ១ ដល់ ២។

[3] សារអេឡិចត្រូនិករបស់ Claude Bouchard មន្ត្រីសម្របសម្រួលជាន់ខ្ពស់មន្ទីរឃុំឃាំង ចុះថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០១២, ប្រតិចារឹក, ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១២, ឯកសារ E1/125.1, ទំព័រ ១២ (ភាសាអង់គ្លេស)។

[4] ការបញ្ជូន អៀង សារី មកកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក សម្រាប់សវនាការ ថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១២, ចុះថ្ងៃទី ៧ វិច្ឆិកា ឆ្នាំ ២០១២, ឯកសារ E239/2។

ដង្ហក់ ស្ពឹកដៃជើង ហើយគាត់មិនអាចដើរបាន ឬសូម្បីតែងើបអង្គុយ ឬងើបឈរ ដោយគ្មានជំនួយឡើយ[5]។

7. កាលពីថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១២ ក្នុងអំឡុងពេលលោក អៀង សារី សម្រាកព្យាបាលនៅមន្ទីរពេទ្យ លោកវេជ្ជបណ្ឌិត លឹម ស៊ីវុតថា និងលោកវេជ្ជបណ្ឌិត គី ប៊ូ សួ ដែលជាតំណាងគណៈអភិបាលត្រួតពិនិត្យសុខភាពនៃមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត សម្រាប់ជនជាប់ចោទនៅមន្ទីរឃុំខ្លួន អ.វ.ត.ក ("វេជ្ជបណ្ឌិតព្យាបាល") មានវត្តមាននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងដើម្បីធ្វើបច្ចុប្បន្នភាពជូនអង្គជំនុំជម្រះសាលាដំបូង និងភាគី អំពីស្ថានភាពសុខភាពរបស់លោក អៀង សារី[6]។ លោកវេជ្ជបណ្ឌិត លឹម ស៊ីវុតថា បានបញ្ជាក់ថា ការថតឆ្អឹងក (CT Scan) លោកអៀង សារី បានបង្ហាញថា គាត់មានរោគសញ្ញាចុះខ្សោយនៃខួរក្បាលផ្នែកខាងក្រោម (vertebrobasilar insufficiency syndrome)។ វាជាបញ្ហាសុខភាពដែលបណ្តាលមកពីកង្វះឈាមហូរចូលក្នុងក្បាល និងដែលបណ្តាលឲ្យគាត់វិលមុខ អស់កម្លាំង និងមានអាការៈស្ពឹក[7]។

8. កាលពីថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសថា ខ្លួននឹងផ្ញើប្រតិចារឹកនៃសវនាការថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១២ និងរបាយការណ៍វេជ្ជសាស្ត្ររបស់លោក អៀង សារី ជូនដល់លោកសាស្ត្រាចារ្យ A. John Campbell អ្នកជំនាញខាងជំងឺមនុស្សចាស់ដែលបានពិនិត្យលោក អៀង សារី កន្លងមក ដើម្បី "ស្នើសុំយោបល់ពីលោកសាស្ត្រាចារ្យ Campbell

---

[5] *សូមមើល* របាយការណ៍វេជ្ជសាស្ត្រប្រចាំថ្ងៃរបស់ អៀង សារី ដែលបានបញ្ជូនពីមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត, (*ឧទាហរណ៍ ឯកសារ* E11/86.1); របាយការណ៍អ្នកជំនាញទាក់ទងនឹងលោក អៀង សារី ដែលត្រូវបានរៀបចំឡើងជាការឆ្លើយតបទៅនឹងសំណើររបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារ E238), ថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ ២០១២, ឯកសារ E238/4; ប្រតិចារឹក, ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១២, ឯកសារ E1/125.1, ទំព័រ ១២, ទំព័រ ១៤, បន្ទាត់ ៦២ ដល់ ៦៣ (ភាសាអង់គ្លេស); ប្រតិចារឹក, ថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ២០១២, ឯកសារ E1/142.1, ទំព័រ ៧៨, ១០៦ (ភាសាអង់គ្លេស)។

[6] ប្រតិចារឹក, ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១២, ឯកសារ E1/125.1។

[7] *ដូចខាងលើ,* ទំព័រ ១៩ ដល់ ២០, ទំព័រ ៤៨ ដល់ ៤៩ (ភាសាអង់គ្លេស)។

ថាតើត្រូវធ្វើកោសល្យវិច័យវេជ្ជសាស្ត្របន្ថែមលើផ្នែកណា ទាក់ទិននឹងជនជាប់ចោទ អៀង សារី ក្នុងករណីចាំបាច់"[8]។

9. កាលពីថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០១២ បន្ទាប់ពីលោកសាស្ត្រាចារ្យ Campbell បានគូសបញ្ជាក់ថា គាត់ពិបាកជឿជាក់អំពីមូលហេតុនៃការប្រែប្រួលលើការធ្វើរោគវិនិច្ឆ័យរបស់ជនជាប់ចោទ អៀង សារី ចាប់តាំងពីពេលគាត់បានពិនិត្យជនជាប់ចោទជាលើកចុងក្រោយ អង្គជំនុំជម្រះបានចាត់តាំងលោកសាស្ត្រាចារ្យ Campbell ឲ្យត្រឡប់មកកម្ពុជាវិញ ដើម្បីពិនិត្យលោក អៀង សារី[9]។

10. កាលពីថ្ងៃទី ៥ និង ៦ ខែវិច្ឆិកា ឆ្នាំ២០១២ លោកសាស្ត្រាចារ្យ Campbell បានពិនិត្យលោកអៀង សារី និងបានធ្វើរបាយការណ៍មួយ[10]។ ក្នុងរបាយការណ៍នោះ លោកសាស្ត្រាចារ្យ Campbell បានសន្និដ្ឋានថាលោក អៀង សារី ពុំមានជំងឺខ្វះឈាមទៅខួរក្បាល (vertebrobasilar insufficiency syndrome) ទេ ប៉ុន្តែគាត់មានជំងឺវិលមុខភ្លាមកម្រិតស្រាល ដោយសារជំហរឬចលនា (benign paroxysmal positional vertigo)[11]។ លោកសាស្ត្រាចារ្យ Campbell បានគូសបញ្ជាក់ថា ការវិលមុខ ជារឿងធម្មតាចំពោះមនុស្សចាស់ និងយល់ឃើញថា លោក អៀង សារី មានសមត្ថភាពចូលរួមសវនាការ ដោយគ្រាន់តែតម្រូវឲ្យមានការកែប្រែបន្តិចបន្តួចចំពោះការមើលថែទាំសុខភាពរបស់គាត់តែប៉ុណ្ណោះ[12]។

---

[8] សេចក្តីណែនាំទៅភាគីក្រោយសវនាការ ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១២, ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១២, ឯកសារ E233, កថាខណ្ឌ ២។

[9] ការតែងតាំងសាស្ត្រាចារ្យ John A. Campbell សម្រាប់ជនជាប់ចោទ អៀង សារី, ថ្ងៃទី ៨ តុលា ឆ្នាំ ២០១២, ឯកសារ E238។

[10] របាយការណ៍អ្នកជំនាញ ទាក់ទងនឹងលោក អៀង សារី ដែលត្រូវបានរៀបចំឡើង ជាការឆ្លើយតបទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារ E238), ថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ ២០១២, ឯកសារ E238/4។

[11] *ដូចខាងលើ*, ទំព័រ ៣ ដល់ ៥ (ភាសាអង់គ្លេស)។

[12] *ដូចខាងលើ*, ទំព័រ ២ ដល់ ៦ (ភាសាអង់គ្លេស)។

11. កាលពីថ្ងៃទី ៧ ខែ វិច្ឆិកា ឆ្នាំ ២០១២ បន្ទាប់ពីបានទទួលការអនុញ្ញាតពីអង្គជំនុំជម្រះសាលាដំបូងរួច[13] ភ្លាមៗនោះ មេធាវីការពារក្តីបានទាក់ទងលោកវេជ្ជបណ្ឌិត Harold Bursztajn អ្នកជំនាញសរសៃប្រសាទវិកលវិទ្យា[14] ដើម្បីបញ្ជាក់ថាតើគាត់អាចពិនិត្យមើលរបាយការណ៍របស់សាស្ត្រាចារ្យ Campbell និងផ្តល់ជំនួយក្នុងការរៀបចំសម្រាប់ការសួរដេញដោលសាស្ត្រាចារ្យ Campbell នៅថ្ងៃបន្ទាប់[15]។ លោកវេជ្ជបណ្ឌិត Bursztajn បានពិនិត្យមើលដោយត្រួសៗ (ដោយសារពេលវេលាមានកម្រិត និងការដាក់កំហិត ផ្សេងៗ)[16] ទៅលើរបាយការណ៍ថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ របស់លោកសាស្ត្រាចារ្យ Campbell និងបានផ្តល់ការវិភាគដោយសង្ខេប[17]។ លោកវេជ្ជបណ្ឌិត Bursztajn យល់ឃើញថា វិធីសាស្ត្ររបស់លោកសាស្ត្រាចារ្យ Campbell មិនអាចទទួលយកបាន និងបានគូសបញ្ជាក់ថា លោកសាស្ត្រាចារ្យ Campbell៖

> ១. [ពុំបាន]ធ្វើតេស្តត្រួតពិនិត្យសមត្ថភាពជាក់លាក់មួយ ទាក់ទងនឹងសមត្ថភាពរបស់ [លោក អៀង សារី] ក្នុងការជួយដល់មេធាវី ដូចជាការពិនិត្យអំពីការចងចាំជីវប្រវត្តិរបស់ជនជាប់ចោទជាដើម។
>
> ២. [ពុំបាន]ធ្វើការវាយតម្លៃជាលក្ខណៈប្រព័ន្ធអំពីសមត្ថភាពនៃការយកចិត្តទុកដាក់ ការផ្ចង់អារម្មណ៍ ភាសា និងមុខងារប្រតិបត្តិរបស់ [លោក អៀង សារី] ទាក់ទងនឹងភាពអំណត់របស់គាត់ចំពោះការហេវហត់អស់កម្លាំង និងការឈឺចុក

---

[13] *សូមមើល* សារអេឡិចត្រូនិកពី Roger Phillips មន្ត្រីច្បាប់របស់អង្គជំនុំជម្រះសាលាដំបូង "យោង ៖ សំណើសុំចែករំលែករបាយការណ៍អ្នកជំនាញ ឯកសារ E238/4", ថ្ងៃទី ៧ ខែ វិច្ឆិកា ឆ្នាំ ២០១២។

[14] វេជ្ជបណ្ឌិត Bursztajn អ្នកឯកទេសនៅសាលាបណ្តុះបណ្តាលវេជ្ជសាស្ត្រ Harvard លើផ្នែកចិត្តវិកលវិទ្យាបច្ចេកវិទ្យា និងមានបទពិសោធយ៉ាងច្រើនលើផ្នែកនេះ។ *សូមមើល ប្រវត្តិផ្ទាល់ខ្លួន*របស់វេជ្ជបណ្ឌិត Bursztajn, ឯកសារ E115.2.2។

[15] *សូមមើល* ការឆ្លើយឆ្លងសារអេឡិចត្រូនិករវាងមេធាវីការពារក្តី និងលោកវេជ្ជបណ្ឌិត Bursztajn, ឯកសារ E238/6.2។

[16] *សូមមើល* ប្រតិចារឹក, ថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ២០១២, ឯកសារ E1/142.1, ទំព័រ ៤៩ (ភាសាអង់គ្លេស); ប្រតិចារឹក, ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១២, ឯកសារ E1/143.1, ទំព័រ ៨ (ភាសាអង់គ្លេស) ដែលសហមេធាវីការពារក្តីអន្តរជាតិ Michael G. Karnavas បានកត់សម្គាល់ថា លិខិតរបស់វេជ្ជបណ្ឌិត Bursztajn ជូនមេធាវីការពារក្តី មិនមែនជារបាយការណ៍អ្នកជំនាញទេ ពីព្រោះថា វេជ្ជបណ្ឌិត Bursztajn មិនបានផ្តល់ឱ្យខ្លួននូវព័ត៌មានចាំបាច់ទាំងអស់ ឬផ្តល់ឱ្យក្នុងពេលវេលាដែលត្រូវរៀបចំរបាយការណ៍អ្នកជំនាញលើផ្នែកវេជ្ជសាស្ត្រ។

[17] លិខិតរបស់វេជ្ជបណ្ឌិត Bursztajn ផ្ញើជូនមេធាវីការពារក្តី, ថ្ងៃទី ៧ ខែ វិច្ឆិកា ឆ្នាំ ២០១២, ឯកសារ E238/6។

ចាប់ នៅពេលដែលរយៈពេលធ្វើសវនាការចេះតែបន្តទៅមុខ និងនៅពេលភាពស្មុគស្មាញនៃព័ត៌មានចេះតែកើនឡើង។

៣. [បានបដិសេធទាំងស្រុង] អំពីផលរំខានដែលអាចមានពីការប្រើប្រាស់ឱសថដោយផ្អែកតាមការសន្មតដោយឯកឯង ដែលថាដោយសារឱសថដែល [លោក អៀង សារី] ប្រើប្រាស់ ពុំមានការផ្លាស់ប្តូរ ទើបជាតិពុលដែលបញ្ចេញបន្តិចម្តងៗ ប៉ុន្តែក្នុងកម្រិតគួរឲ្យកត់សម្គាល់ តាមជាលិកាប្រសាទទាក់ទងនឹងការប្រើប្រាស់ឱសថ អាចត្រូវបណ្តេញចេញ ឬអាចត្រូវបានកត់សម្គាល់ឃើញដោយវេជ្ជបណ្ឌិតព្យាបាលជនជាប់ចោទ[18]។

12. កាលពីថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ២០១២ លោកសាស្ត្រាចារ្យ Campbell បានផ្តល់សក្ខីកម្មក្នុងតុលាការ[19]។ សក្ខីកម្មរបស់គាត់មានភាពស៊ីសង្វាក់គ្នានឹងរបាយការណ៍ថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ របស់គាត់ ពោលគឺថា ទោះបីមានភាពទន់ខ្សោយផ្នែករូបរាងកាយក៏ដោយ ក៏លោក អៀង សារី មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមកិច្ចដំណើរការនីតិវិធី ដរាបណាមានការអនុវត្តតាមអនុសាសន៍តិចតួច ដូចជាត្រូវពាក់ទ្រនាប់កទន់ ជាដើម។ លោកសាស្ត្រាចារ្យ Campbell មើលមិនឃើញមានបញ្ហាណាមួយចំពោះលោក អៀង សារី ដែលសម្រាន្តក្នុងពេលសវនាការទេ ដោយគាត់ពន្យល់ថា៖ "នាពេលនេះ ខ្ញុំបានងោកងុយក្នុងការស្តាប់បឋកថាកន្លងមក ហើយវាមិនមានន័យថាខ្ញុំមិនមានសមត្ថភាពផ្ចង់អារម្មណ៍នោះទេ។ ហើយតាមការពិនិត្យលោក អៀង សារី ខ្ញុំរកមិនឃើញភស្តុតាងថា គាត់មិនអាចផ្ចង់អារម្មណ៍បាននោះទេ។ ការលើកឡើងដូច្នេះពុំមានន័យថា [sic] គាត់មិនងោកងុយម្តងម្កាលនោះទេ ដូចខ្ញុំបាននិយាយខាងដើមហើយថា ពួកយើងជាច្រើននាក់សុទ្ធតែធ្លាប់ងោកងុយ ប្រសិនបើនៅពេលណាមួយ វាគ្មានអ្វីច្រើនដែលគួរឲ្យយើងចាប់អារម្មណ៍ចង់ស្តាប់នោះ"[20]។ បន្ទាប់ពីសក្ខីកម្មរបស់សាស្ត្រាចារ្យ Campbell បានបញ្ចប់ អង្គជំនុំជម្រះសាលាដំបូង បានជូនដំណឹងភាគីថា នៅថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១២ ភាគីត្រូវបានផ្តល់ឱកាស

---

[18] *ដូចខាងលើ*។

[19] ប្រតិចារឹក, ថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ២០១២, ឯកសារ E1/142.1។

[20] *ដូចខាងលើ*, ទំព័រ ៥៦ (ភាសាអង់គ្លេស)។

រយៈពេលខ្លីដើម្បីធ្វើការកត់សម្គាល់ និងធ្វើសេចក្ដីសង្កេតពាក់ព័ន្ធនឹងរបាយការណ៍របស់លោកសាស្ត្រាចារ្យ Campbell[21]។

13. កាលពីថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១២ មេធាវីការពារក្ដី បានលើកសំណើផ្ទាល់មាត់ស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង តែងតាំងអ្នកជំនាញបន្ថែមម្នាក់ពិនិត្យលោក អៀង សារី ដើម្បីវាយតម្លៃសម្បទារបស់គាត់ក្នុងការចូលរួមសវនាការ ដោយសារលោកវេជ្ជបណ្ឌិត Bursztajn បានរិះគន់ចំពោះវិធីសាស្ត្ររបស់លោកសាស្ត្រាចារ្យ Campbell និង ដោយសារការសង្កេតរបស់ក្រុមមេធាវីការពារពាក់ព័ន្ធនឹងសម្បទារបស់លោក អៀង សារី ក្នុងការចូលរួមការជំនុំជម្រះ មានភាពផ្ទុយគ្នាស្រឡះពីការសង្កេតរបស់លោកសាស្ត្រាចារ្យ Campbell[22]។ មេធាវីការពារក្ដីបានលើកឡើងថា ការលើកឡើងនូវសារណាអំពីសម្បទារបស់លោក អៀង សារី ត្រង់ចំណុចនោះជាការឆាប់រហ័សពេក[23]។ មេធាវីការពារក្ដីបានអះអាងថា បច្ចុប្បន្ននេះ លោក អៀង សារី ពុំមានកាយសម្បទាដើម្បីចូលរួមសវនាការទេ ប៉ុន្តែសវនាការអាចបន្តទៅមុខបានជាមួយសាក្សីដែលលោក អៀង សារី បានលះបង់សិទ្ធិមានវត្តមាននៅពេលសវនាការ ដោយសង្ឃឹមថាសុខភាពរបស់លោក អៀង សារី នឹងអាចប្រសើរឡើង[24]។ សហព្រះរាជអាជ្ញាបានស្នើឡើងថា សវនាការគួរបន្តទៅមុខដោយឲ្យលោក អៀង សារី ចូលរួមពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ហើយបានស្នើឡើងបន្ថែមថា អង្គជំនុំជម្រះសាលាដំបូងត្រូវសម្រេចលើសម្បទារបស់លោក អៀងសារី នៅពេលនេះ ជាជាងរង់ចាំរហូតដល់ពេលសុខភាពរបស់គាត់មានលក្ខណៈប្រសើរឡើង[25]។ សហព្រះរាជអាជ្ញាលើកឡើងថា មិន

---

[21] *ដូចខាងលើ,* ទំព័រ ១៤០ (ភាសាអង់គ្លេស)។

[22] ប្រតិចារឹក, ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១២, ឯកសារ E1/143.1, ទំព័រ ៧ ដល់ ១១ (ភាសាអង់គ្លេស)។

[23] *ដូចខាងលើ,* ទំព័រ ៥ ដល់ ៦ (ភាសាអង់គ្លេស) "លោកត្រូវតែចាំថា យើងដែលជាមេធាវីការពារក្ដី លោកអៀង សារី មិនបានធ្វើសំណើណាមួយ សុំឲ្យមានការបញ្ឈប់កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងលោក អៀង សារី ឡើយ" *ដូចខាងលើ,* ទំព័រ ៥ (ភាសាអង់គ្លេស)។

[24] *ដូចខាងលើ,* ទំព័រ ១១ ដល់ ១២ (ភាសាអង់គ្លេស)។

[25] *ដូចខាងលើ,* ទំព័រ ២៥ ដល់ ៣០ (ភាសាអង់គ្លេស)។

មានភាពចាំបាច់ក្នុងការតែងតាំងអ្នកជំនាញបន្ថែមទៀតឡើយ[26]។ ដើមបណ្ដឹងរដ្ឋប្បវេណីបានគាំទ្រចំពោះការលើកឡើងរបស់សហព្រះរាជអាជ្ញា[27]។

14. នៅថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្ដីសម្រេចរបស់ខ្លួនដោយសម្រេចថា លោក អៀង សារី មានសម្បទាចូលរួមការជំនុំជម្រះ និងបដិសេធចោលសំណើរបស់មេធាវីការពារក្ដីសុំតែងតាំងអ្នកជំនាញវេជ្ជសាស្ត្របន្ថែម[28]។ នៅក្នុងសេចក្ដីសម្រេចនេះ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាថា តើអង្គជំនុំជម្រះគួរតែបង្គាប់ឲ្យលោក អៀង សារី ចូលរួមក្នុងកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ឬយ៉ាងណា។ អង្គជំនុំជម្រះបានកត់សម្គាល់ថា ភាពទន់ខ្សោយផ្នែករូបរាងកាយរបស់លោក អៀង សារី បានបង្កើតជាការប្រឈមមួយចំនួនក្នុងការរៀបចំសវនាការ និងបានបណ្ដាលឲ្យមានថ្ងៃសវនាការចំនួន ១២ ថ្ងៃ ត្រូវផ្អាកដោយផ្នែក ឬទាំងស្រុង[29]។ អង្គជំនុំជម្រះ "កត់សម្គាល់បន្ថែមលើការបញ្ជាក់របស់គ្រូពេទ្យជំនាញខាងព្យាបាលមនុស្សចាស់ថា [លោក អៀង សារី] អាចផ្ដោតអារម្មណ៍បានយ៉ាងល្អ នៅពេលដែលគាត់ទម្រេតខ្លួនចុះ និងលើកឡើងថា ដោយពិចារណាអំពីភាពទន់ខ្សោយកាន់តែដុនដាប តម្រូវការផ្នែកវេជ្ជសាស្ត្ររបស់ [លោក អៀង សារី] ត្រូវបានផ្ដល់ឲ្យស្ទើរតែបានសមស្របទៅហើយនៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ"[30]។ អង្គជំនុំជម្រះសាលាដំបូងមិនបានពិចារណាថតវីដេអូពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការថាជាការចាំបាច់ទេ ដោយសារមេធាវីការពារក្ដី និងអង្គភាពវេជ្ជសាស្ត្ររបស់ អ.វ.ត.ក អាចចេញចូលបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការបានគ្រប់ពេល[31]។ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា អង្គជំនុំជម្រះអាចបង្គាប់ឲ្យលោក អៀង សារី ចូលរួមតាមរយៈមធ្យោបាយសោតទស្សន៍ "ដើម្បីជាប្រយោជន៍យុត្តិធម៌" និងផ្ដល់ការជូនដំណឹង

---

[26] *ដូចខាងលើ,* ទំព័រ ៣៦ ដល់ ៣៧ (ភាសាអង់គ្លេស)។

[27] *ដូចខាងលើ,* ទំព័រ ៣៩ ដល់ ៤២ (ភាសាអង់គ្លេស)។

[28] សេចក្ដីសម្រេចស្ដីពីសម្បទាជនជាប់ចោទ អៀង សារី ក្នុងការចូលរួមសវនាការ, ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១២, ឯកសារ E238/9។

[29] *ដូចខាងលើ,* កថាខណ្ឌ ៣៥។

[30] *ដូចខាងលើ,* កថាខណ្ឌ ៣៦។

[31] *ដូចខាងលើ*។

ជាមុនដល់ភាគីថា អង្គជំនុំជម្រះអាចសម្រេចឱ្យប្រើប្រាស់មធ្យោបាយនេះ នៅពេលដែលវត្តមានរបស់គាត់នៅក្នុងបន្ទប់សវនាការ អាចនឹងផ្ទុយពីស្ថានភាពផ្នែកវេជ្ជសាស្ត្ររបស់គាត់ និង/ផ្ទុយនឹងការប្រព្រឹត្តទៅឱ្យបានឆាប់រហ័សនៃការជំនុំជម្រះ[32]។

15. នៅថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០១២ លោក អៀង សារី បានជូនដំណឹងទៅអង្គជំនុំជម្រះសាលាដំបូងពីការដកហូតលិខិតលះបង់[33] សិទ្ធិមានវត្តមានរបស់គាត់ក្នុងអំឡុងពេលនៃការផ្តល់សក្ខីកម្មរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន ដែលគាត់បានចុះហត្ថលេខាក្នុងពេលសម្រាកក្នុងមន្ទីរពេទ្យ។ គាត់បានជូនដំណឹងបន្ថែមទៀតទៅអង្គជំនុំជម្រះសាលាដំបូងថា គាត់មានបំណងអនុវត្តសិទ្ធិរបស់ខ្លួនក្នុងការមានវត្តមាននៅក្នុងបន្ទប់សវនាការ ក្នុងអំឡុងពេលនៃការផ្តល់សក្ខីកម្មរបស់សាក្សីទាំងអស់[34]។

### ខ. សេចក្តីសម្រេចដែលត្រូវបានជំទាស់

16. នៅថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០១២ កិច្ចដំណើរការនីតិវិធីជំនុំជម្រះចាប់ផ្តើមបន្តទៅទៀត។ លោក អៀង សារី មិនត្រូវបាននាំមកកាន់បន្ទប់សវនាការទៅតាមសំណើរបស់គាត់ទេ តែគាត់ត្រូវបាននាំខ្លួនទៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការវិញ។ នាពេលព្រឹកនោះ របាយការណ៍មួយរបស់វេជ្ជបណ្ឌិតនៅ អ.វ.ត.ក បាននិយាយថា បើតាមយោបល់របស់វេជ្ជបណ្ឌិត លោក អៀង សារី មិនអាចតាមដានកិច្ចដំណើរការនីតិវិធីនៅក្នុងបន្ទប់សវនាការបានទេ ហើយគាត់គួរតែនៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ដោយសារគាត់មានការហត់ខ្លាំង នៅពេលគាត់ធ្វើចលនា

---

[32] *ដូចខាងលើ,* កថាខណ្ឌ ៣៧។

[33] ពាក្យសុំលះបង់សិទ្ធិមានវត្តមានមានដែនកំណត់ក្នុងកិច្ចដំណើរការនីតិវិធីរបស់លោក អៀង សារី, ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១២, ឯកសារ E229; ពាក្យសុំលះបង់សិទ្ធិមានវត្តមានមានដែនកំណត់ក្នុងកិច្ចដំណើរការនីតិវិធីរបស់លោក អៀង សារី, ថ្ងៃទី ១ ខែ តុលា ឆ្នាំ ២០១២, ឯកសារ E237; ពាក្យសុំលះបង់សិទ្ធិមានវត្តមានមានដែនកំណត់ក្នុងកិច្ចដំណើរការនីតិវិធីរបស់លោក អៀង សារី, ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១២, ឯកសារ E237/1។

[34] ការដកហូតលិខិតលះបង់សិទ្ធិរបស់លោក អៀង សារី ក្នុងការមានវត្តមាន, ថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០១២, ឯកសារ E237/2; ការជូនដំណឹងរបស់ អៀង សារី អំពីការដកពាក្យសុំលះបង់សិទ្ធិមានវត្តមានក្នុងអំឡុងការធ្វើសក្ខីកម្មរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន, ថ្ងៃទី ៦ ខែ ធ្នូ ឆ្នាំ ២០១២, ឯកសារ E249។

បន្តិចបន្តួច និងចុកទ្រូង សំរាន្តមិនលក់ ហូបបានមិនបាន និង ក្អួត[35]។ សហមេធាវីអន្តរជាតិលោក Michael G. Karnavas បានស្នើសុំឱ្យនាំ លោក អៀង សារី ចូលមកក្នុងបន្ទប់សវនាការ ឬយ៉ាងហោចណាស់ក៏មានថតរូបភាពវីដេអូពីក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ដោយអង្គភាពសោតទស្សន៍ក៏បាន ឬយ៉ាងហោចណាស់ក៏ពីក្រុមមេធាវីការពារក្តីដែរ ដើម្បីឱ្យអង្គជំនុំជម្រះសាលាដំបូងអាចសង្កេតពីស្ថានភាពរបស់គាត់បាន[36]។ គាត់បានថ្លែងថា៖

> ក្នុងនាមជាមេធាវី ខ្ញុំតែងគិតថា នេះជាតួនាទី និងការទទួលខុសត្រូវរបស់មេធាវីក្នុងការពារសិទ្ធិរបស់កូនក្តី។ ដូច្នេះ របៀបដែលយើងធ្វើការតាមដានកូនក្តីចង់ដឹងថា តើគាត់មានសមត្ថភាពក្នុងការតាមដានសវនាការ ពីមួយពេលទៅមួយពេល ពីមួយម៉ោងទៅមួយម៉ោង ពីមួយថ្ងៃទៅមួយថ្ងៃ ក្នុងការតាមដានកិច្ចដំណើរការនីតិវិធីនោះឬទេ? យើងមិនអាចនិយាយបានទេថា ប្រសិនបើគាត់នៅខាងក្រោមហើយមានទូរទស្សន៍មើលហ្នឹង វាអាចបញ្ជាក់ថា គាត់មានវត្តមាន ហើយអាចតាមដានកិច្ចដំណើរការនីតិវិធី។ នោះវាមិនគ្រប់គ្រាន់ទេ។ អាចថា ខ្ញុំលើកឧទាហរណ៍មួយ ខ្ញុំគេងលក់នៅលើសាឡុង ហើយទូរទស្សន៍ក៏បើកចោល មិនមែនខ្ញុំកំពុងមើលអ្វីដែលមាននៅលើកញ្ចក់ទូរទស្សន៍ទេ។ តើខ្ញុំកំពុងមានវត្តមាននៅក្នុងបន្ទប់ទទួលភ្ញៀវឬ? បាទ តែនោះជាអ្វីដែលយើង [មិន] កំពុងនិយាយនោះឡើយ[37]។

អង្គជំនុំជម្រះសាលាដំបូងបានពិភាក្សាគ្នា ហើយលោកស្រីចៅក្រម Cartwright បានអានសេចក្តីសម្រេចដែលត្រូវបានជំទាស់ថា៖

---

[35] ឯកសារ E1/147.2. កត់សម្គាល់ថា របាយការណ៍នេះត្រូវបានចាត់ថ្នាក់ជាឯកសារសម្ងាត់បំផុត ទោះបីលោក អៀង សារី បានជូនដំណឹងថា បញ្ហាសុខភាពរបស់គាត់គួរត្រូវផ្សព្វផ្សាយជាសាធារណៈក៏ដោយ។ *សូមមើល* ការយល់ព្រមរបស់លោក អៀង សារី ចំពោះការពិភាក្សាជាសាធារណៈលើបញ្ហាសុខភាពរបស់គាត់, ចុះថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ២០១២, ឯកសារ E1/142.2។

[36] ប្រតិចារឹក, ថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០១២, ឯកសារ E1/147.1, ទំព័រ ១២ ដល់ ១៥ (ភាសាអង់គ្លេស)។

[37] *ដូចខាងលើ,* ទំព័រ ១៣ (ភាសាអង់គ្លេស)។

ជាចំណុចចាប់ផ្តើម អង្គជំនុំជម្រះសាលាដំបូងចេញសេចក្តីសម្រេចលើសម្បទារបស់ លោក អៀង សារី ក្នុងការចូលរួមសវនាការ។ សេចក្តីសម្រេចនេះសំអាងទៅលើសក្ខីកម្មរបស់អ្នកជំនាញ និងភស្តុតាងនានាដែលពាក់ព័ន្ធ ហើយបានផ្តល់ឱកាសឲ្យភាគីទាំងអស់ដាក់នូវសំណើសុំផ្សេងៗ។ នេះគឺជាចំណុចចាប់ផ្តើមនៃសេចក្តីសម្រេចនេះ ក៏ប៉ុន្តែអ្នកជំនាញបានបញ្ជាក់ថា ស្ថានភាពផ្នែករូបរាងកាយរបស់លោក អៀង សារី អាចនឹងប្រែប្រួលពីពេលមួយទៅពេលមួយ ហើយអង្គជំនុំជម្រះសាលាដំបូងបានពិចារណាទៅលើចំណុចនេះ ហើយពិចារណាសម្រេចទៅលើស្ថានភាពសុខភាពរបស់គាត់។ ដោយយល់ឃើញថា វេជ្ជបណ្ឌិតព្យាបាលលោក អៀង សារី បានចេញនូវរបាយការណ៍វេជ្ជសាស្ត្រមួយជូនអង្គជំនុំជម្រះនៅព្រឹកនេះ ដោយផ្តោតទៅលើការពិនិត្យសុខភាពជនជាប់ចោទនៅថ្ងៃនេះ ហើយជាភាសាអង់គ្លេស សេចក្តីសង្ខេបនៃរបាយការណ៍គឺថា លោក អៀង សារី មិនអាចតាមដានកិច្ចដំណើរការនីតិវិធីនៅក្នុងបន្ទប់សវនាការបានទេ។ ហើយវេជ្ជបណ្ឌិតបានស្នើសុំថា អង្គជំនុំជម្រះត្រូវអនុញ្ញាតឲ្យលោក អៀង សារី ចូលទៅតាមដាននៅបន្ទប់ខាងក្រោម ដើម្បីអាចនឹងឲ្យវេជ្ជបណ្ឌិតត្រៀមខ្លួនជាស្រេចតាមដានពិនិត្យសុខភាពរបស់លោក អៀង សារី។ ដោយពិចារណាទៅលើសំណើសុំដោយមេធាវីការពារក្តីអន្តរជាតិរបស់គាត់ លោក អៀង សារី បានលើកឡើងនូវចំណុចបឋមថា "វាជាការចាំបាច់ដែលសម្បទារបស់លោក អៀង សារី គឺអាចសំអាងតែទៅលើមតិយោបល់ផ្នែកពេទ្យ"។ ហើយអង្គជំនុំជម្រះបានសម្រេចថា យោងទៅតាមវិធាន ៨១(៥) ការលំបាកដែលបណ្តាលឲ្យលោក អៀង សារី មិនអាចចូលរួមមកក្នុងបន្ទប់សវនាការបាននោះ ឬក៏លំបាកដែលនឹងអនុញ្ញាតឲ្យគាត់ចូលមកបាននោះ គឺថាអាចនឹងធ្វើឲ្យសវនាការនេះមានការពន្យារយ៉ាងវែង។ ហេតុដូច្នេះ អង្គជំនុំជម្រះបង្គាប់ឲ្យលោក អៀង សារី តាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។ ហើយអង្គជំនុំជម្រះក៏ពិចារណាផងដែរថា ការគាំទ្រផ្នែកបច្ចេកទេសទាំងអស់ ដើម្បីគាំទ្រទៅដល់ការតាមដានកិច្ចដំណើរការនីតិវិធីនៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។ ក្នុងនោះមានការភ្ជាប់ខ្សែទូរស័ព្ទដើម្បីទាក់ទងជាមួយនឹងមេធាវីរបស់គាត់។ អង្គជំនុំជម្រះក៏

បានគិតថា ការតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ខាងក្រោមដែលបានស្នើសុំដោយអ្នកជំនាញ ដោយសារហេតុនេះឯង ជាពិសេស គឺថាត្រូវតែបំពាក់ប្រព័ន្ធបច្ចេកទេស ដើម្បីឲ្យគាត់អាចតាមដានបាន ហើយសម្ភារៈដែលបានស្នើសុំដោយអ្នកជំនាញត្រូវតែបំពាក់ឲ្យបានសមស្រប ដើម្បីឲ្យលោក អៀង សារី តាមដាននៅក្នុងកាលៈទេសៈនេះ ឲ្យបានសមស្របជាងនៅក្នុងបន្ទប់សវនាការនេះទៅទៀត។ ទាក់ទងទៅនឹងកាតព្វកិច្ចដែលត្រូវតាមដានសុខភាពសម្បទារបស់លោក អៀង សារី ជាបន្តទៅទៀត អង្គជំនុំជម្រះសង្ឃឹមទៅលើគ្រូពេទ្យព្យាបាលដែលអាចនឹងជម្រាបមកអង្គជំនុំជម្រះ នូវការប្រែប្រួលណាមួយជាបន្ទាន់នៃស្ថានភាពសុខភាពរបស់លោក អៀង សារី។ ហើយអង្គជំនុំជម្រះក៏សូមបញ្ជាក់ផងដែរថា ការតាមដានផ្នែកសុខភាពនេះគឺថា គឺជាភារកិច្ចរបស់គ្រូពេទ្យតាមដាន មិនមែនជាភារកិច្ចរបស់មេធាវី ឬក៏ចៅក្រម ឬសារសាធារណជន ដោយផ្ទាល់នោះទេ។ ដោយហេតុផលនេះ អង្គជំនុំជម្រះបដិសេធមិនសម្រេចឲ្យថតវីដេអូពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ រួចបញ្ជាំងចូលមកក្នុងបន្ទប់សនាការទេ។ យើងសង្ឃឹមទៅលើគ្រូពេទ្យព្យាបាល ជាអ្នកផ្តល់ព័ត៌មានអំពីស្ថានភាពសុខភាពរបស់លោកអៀង សារី មកឲ្យពួកយើង[38]។

បន្ទាប់មក លោកស្រីចៅក្រម Cartwright បានបញ្ជាក់ច្បាស់ថា៖

បញ្ហាចម្បងបំផុតសម្រាប់អង្គជំនុំជម្រះសាលាដំបូងគឺ បញ្ហានៃការវាយតម្លៃទៅលើស្ថានភាពសុខភាពនៃសម្បទារបស់លោក អៀង សារី ក្នុងការចូលរួមក្នុងសវនាការ។ ហេតុដូច្នេះឯង ការតាមដានសុខភាពដោយគ្រូពេទ្យព្យាបាលគាត់នេះគឺជារឿងសំខាន់ណាស់។ វាជាមធ្យោបាយដែលជួយបង្កលក្ខណៈជម្រាបដល់អង្គជំនុំជម្រះ ក៏ដូចជាភាគីទាំងអស់អំពីស្ថានភាពសុខភាពរបស់លោក អៀង សារី បើមានការកែប្រែណាមួយ។ នេះជាហេតុផលមួយដែលសមស្របសម្រាប់បង្កលក្ខណៈឲ្យគាត់ស្ថិតនៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ដែល

---

[38] *ដូចខាងលើ,* ទំព័រ ១៧ ដល់ ១៩ (ភាសាអង់គ្លេស)។

គ្រូពេទ្យអាចពិនិត្យ តាមដានសុខភាពរបស់គាត់។ ក្រុមមេធាវីការពារក្តីរបស់លោក អៀង សារី អាចឲ្យបុគ្គលិកណាម្នាក់ពីក្រុមរបស់ខ្លួនចូលទៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ បើសិនណាជាក្រុមមេធាវីការពារក្តីយល់ឃើញថា សមាជិកនៃក្រុមការពារក្តីនោះ អាចនឹងធ្វើសេចក្តីសន្និដ្ឋានទៅលើស្ថានភាពសុខភាពរបស់លោក អៀង សារី ជម្រាបគ្រូពេទ្យព្យាបាលបាន។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះនឹងមិនអនុញ្ញាតឲ្យមានការថតវីដេអូទេ[39]។

## គ. ព្រឹត្តិការណ៍ពាក់ព័ន្ធនានាបន្ទាប់ពីចេញសេចក្តីសម្រេចដែលត្រូវបានជំទាស់

17. នៅថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០១២ បន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេច មេធាវីការពារក្តីបានដាក់មន្ត្រីសំណុំរឿងរបស់ខ្លួនគឺលោក សូ មូស្សេទ្ធី (ដែលជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាតាំងពីឆ្នាំ ២០០៣ មក និងមានបទពិសោធន៍ជាច្រើនផ្នែកច្បាប់)[40] ទៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។ លោក សូ មូស្សេទ្ធី បាននៅប្រចាំការក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការជារៀងរាល់ថ្ងៃ ដើម្បីកត់ត្រានូវការសង្កេតរបស់ខ្លួនចំពោះលោក អៀង សារី នៅក្នុងតារាងពេលវេលានៃការសង្កេតប្រចាំថ្ងៃ ហើយទាក់ទងវេជ្ជបណ្ឌិតភ្លាម នៅពេលចាំបាច់។

18. នៅថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០១២ មេធាវីការពារក្តីបានផ្សព្វផ្សាយនូវសំណៅចម្លងរបស់មន្ត្រីគ្រប់គ្រងសំណុំរឿងរបស់ខ្លួនចំពោះការសង្កេតទៅលើលោក អៀង សារី នៅថ្ងៃកន្លងមក[41]។ នៅពេលចាប់ផ្តើមកិច្ចដំណើរការនីតិវិធីជំនុំជម្រះ សហមេធាវីអន្តរជាតិលោក Michael G. Karnavas បានជូនដំណឹងទៅអង្គជំនុំជម្រះសាលាដំបូងថា មន្ត្រីគ្រប់គ្រងសំណុំរឿងមានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួន

---

[39] *ដូចខាងលើ,* ទំព័រ ២៧ ដល់ ២៨ (ភាសាអង់គ្លេស)។

[40] មុនពេលចូលរួមបម្រើការងារនៅ អ.វ.ត.ក លោក សូ មូស្សេទ្ធី គឺជាអនុប្រធានគម្រោងតាមដានតុលាការសម្រាប់មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម។ បច្ចុប្បន្នគាត់មានឈ្មោះក្នុងបញ្ជីមេធាវីជាតិរបស់អង្គភាពគាំពារការការពារក្តី ដែលមានគុណសម្បត្តិក្លាយជាសហមេធាវីនៅ អ.វ.ត.ក បាន។

[41] តារាងពេលវេលានៃការសង្កេតលើបញ្ហាសុខភាពរបស់លោក អៀង សារី ថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០១២, ចុះថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០១២, ឯកសារ E248/2.1។

ខាងក្រោមសាលសវនាការដើម្បីកត់ត្រាស្ថានភាពសុខភាពរបស់លោក អៀង សារី ហើយ មេធាវីការពារក្តីមានបំណងដាក់សេចក្តីសង្កេតប្រចាំថ្ងៃរបស់ខ្លួនស្តីពីស្ថានភាពរបស់លោក អៀង សារី[42] ទៅក្នុងសំណុំរឿង។ លោក Karnavas ក៏បានគូសបញ្ជាក់ផងដែរថា ទោះបីរបាយការណ៍វេជ្ជសាស្ត្រនៅថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០១២ របស់វេជ្ជបណ្ឌិតនៅ អ.វ.ត.ក បានអះអាងថា លោក អៀង សារី នឹងមានផាសុកភាពក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការជាងក្នុងបន្ទប់សវនាការក៏ដោយ ក៏ផាសុកភាពនោះមិនអាចឲ្យគាត់អាចតាមដានកិច្ចដំណើរការនីតិវិធីបានទេ[43]។ លោកស្រីចៅក្រម Cartwright បានជូនដំណឹងទៅមេធាវីការពារក្តីថា អង្គជំនុំជម្រះសាលាដំបូង "ក្នុងការសម្រេចពាក់ព័ន្ធទៅនឹងលទ្ធភាពរបស់លោក អៀង សារី ក្នុងការចូលរួមសវនាការ ផ្តោតជាសំខាន់ទៅលើរបាយការណ៍ពេទ្យ"[44]។ លោក Karnavas បានបញ្ជាក់ថា៖ "យើងខ្ញុំមិនវាយតម្លៃលទ្ធភាពរបស់កូនក្តីយើងខ្ញុំទេ គឺគ្រាន់តែចូលរួមសង្កេតទៅលើស្ថានភាព ដែលអាចមានប្រយោជន៍សម្រាប់អង្គជំនុំជម្រះសាលាដំបូង ឬសម្រាប់គ្រូពេទ្យដែលមិនបានស្ថិតនៅក្នុងបន្ទប់គ្រប់ពេល តែគ្រាន់តែមកពិនិត្យម្តង ឬពីរដងក្នុងមួយថ្ងៃនោះ"[45]។ ជំនួយការជាន់ខ្ពស់នៃសហព្រះរាជអាជ្ញា លោក Keith Raynor បានស្នើសុំអង្គជំនុំជម្រះសាលាដំបូង "ធ្វើយ៉ាងណាឲ្យរបាយការណ៍ពេទ្យដែលបញ្ជូនមកអង្គជំនុំជម្រះជារៀងរាល់ព្រឹក ត្រូវតែមានព័ត៌មានលម្អិតអំពីលទ្ធភាពរបស់លោក អៀង សារី ក្នុងការតាមដានកិច្ចដំណើរការនីតិវិធី"[46]។ បន្ទាប់ពីការសម្រាកលើកទី១ នៅពេលព្រឹក សហមេធាវីជាតិលោក អាង ឧត្តម បានជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូងថា លោក អៀង សារី បានសម្រាន្តលក់ពេលសវនាការនៅពេលព្រឹក[47]។ ចៅក្រមក៏បានពិភាក្សាគ្នា ហើយលោកស្រីចៅក្រម Cartwright បានថ្លែងថា អង្គជំនុំជម្រះសាលាដំបូង៖

---

[42] ប្រតិចារឹក, ថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០១២, ឯកសារ E1/148.1, ទំព័រ ២ (ភាសាអង់គ្លេស)។ *សូមមើល* ឧបសម្ព័ន្ធ ក-គ ដែលភ្ជាប់មកជាមួយ រួមមានតារាងពេលវេលានៃការសង្កេតដែលបានដាក់ដោយមេធាវីការពារក្តី។

[43] ប្រតិចារឹក, ថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០១២, ឯកសារ E1/148.1, ទំព័រ ២ (ភាសាអង់គ្លេស)។

[44] *ដូចខាងលើ,* ទំព័រ ៤ (ភាសាអង់គ្លេស)។

[45] *ដូចខាងលើ,* ទំព័រ ៥ (ភាសាអង់គ្លេស)។

[46] *ដូចខាងលើ,* ទំព័រ ៦ (ភាសាអង់គ្លេស)។

[47] *ដូចខាងលើ,* ទំព័រ ៣៦ ដល់ ៣៧ (ភាសាអង់គ្លេស)។

សូមលើកឡើងម្តងទៀតថា ការចាប់ផ្តើមនៅក្នុងការវាយតម្លៃពីលទ្ធភាពរបស់លោក អៀង សារី ក្នុងការចូលរួមក្នុងសវនាការ គឺផ្អែកទៅលើរបាយការណ៍របស់អ្នកជំនាញ។ វាជាការចាប់អារម្មណ៍ដែលថា លោកបានលើកឡើងថា លោក អៀង សារី កំពុងតែសម្រាន្តលក់នៅព្រឹកមិញនេះ។ យើងមានដំណោះស្រាយងាយស្រួលទេ ឲ្យមន្ត្រីគ្រប់គ្រងសំណុំរឿងរបស់លោកដាស់គាត់ឲ្យភ្ញាក់មក។ វាមិនមែនជាបញ្ហាសុខភាពបញ្ហាស្មារតីរបស់គាត់នោះទេ ដូចអ្នកជំនាញបានបញ្ជាក់ច្បាស់ហើយថា លោក អៀង សារី ខ្លួនឯងមិនដែលអះអាងថា ខ្លួនមានបញ្ហាស្មារតីមិនគ្រប់គ្រាន់នោះឡើយ។ ម្យ៉ាងវិញទៀត ការសម្រាន្តលក់នោះគឺគ្រាន់តែបង្ហាញថា គាត់មិនចាប់អារម្មណ៍ នៅក្នុងការស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះប៉ុណ្ណោះ។ អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា គ្រូពេទ្យព្យាបាលនឹងចេញរបាយការណ៍មកឲ្យអង្គជំនុំជម្រះ ប្រសិនបើសង្កេតឃើញមានការនឿយហត់អស់កម្លាំងណាមួយខ្លាំង ចំពោះលោក អៀង សារី[48]។

19. កាលពីថ្ងៃទី ៦ ខែ ធ្នូ ឆ្នាំ ២០១២ មេធាវីការពារក្តីបានចែកឯកសារស្តីពីសេចក្តីសង្កេតអំពីលោក អៀង សារី របស់មន្ត្រីទទួលបន្ទុកសំណុំរឿងរបស់ខ្លួន ដែលបានធ្វើកាលពីមួយថ្ងៃមុន[49]។ សេចក្តីសង្កេតទាំងនេះបានបញ្ជាក់ថាវេជ្ជបណ្ឌិត លឹម ស៊ីវុតថា បានមានប្រសាសន៍ថាគាត់ពុំអាចវាយតម្លៃអំពីសមត្ថភាពផ្នែកស្មារតីរបស់លោក អៀង សារី ក្នុងការតាមដានកិច្ចដំណើរការនីតិវិធីបានឡើយ ដោយហេតុថាគាត់ពុំមែនជាវេជ្ជបណ្ឌិតឯកទេសជំងឺផ្លូវចិត្ត[50]។ នៅពេលចាប់ផ្តើមកិច្ចដំណើរការនីតិវិធី លោក អាង ឧត្តម បានជូនដំណឹងទៅអង្គជំនុំជម្រះសាលាដំបូងថាលោក អៀង សារី ពុំបានសម្រាន្តលក់ស្រួលឡើយកាលពីយប់មុន ហើយគាត់ជ្រើសរើសបន្តស្ថិតនៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ[51]។ បន្ថែមពីលើនេះទៀត គាត់បានជូនដំណឹងទៅអង្គជំនុំជម្រះ

---

[48] *ដូចខាងលើ,* ទំព័រ ៣៧ ដល់ ៣៨ (ភាសាអង់គ្លេស)។

[49] តារាងពេលវេលានៃការសង្កេតលើលទ្ធភាពរបស់លោក អៀង សារី ក្នុងការតាមដានកិច្ចដំណើរការនីតិវិធី និងចូលរួមក្នុងការការពារក្តីរបស់លោក ថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០១២, ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១២, ឯកសារ E248.1។

[50] *ដូចឯកសារយោងខាងលើ,* ត្រង់វេលាម៉ោង ៨:៥៥ នាទីព្រឹក-៩:១០ នាទីព្រឹក។

[51] ប្រតិចារឹក, ថ្ងៃទី ៦ ខែ ធ្នូ ឆ្នាំ ២០១២, ឯកសារ E1/149.1, ទំព័រ ៣។

សាលាដំបូងថា របាយការណ៍វេជ្ជសាស្ត្រនៃថ្ងៃទី ៦ ខែ ធ្នូ ឆ្នាំ ២០១២ ពុំបានបញ្ជាក់ថាតើលោក អៀង សារី មានសមត្ថភាពដើម្បីចូលរួមកិច្ចដំណើរការនីតិវិធីដែរ ឬយ៉ាងណាឡើយ[52]។

20. កាលពីថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១២ មេធាវីការពារក្តីបានចែកនូវឯកសារស្តីពីសេចក្តីសង្កេតអំពីលោក អៀង សារី របស់មន្ត្រីទទួលបន្ទុកសំណុំរឿងរបស់ខ្លួនដែលបានធ្វើកាលពីមួយថ្ងៃមុន[53]។ ឯកសារនេះបានបញ្ជាក់ថា វេជ្ជបណ្ឌិត កឹម សមសាន្ត បានមានប្រសាសន៍ថា គាត់ពុំមានសមត្ថភាពដើម្បីវាយតម្លៃអំពីសមត្ថភាពរបស់ លោក អៀង សារី ក្នុងការតាមដានកិច្ចដំណើរការនីតិវិធីឡើយ[54]។ នៅវេលាថ្ងៃដដែល មេធាវីការពារក្តីបានទទួលសារអេឡិចត្រូនិកមួយច្បាប់ពីមន្ត្រីច្បាប់នៃអង្គជំនុំជម្រះសាលាដំបូង ដែល*ក្នុងចំណោមចំណុចផ្សេងៗ* បានបញ្ជាក់ថា៖

> អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ឃើញថា ដោយគ្មានការអនុញ្ញាតជាមុនពី អង្គជំនុំជម្រះសាលាដំបូង មេធាវីការពារក្តី អៀង សារី បានបង្គាប់ឲ្យមន្ត្រីទទួលបន្ទុកសំណុំរឿងរបស់ខ្លួន ថតជាខ្សែអាត់សំឡេងចំពោះជនជាប់ចោទ និងកិច្ចសន្ទនានានាជាមួយគ្រូពេទ្យព្យាបាលជនជាប់ចោទ (*សូមមើល ឧទាហរណ៍* ឯកសារ E248.1) និងដាក់កំណត់ហេតុនៃការសង្កេតទាំងនេះ។ អង្គជំនុំជម្រះបង្គាប់ឲ្យមេធាវីការពារក្តី អៀង សារី បញ្ឈប់ការថតខ្សែអាត់សំឡេងនេះជាបន្ទាន់។ ប្រសិនបើមេធាវីការពារក្តី អៀង សារី មានបំណងចង់បន្តការថតខ្សែអាត់សំឡេងរបស់ជនជាប់ចោទ និង/ឬ គ្រូពេទ្យព្យាបាលជនជាប់ចោទនោះ មេធាវីការពារក្តី អៀង សារី ត្រូវស្នើសុំការអនុញ្ញាតជាមុនដោយអនុលោមតាមវិធាន ៩២ នៃវិធានផ្ទៃក្នុង ដោយបញ្ជាក់អំពីហេតុផលទាំងឡាយដែលអាចអនុញ្ញាតឲ្យធ្វើដូច្នេះក្រោមក្របខណ្ឌគតិយុត្ត អ.វ.ត.ក...។ ការធ្វើសេចក្តីសង្កេតណាមួយរបៀបនេះតទៅទៀត អំពីស្ថានភាពរបស់ អៀង សារី ទោះជាធ្វើឡើងតាមរយៈការថតជាខ្សែអាត់សំឡេង ការថតជាវីដេអូ ការសង្កេតរបស់ក្រុមមេធាវីការពារក្តី អៀង សារី ឬតាម

---

[52] *ដូចឯកសារយោងខាងលើ,* ទំព័រ ៣-៤។

[53] តារាងពេលវេលានៃការសង្កេតលើលទ្ធភាពរបស់លោក អៀង សារី ក្នុងការតាមដានកិច្ចដំណើរការនីតិវិធី និងចូលរួមក្នុងការការពារក្តីរបស់លោក ថ្ងៃទី ៦ ខែ ធ្នូ ឆ្នាំ ២០១២, ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១២, ឯកសារ E248.1.1 ។

[54] *ដូចឯកសារយោងខាងលើ,* ត្រង់ចំណុចនៃវេលាម៉ោង ១០:៣៦ នាទីព្រឹក-១០:៣៨ នាទីព្រឹក។

មធ្យោបាយផ្សេងពីនេះក្តី ត្រូវបានហាមឃាត់ រហូតដល់អនុញ្ញាតឲ្យមានការអនុវត្តបែបនេះត្រូវបានសម្រេចដោយអង្គជំនុំជម្រះសាលាដំបូងជាមុនសិន[55]។

21. កាលពីថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០១២ មេធាវីការពារក្តីបានឆ្លើយតបទៅនឹងសារអេឡិចត្រូនិករបស់មន្ត្រីច្បាប់នៃអង្គជំនុំជម្រះសាលាដំបូង ដោយបានស្នើសុំឲ្យមានសវនាការដោយផ្ទាល់មាត់មួយលើបញ្ហានេះ និងស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងផ្តល់សំអាងហេតុចំពោះសេចក្តីសម្រេចរបស់ខ្លួនដែលពុំអនុញ្ញាតឲ្យមានការថតខ្សែអាត់សំឡេង[56]។

22. កាលពីថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១២ ចៅក្រម Cartwright បានជូនដំណឹងទៅមេធាវីការពារក្តីថាសំណើរបស់ខ្លួនដែលស្នើសុំឲ្យមានសវនាការដោយផ្ទាល់មាត់ត្រូវបានបដិសេធ[57]។ លោក Karnavas បានស្នើសុំបន្តថតខ្សែអាត់សំឡេងរបស់ លោក អៀង សារី ថ្វីបើការពិភាក្សាសម្រេចត្រូវបានធ្វើពាក់ព័ន្ធនឹងថាតើការថតខ្សែអាត់សំឡេង អាចត្រូវបានអនុញ្ញាតដែរ ឬយ៉ាងណា ដោយបានពន្យល់ថា ការថតទាំងនេះនឹងពុំត្រូវបានធ្វើជាសាធារណៈ អាចត្រូវបានប្រគល់ជូនអង្គជំនុំជម្រះសាលាដំបូង នៅថ្ងៃនីមួយៗ និងអាចត្រូវបានលុបចោលក្នុងករណីចាំបាច់។ គាត់បានពន្យល់ថា ប្រសិនបើកំណត់ហេតុទាំងឡាយពុំត្រូវបានធ្វើនោះ នឹងពុំមានកំណត់ហេតុឡើយ[58]។ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធសំណើនេះ[59]។

## IV. បញ្ហាបឋម

### ក. ភាពអាចទទួលយកបាននៃបណ្តឹងសាទុក្ខ

---

[55] សារអេឡិចត្រូនិករបស់មន្ត្រីច្បាប់នៃអង្គជំនុំជម្រះសាលាដំបូង, "កម្មវត្ថុ៖ លិខិតរបស់មេធាវីការពារក្តី អៀង សារី តបទៅនឹងរបាយការណ៍របស់មន្ទីរឃុំឃាំង", ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១២។ សារអេឡិចត្រូនិកនេះត្រូវបានសរសេរឡើងវិញនៅក្នុងអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង។ *សូមមើល* ការបង្គាប់ឲ្យដាក់សារណា, ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២, ឯកសារ E254 ។

[56] សារអេឡិចត្រូនិករបស់មន្ត្រីច្បាប់នៃអង្គជំនុំជម្រះសាលាដំបូង, "កម្មវត្ថុ៖ លិខិតរបស់មេធាវីការពារក្តី អៀង សារី តបទៅនឹងរបាយការណ៍របស់មន្ទីរឃុំឃាំង", ថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០១២។

[57] ប្រតិចារិកក្នុងសំណៅព្រាង, ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១២ ទំព័រ ២។

[58] *ដូចឯកសារយោងខាងលើ*, ទំព័រ ៣-៤។

[59] *ដូចឯកសារយោងខាងលើ*, ទំព័រ ៥។

### ១. បណ្តឹងសាទុក្ខមានលក្ខណៈអាចឲ្យទទួលយកបាន ដោយអនុលោមតាមវិធាន ១០៤(៤)(ក)

23. វិធាន ១០៤(៤)(ក) អនុញ្ញាតឲ្យមានបណ្តឹងសាទុក្ខភ្លាមៗជំទាស់នឹង "សេចក្តីសម្រេចដែលមានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី"។ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា លោក អៀង សារី *ត្រូវតែ* ចូលរួមកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ និង*ពុំអាច* មានវត្តមាននៅក្នុងបន្ទប់សវនាការ មានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធីចំពោះលោក អៀង សារី ដោយហេតុថាលោក អៀង សារី ពុំអាចតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការបានឡើយ។ កំណត់ហេតុនៃសេចក្តីសង្កេតប្រចាំថ្ងៃដែលមន្ត្រីទទួលបន្ទុកសំណុំរឿងរបស់មេធាវីការពារក្តីបានរៀបចំសម្រាប់ថ្ងៃទី ៤-៦ ខែ ធ្នូ ឆ្នាំ ២០១២ បង្ហាញថាលោក អៀង សារី រមែងពុំមានសមត្ថភាពដើម្បីចូលរួមក្នុងកិច្ចដំណើរការនីតិវិធីដោយសារគាត់មានអាការៈឈឺចុកចាប់ ឬដោយសារគាត់ពុំអាចមើលឃើញអេក្រង់កុំព្យូទ័រ គាត់នឿយហត់អស់កម្លាំង ឬសម្រាន្តលក់ ឬដោយសារហេតុផលដទៃទៀត[60]។ តាមការពិត កិច្ចដំណើរការនីតិវិធីត្រូវបានបញ្ចប់ចំពោះលោក អៀង សារី ដោយហេតុថា សម្រាប់រូបគាត់ កិច្ចដំណើរការនីតិវិធីទាំងនេះក្លាយជាឥតន័យ។

---

[60] *សូមមើល* សំណើរបស់ អៀង សារី ស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងពិចារណាឡើងវិញចំពោះសេចក្តីសម្រេចរបស់ខ្លួន ដែលសម្រេចថា អៀង សារី មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ និងបដិសេធសំណើរបស់គាត់សុំតែងតាំងអ្នកជំនាញម្នាក់បន្ថែមទៀតដើម្បីជួយក្នុងការកំណត់អំពីសម្បទារបស់គាត់, ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១២, ឯកសារ E238/11។ តារាងពេលវេលានៃការសង្កេតលើបញ្ហាសុខភាពរបស់លោក អៀង សារី ក្នុងការតាមដានកិច្ចដំណើរការនីតិវិធី និងចូលរួមក្នុងការការពារក្តីរបស់លោក ថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០១២, ថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០១២, ឯកសារ E248/2.1។ តារាងពេលវេលានៃការសង្កេតលើបញ្ហាសុខភាពរបស់លោក អៀង សារី ក្នុងការតាមដានកិច្ចដំណើរការនីតិវិធី និងចូលរួមក្នុងការការពារក្តីរបស់លោក ថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០១២, ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១២, ឯកសារ E248.1។ តារាងពេលវេលានៃការសង្កេតលើបញ្ហាសុខភាពរបស់លោក អៀង សារី ក្នុងការតាមដានកិច្ចដំណើរការនីតិវិធី និងចូលរួមក្នុងការការពារក្តីរបស់លោក ថ្ងៃទី ៦ ខែ ធ្នូ ឆ្នាំ ២០១២, ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១២, ឯកសារ E248/1.1។ កាលពីពេលថ្មីៗ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឲ្យមេធាវីការពារក្តីបញ្ឈប់ការដាក់សេចក្តីសង្កេតទាំងនេះ។ *សូមមើល* ការបង្គាប់ឲ្យដាក់សារណា, ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២, ឯកសារ E254។

## ២. បណ្តឹងសាទុក្ខមានលក្ខណៈអាចឲ្យទទួលយកបាន ដោយអនុលោមតាមវិធាន ១០៤(៤)(ខ)

24. វិធាន ១០៤(៤)(ខ) អនុញ្ញាតឲ្យមានបណ្តឹងសាទុក្ខភ្លាមៗជំទាស់នឹង "សេចក្តីសម្រេចអំពីការឃុំខ្លួន និងការដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការដោយអនុលោមតាមវិធាន ៨២"។ សេចក្តីសម្រេចដែលថាលោក អៀង សារី ត្រូវតែបន្តស្ថិតនៅក្នុងមន្ទីរឃុំឃាំងគឺជាសេចក្តីសម្រេចអំពីការឃុំខ្លួន។ សេចក្តីសម្រេចនេះរិតត្បិតដោយពុំចាំបាច់នូវជម្រើសរបស់លោក អៀង សារី ថាតើគាត់ត្រូវចូលរួមក្នុងសវនាការរបស់គាត់ពីបន្ទប់សវនាការ ឬបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ដោយហេតុថា គាត់ត្រូវបានឃុំខ្លួន។ សេចក្តីសម្រេចដែលថាលោក អៀង សារី ពុំអាចត្រូវបានថតវីដេអូនៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការរបស់គាត់ គឺជាសេចក្តីសម្រេចអំពីការឃុំខ្លួន ដោយហេតុថា សេចក្តីសម្រេចនេះជាផ្នែកមួយនៃនីតិវិធីនៃការឃុំខ្លួនលោក អៀង សារី[61]។ ប្រសិនបើលោក អៀង សារី ពុំស្ថិតក្នុងការឃុំខ្លួន មេធាវីការពារក្តីនឹងមានសេរីភាពដើម្បីថតវីដេអូចំពោះគាត់ ដើម្បីធ្វើកំណត់ហេតុសម្រាប់បណ្តឹងសាទុក្ខ។ ក្នុងការពិចារណាអំពីបណ្តឹងឧទ្ធរណ៍ជំទាស់ការបដិសេធរបស់ ក.ស.ច.ស ទៅនឹងសំណើរបស់មេធាវីការពារក្តីដែលបានស្នើសុំថតវីដេអូនៃជំនួបជាមួយលោក អៀង សារី អង្គបុរេជំនុំជម្រះបានសម្រេចកាលពីពេលមុនថា "ទិដ្ឋភាពណាមួយនៃទម្រង់ឃុំខ្លួនបណ្តោះអាសន្ន ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យដ៏មានប្រសិទ្ធភាពរបស់អាជ្ញាធរមានសមត្ថកិច្ចខាងតុលាការរបស់ អ.វ.ត.ក និងមានកម្រិតជាក់លាក់ត្រឹមតែតម្រូវការនៃកិច្ចដំណើរការនីតិវិធីប៉ុណ្ណោះ"[62]។ ដោយអនុលោមតាមវិធាន ២១(២) ករណីដដែលនេះមានភាពត្រឹមត្រូវនៅក្នុងដំណាក់កាលជំនុំជម្រះ[63]។ អង្គបុរេជំនុំជម្រះបានទទួលយកបណ្តឹងឧទ្ធរណ៍

---

[61] *សូមមើល* សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចបដិសេធសំណើសុំអនុញ្ញាតថតសំឡេង/រូបភាពវីដេអូនៃការជួបជាមួយលោក អៀង សារី នៅក្នុងមន្ទីរឃុំឃាំង, ថ្ងៃទី ១១ ខែមិថុនា ឆ្នាំ ២០១០, ឯកសារ A371/2/12 , កថាខណ្ឌ ១១។

[62] *ដូចឯកសារយោងខាងលើ។*

[63] វិធាន ២១(២) ចែងថា៖ "វិធានការចាប់បង្ខំទាំងឡាយណាចំពោះបុគ្គលណាម្នាក់ ត្រូវធ្វើឡើងដោយ ឬស្ថិតនៅក្រោមការត្រួតពិនិត្យដោយយកចិត្តទុកដាក់ពីអាជ្ញាធរមានសមត្ថកិច្ចរបស់អង្គជំនុំជម្រះវិសាមញ្ញ។ វិធានការនេះត្រូវតែកម្រិតតឹងរ៉ឹងបំផុតសម្រាប់តែតម្រូវការនៃដំណើរការនីតិវិធី ...." (សេចក្តីបញ្ជាក់បន្ថែម)។

ជំទាស់នឹងសេចក្តីសម្រេចរបស់ ក.ស.ច.ស ដែលបានហាមឃាត់មេធាវីការពារក្តីមិនឱ្យថតអំពីជំនួបជាមួយលោក អៀង សារី ដោយអនុលោមតាមវិធាន ៧៤(៣)(ច) (វិធានសម្រាប់បណ្តឹងឧទ្ធរណ៍មុនការជំនុំជម្រះ) ក្នុងលក្ខណៈជាបណ្តឹងឧទ្ធរណ៍ "ដែលពាក់ព័ន្ធនឹងការឃុំខ្លួនបណ្តោះអាសន្ន"។ បណ្តឹងសាទុក្ខនាពេលបច្ចុប្បន្នគួរត្រូវបានទទួលយកស្រដៀងគ្នានេះ ដោយអនុលោមតាមវិធាន ១០៤(៤)(ខ)។

### ៣. បណ្តឹងសាទុក្ខមានលក្ខណៈអាចឱ្យទទួលយកបាន ដោយអនុលោមតាមវិធាន ១០៤(៤)(ឃ)

25. វិធាន ១០៤(៤)(ឃ) អនុញ្ញាតឱ្យមានបណ្តឹងសាទុក្ខភ្លាមៗជំទាស់នឹង "សេចក្តីសម្រេចស្តីពីការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ តាមវិធាន ៣៥(៦)"។ អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាឃើញថា "'គ្មានកំហុសអង្គច្បាប់ ឬអង្គហេតុ និងគ្មានការរំលោភនូវឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងណាមួយ ដែលអាចបង្កើតបានជាការជ្រៀតជ្រែកដោយដឹង និងមានចេតនាទៅលើកិច្ចការរដ្ឋបាលតុលាការ យោងយោងតាមអត្ថន័យនៃវិធាន ៣៥ នៃវិធានផ្ទៃក្នុងឡើយ'"[64]។ អង្គជំនុំជម្រះសាលាដំបូងពុំត្រឹមតែបានប្រព្រឹត្តកំហុស ឬរំលោភបំពានឆន្ទានុសិទ្ធិរបស់ខ្លួនឡើយ។ តាមរយៈសេចក្តីសម្រេចមួយចំនួនដែលមានទំនាក់ទំនងទៅវិញទៅមក (រួមទាំងសេចក្តីសម្រេចដែលត្រូវបានជំទាស់) អង្គជំនុំជម្រះសាលាដំបូងបានជ្រៀតជ្រែកដោយចេតនា និងពិតប្រាកដជាបន្តបន្ទាប់ចូលកិច្ចការរដ្ឋបាលតុលាការ តាមរយៈការរំលោភសិទ្ធិក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ លោក អៀង សារី ដើម្បីមានវត្តមានដោយផ្ទាល់នៅឯសវនាការរបស់គាត់ និងដើម្បីរៀបចំការការពារក្តីរបស់គាត់តាមរយៈការធ្វើកំណត់ហេតុ។

*ទីមួយ* អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថាលោក អៀង សារី ពុំមានសម្បទាគ្រប់គ្រាន់ដើម្បីចូលរួមសវនាការ ដោយពុំបានស្តាប់ឱ្យបានពេញលេញពីសំណាក់មេធាវីការពារក្តីលើបញ្ហានេះ។ លើសពីនេះ អង្គជំនុំជម្រះសាលាដំបូងបានផ្អែកសេចក្តីសម្រេចរបស់ខ្លួនលើយោបល់របស់វេជ្ជបណ្ឌិតមួយរូប ដែលពុំមានជំនាញដើម្បីធ្វើការវាយតម្លៃនេះ ហើយយោបល់

[64] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបង្គាប់ឱ្យជនជាប់ចោទមានវត្តមានក្នុងសាលសវនាការ, ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១២, ឯកសារ E130/4/3, ទំព័រ ១ (សេចក្តីបញ្ជាក់បន្ថែម)។

ផ្នែកវេជ្ជសាស្ត្ររបស់គាត់ខុសគ្នាទាំងស្រុង ពីយោបល់របស់គណៈកម្មការនៃវេជ្ជបណ្ឌិតព្យាបាលរបស់លោកអៀង សារី[65]។

*ទីពីរ* អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឲ្យលោក អៀង សារី ចូលរួមសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ និងបានបដិសេធអំពីសិទ្ធិរបស់គាត់ក្នុងការមានវត្តមាននៅក្នុងបន្ទប់សវនាការ។

*ទីបី* អង្គជំនុំជម្រះសាលាដំបូងបានហាមឃាត់ការថតវីដេអូចំពោះលោក អៀង សារី នៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការរបស់គាត់ ពីសំណាក់អង្គភាពសោតទស្សន៍ ឬក្រុមមេធាវីការពារក្ដីរបស់គាត់។

*ជាចុងក្រោយ* អង្គជំនុំជម្រះសាលាដំបូងបានហាមឃាត់មេធាវីការពារក្ដីមិនឲ្យថតខ្សែអាត់សំឡេងរបស់លោក អៀង សារី នៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ និងមិនឲ្យដាក់ការសង្កេតរបស់ខ្លួនអំពីស្ថានភាពរបស់លោក អៀង សារី[66] ទៅក្នុងសំណុំរឿង។

នេះគឺជាករណីទូទៅនៃភាពងងឹតងងុលដោយចេតនា។ អង្គជំនុំជម្រះសាលាដំបូងបានប៉ុនប៉ងតាម*រាល់*គ្រប់មធ្យោបាយដែលអាចធ្វើទៅបាន ដើម្បីបំបាំងខ្លួនពីព័ត៌មាន *ទាំងឡាយណា* ដែលបំបាត់ដោយតម្លាភាព និងដោយត្រឹមត្រូវនូវជំនឿដែលថាលោក អៀង សារី ពិតជាមានសមត្ថភាពគ្រប់ពេលវេលាដើម្បីចូលរួមពេញលេញ និងប្រកបដោយអត្ថន័យក្នុងកិច្ចដំណើរការនីតិវិធី ដែលខុសពីការចូលរួមដោយមិនទៀងទាត់ ឬពុំសូវញឹកញាប់។

### ៤. ការបកស្រាយវិធាន ១០៤(៤) ក្នុងន័យទូលាយ ត្រូវបានតម្រូវដោយវិធាន ២១ និងដើម្បីផលប្រយោជន៍នៃយុត្តិធម៌

---

65 *សូមមើល* សំណើរបស់ អៀង សារី ស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងពិចារណាឡើងវិញចំពោះសេចក្ដីសម្រេចរបស់ខ្លួនដែលសម្រេចថា អៀង សារី មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ និងបដិសេធសំណើរបស់គាត់សុំតែងតាំងអ្នកជំនាញម្នាក់បន្ថែមទៀតដើម្បីជួយក្នុងការកំណត់អំពីសម្បទារបស់គាត់, ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១២, ឯកសារ E238/11 ។

66 សារអេឡិចត្រូនិករបស់មន្ត្រីច្បាប់នៃអង្គជំនុំជម្រះសាលាដំបូង, "កម្មវត្ថុ៖ លិខិតរបស់មេធាវីការពារក្ដី អៀង សារី តបទៅនឹងរបាយការណ៍របស់មន្ទីរឃុំឃាំង", ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១២។

26. ការបកស្រាយក្នុងន័យទូលាយអំពីភាពអាចទទួលយកបាននៃបណ្តឹងសាទុក្ខ ដោយអនុលោមតាមវិធាន ១០៤(៤) គឺជាការចាំបាច់ដើម្បីការពារសិទ្ធិជាសារវ័ន្តក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដោយមានវត្តមានរបស់គាត់ និងដើម្បីរៀបចំការការពារក្តី តាមរយៈការធ្វើកំណត់ហេតុដែលជាក់ស្តែងរួមបញ្ចូលទាំងការរក្សាទុកកំហុសអង្គច្បាប់ កំហុសអង្គហេតុ ឬការរំលោភបំពានឆន្ទានុសិទ្ធិសម្រាប់ការពិនិត្យមើលឡើងវិញលើបណ្តឹងសាទុក្ខក្រោយសវនាការ ឬបណ្តឹងសាទុក្ខបន្ទាន់បន្ទំ។ ស្រដៀងគ្នានេះ កាលពីពេលថ្មីៗ ក.ស.ព បានលើកអំណះអំណាងជំទាស់នឹងការបកស្រាយវិធាន ១០៤(៤) ក្នុងន័យចង្អៀត ដោយបានពន្យល់ថា "ការបកស្រាយសមហេតុផលនូវវិធាន ១០៤ ត្រូវតែអនុញ្ញាតឲ្យមានសិទ្ធិក្នុងការពិនិត្យមើលឡើងវិញលើបណ្តឹងសាទុក្ខដោយប្រសិទ្ធភាព"[67]។

27. ប្រសិនបើបណ្តឹងសាទុក្ខនេះពុំត្រូវបានទទួលយកនៅដំណាក់កាលនេះ លោក អៀង សារី នឹងពុំមានសំណងសម្រាប់ការរំលោភសិទ្ធិរបស់គាត់ឡើយ។ សំណងតែមួយគត់នៅថ្ងៃខាងមុខគឺការផ្តល់ឲ្យលោក អៀង សារី នូវការជំនុំជម្រះថ្មីមួយ។ ដោយសារអាយុ និងសុខភាពខ្សត់ខ្សោយរបស់គាត់ និងថេរវេលានៃការជំនុំជម្រះនេះ ការជំនុំជម្រះជាថ្មីគឺពុំអាចធ្វើទៅបានឡើយ។

28. បើទោះបីជាលោក អៀង សារី បានរង់ចាំរហូតទម្រាំដល់ពេលមានសាលក្រមដើម្បីធ្វើបណ្តឹងសាទុក្ខជំទាស់នឹងរំលោភសិទ្ធិរបស់គាត់ក៏ដោយ ក៏លោក អៀង សារី នឹងពុំមានកំណត់ហេតុដើម្បីធ្វើជាមូលដ្ឋាននៃបណ្តឹងសាទុក្ខរបស់គាត់ឡើយ។ តាមរយៈការខិតខំប្រឹងប្រែងរួម និងដោយគិតទុកជាមុន អង្គជំនុំជម្រះសាលាដំបូងបានរារាំងនូវរាល់គ្រប់មធ្យោបាយដែលមេធាវីការពារក្តីមាន ដើម្បីកុំឲ្យមេធាវីការពារក្តីមានលទ្ធភាពធ្វើកំណត់ហេតុ និងបំពេញមុខងារប្រកបដោយការយកចិត្តទុកដាក់ត្រឹមត្រូវ។

[67] *សូមមើល* បណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹង "សេចក្តីសម្រេចស្តីពីវិសាលភាពនៃការជំនុំជម្រះក្តី នៅក្នុងសំណុំរឿងលេខ ០០២/០១ មានឧបសម្ព័ន្ធ (I) និងឧបសម្ព័ន្ធសម្ងាត់ (II), ថ្ងៃទី ៧ ខែ វិច្ឆិកា ឆ្នាំ ២០១២, ឯកសារ E163/5/1/1, កថាខណ្ឌ ១៤។

29. អង្គជំនុំជម្រះសាលាដំបូងបានដាក់មេធាវីការពារក្ដីឲ្យស្ថិតក្នុងស្ថានភាពខុសទំនង ដែលមេធាវីការពារក្ដីពុំអាចការពារខ្លួនបាន ៖

- អង្គជំនុំជម្រះសាលាដំបូងបានហាមឃាត់វត្តមានរបស់លោក អៀង សារី នៅក្នុងបន្ទប់សវនាការ ជាកន្លែងដែលសមត្ថភាពដើម្បីតាមដានសវនាការរបស់គាត់អាចត្រូវបានវាយតម្លៃ និងបានហាមឃាត់ការធ្វើកំណត់ហេតុក្នុងពេលដំណាលគ្នាជាមួយសវនាការ នៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។
- អង្គជំនុំជម្រះសាលាដំបូងបានគូសបញ្ជាក់ថា ខ្លួននឹង "ពឹងផ្អែកលើវេជ្ជបណ្ឌិតព្យាបាលរបស់លោក អៀង សារី ដើម្បីជូនដំណឹងមកខ្លួនអំពីការប្រែប្រួលដែលគួរឲ្យកត់សម្គាល់ណាមួយនៃស្ថានភាពផ្លូវកាយរបស់ អៀង សារី"[68]។
- វេជ្ជបណ្ឌិតនៅ អ.វ.ត.ក *បានត្រឹមតែ* តាមដានស្ថានភាពផ្លូវកាយរបស់លោក អៀង សារី និង បានគូសបញ្ជាក់ថា ពួកគាត់ពុំមានលទ្ធភាពដើម្បីវាយតម្លៃថា តើជនជាប់ចោទមានសមត្ថភាព ក្នុងការតាមដានកិច្ចដំណើរការនីតិវិធីដែរ ឬយ៉ាងណាឡើយ[69]។

អង្គជំនុំជម្រះសាលាដំបូងនឹង *ពុំដែល* ស្ថិតនៅក្នុងតួនាទីដើម្បីដឹងថាតើលោក អៀង សារី មានសមត្ថភាពតាមដានកិច្ចដំណើរការនីតិវិធីនៅថ្ងៃនីមួយៗដែរ ឬយ៉ាងណាឡើយ លើកលែងតែសុខភាពផ្លូវកាយរបស់គាត់ធ្លាក់ចុះធ្ងន់ធ្ងរ ដូចជាជំងឺដាច់សសៃឈាមខួរក្បាលជាដើម។ អង្គជំនុំជម្រះសាលាដំបូងកំពុងអនុវត្តដោយខ្លួនឯងដោយចេតនាដើម្បីជះឥទ្ធិពលដល់លទ្ធផលដែលខ្លួនចង់បាន នោះគឺការធានាឲ្យមានការបដិសេធដែលអាចធ្វើទៅបានអំពីសមត្ថភាពប្រចាំថ្ងៃរបស់លោក អៀង សារី ក្នុងការតាមដានសវនាការ។ តាមរយៈលក្ខខណ្ឌមិនសមហេតុផលដែលអង្គជំនុំជម្រះសាលាដំបូងបានកំណត់ អង្គជំនុំជម្រះសាលាដំបូងបានបិទបាំងខ្លួនឯងពីការជូនដំណឹងនានា ប៉ុន្តែលើកលែងតែអង្គជំនុំជម្រះបានទទួលការជូនដំណឹង ទើបខ្លួនចាត់វិធានការ។ សេណារីយ៉ូនេះត្រូវបានចាត់ទុកជារួមថាជាស្ថានភាពទាល់ច្រក

[68] ប្រតិចារឹក, ថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០១២, ទំព័រ ១៩។

[69] *សូមមើល* សេចក្ដីសង្កេតរបស់ក្រុមមេធាវីការពារក្ដីអំពីលោក អៀង សារី, ថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០១២, ត្រង់ចំណុចនៃវេលាម៉ោង ៨:៥៥ ព្រឹក-៩:១០ ព្រឹក, ឯកសារ E248.1។ សេចក្ដីសង្កេតរបស់ក្រុមមេធាវីការពារក្ដីអំពីលោក អៀង សារី, ថ្ងៃទី ៦ ខែ ធ្នូ ឆ្នាំ ២០១២, ត្រង់ចំណុចនៃវេលាម៉ោង ១០:៣៦ ព្រឹក-១០:៣៩ ព្រឹក, ឯកសារ E248.1.1។

"ដែលជាស្ថានភាពនៃបញ្ហាដែលដំណោះស្រាយតែមួយគត់ ត្រូវបានបដិសេធដោយកាលៈទេសៈដែលមានពីធម្មជាតិ នៅក្នុងបញ្ហានេះ ឬដោយវិធាន"[70]។ អង្គជំនុំជម្រះសាលាដំបូងបានធ្វើមិនដឹងមិនឮដោយចេតនា និងឥតអៀនខ្មាស់តាមរយៈការលេងល្បិចនេះ។ បណ្តឹងសាទុក្ខបន្ទាន់បង្ខំ នឹងអនុញ្ញាតឲ្យមានការត្រួតពិនិត្យអំពីការអនុវត្តបែបនេះ។

30. វិធាន ២១(១) តម្រូវឲ្យអង្គជំនុំជម្រះតុលាការកំពូល បកស្រាយច្បាប់ និងវិធានជាធរមានរបស់ អ.វ.ត.ក ដើម្បីការពារជាប់ជានិច្ចនូវផលប្រយោជន៍របស់លោក អៀង សារី[71]។ អង្គជំនុំជម្រះតុលាការកំពូលបានទទួលស្គាល់ចំណុចនេះ ដោយបានសម្រេចថាវិធាន ២១ "ត្រូវតែអានក្នុងន័យថា ការបកស្រាយវិធានផ្ទៃក្នុង មិនត្រូវឲ្យមានការរំលោភលើប្រយោជន៍ណាមួយរបស់ជនជាប់ចោទដែលកើតចេញពីសិទ្ធិសារវ័ន្ត ត្រូវបានធានានៅក្នុងលក្ខន្តិកៈ និងលិខិតុបករណ៍អន្តរជាតិជាធរមានមានដូចជា...សិទ្ធិទទួលបានការការពារខ្លួន"[72]។ ស្រដៀងនេះ អង្គបុរេជំនុំជម្រះបានទទួលស្គាល់ថាវិធាន ២១ តម្រូវឲ្យមានការបកស្រាយសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងន័យទូលាយ៖ "ក្រោយពីបានពិចារណាលើសិទ្ធិទទួលបានការជំនុំជម្រះ ដោយយុត្តិធម៌របស់ម្ចាស់បណ្តឹងឧទ្ធរណ៍... អង្គបុរេជំនុំជម្រះយល់ឃើញថា វិធាន ២១ តម្រូវឲ្យខ្លួនបកស្រាយវិធានផ្ទៃក្នុង តាមមធ្យោបាយដែលមានន័យ

---

[70] *សូមមើល* វចនានុក្រម MERRIAM-WEBSTER *នៅលើគេហទំព័រ* http://www.merriam-webster.com/dictionary/catch%2022។ ស្ថានភាពសមហេតុផលដែលគេស្គាល់ថាជាស្ថានភាពទាល់ច្រក ត្រូវបានបង្កើតឡើងដោយអ្នកនិពន្ធឈ្មោះ Joseph Heller នៅក្នុងសៀវភៅរបស់គាត់ក្នុងចំណងជើងដដែល។

[71] វិធាន ២១ (១) ចែងថា៖ "ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាលជាធរមានទាំងអស់ ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និងជនរងគ្រោះ ដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព ដោយគិតដល់លក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចមានចែងក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងកិច្ចព្រមព្រៀង"។

[72] សេចក្តីសម្រេចស្តីពីបណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំដោះលែងជាបន្ទាន់, ថ្ងៃទី ៣ ខែ មិថុនា ឆ្នាំ ២០១១, ឯកសារ E50/2/1/4, កថាខណ្ឌ ៣៩។

ថា បណ្ដឹងឧទ្ធរណ៍នេះក៏អាចទទួលយកបានតាមមូលដ្ឋាននៃវិធាន ២១ ផងដែរ"[73]។ ការកំហិតតឹងតែងចំពោះបណ្ដឹងឧទ្ធរណ៍បន្ទាន់បង្ខំ "ពុំស្របជាមួយយុត្តិសាស្ត្ររបស់ អ.វ.ត.ក ទម្លាប់អនុវត្តន៍របស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិទាំងអស់ និងតម្រូវការនៃការជំនុំជម្រះប្រកបដោយយុត្តិធម៌ និងឆាប់រហ័សរបស់ជនជាប់ចោទ"[74]។ ជាការពិត សិទ្ធិជាសារវ័ន្តរបស់លោក អៀង សារី ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដើម្បីមានវត្តមាននៅតុលាការ និងការរៀបចំការការពារក្ដី តាមរយៈការធ្វើកំណត់ហេតុ គឺពិតជាប្រភេទនៃបញ្ហាដែលនឹងបើកផ្លូវសម្រាប់បណ្ដឹងសាទុក្ខបន្ទាន់បង្ខំ នៅឯតុលាការឧក្រិដ្ឋកម្មអន្តរជាតិទាំងនោះ[75]។

31. ការបកស្រាយវិធាន ១០៤(៤) ក្នុងន័យចង្អៀត និងការសម្រេចថា បណ្ដឹងសាទុក្ខនេះពុំមានលក្ខណៈអាចឲ្យទទួលយកបាន នឹងរំលោភសិទ្ធិជាសារវ័ន្តក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌របស់លោក អៀង សារី ដែលត្រូវបានធានាដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រ

[73] សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចបដិសេធសំណើសុំអនុញ្ញាតថតសំឡេង/រូបភាពវីដេអូ នៃការជួបជាមួយលោក អៀង សារី នៅក្នុងមន្ទីរឃុំឃាំង, ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១០, ឯកសារ A371/2/12, កថាខណ្ឌ ១៨ (សេចក្ដីបញ្ជាក់បន្ថែម)។

[74] សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខរបស់ អៀង សារី ជំទាស់នឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើអញ្ញត្រកម្មរបស់ អៀង សារី ដោយអនុលោមតាមវិធាន ៨៩ (*គោលការណ៍ គ្មានការកាត់សេចក្ដី ២ ដងលើបទល្មើសតែមួយ* និង ការលើកលែងទោស និងការអនុគ្រោះទោស), យោបល់ជំទាស់របស់ចៅក្រម Klonowiecka-Milart និងចៅក្រម Jayasinghe, ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១២, ឯកសារ E51/15/1/2.1, កថាខណ្ឌ ១។ យោបល់នេះត្រូវបាន ក.ស.ព យល់ស្រប និងលើកយកមកសំអាងកាលពីពេលថ្មីៗ។ *សូមមើល* បណ្ដឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹង "សេចក្ដីសម្រេចស្ដីពីវិសាលភាពនៃការជំនុំជម្រះក្ដី នៅក្នុងសំណុំរឿង ០០២/០១ មានឧបសម្ព័ន្ធ (I) និងឧបសម្ព័ន្ធសម្ងាត់ (II), ថ្ងៃទី ៧ ខែ វិច្ឆិកា ឆ្នាំ ២០១២, ឯកសារ E163/5/1/1, n. 28។

[75] *សូមមើល ឧទាហរណ៍ សំណុំរឿង រដ្ឋអាជ្ញា ទល់នឹង Stanišić & Simatović*, លេខសំណុំរឿង IT-03-69-AR73.2, សាលដីកាលើបណ្ដឹងសាទុក្ខរបស់មេធាវីការពារក្ដីជំទាស់នឹងសេចក្ដីសម្រេចស្ដីពីកិច្ចដំណើរការនីតិវិធីនៅថ្ងៃខាងមុខ, ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០០៨ ("សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង *Stanišić*")។ សំណុំរឿង *រដ្ឋអាជ្ញា ទល់នឹង Karemera et al.*, លេខសំណុំរឿង ICTR-98-44-AR73.10, សាលដីកាលើបណ្ដឹងសាទុក្ខបន្ទាន់បង្ខំរបស់ Nzirorera ពាក់ព័ន្ធនឹងសិទ្ធិមានវត្តមានរបស់គាត់នៅសវនាការ, ថ្ងៃទី ៥ ខែ តុលា ឆ្នាំ ២០០៧។

កម្ពុជា[76] កិច្ចព្រមព្រៀង[77] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[78] និងលិខិតុបករណ៍គតិយុត្តអន្តរជាតិជាធរមាន[79]។ ប្រសិនបើមានវិមតិសង្ស័យអំពីភាពអាចទទួលយកបាននៃបណ្តឹងសាទុក្ខដោយអនុលោមតាមវិធាន ១០៤(៤) នេះ ការបកស្រាយត្រូវតែបានជាប្រយោជន៍ដល់លោក អៀង សារី[80]។ ក្រៅពីការធ្វើបណ្តឹងសាទុក្ខបន្ទាន់បន្ទំ លោក អៀង សារី ពុំមានមធ្យោបាយផ្សេងដើម្បីកែតម្រូវការរំលោភរបស់អង្គជំនុំជម្រះសាលាដំបូងលើសិទ្ធិនាពេលបច្ចុប្បន្នរបស់លោក អៀង សារី ក្នុងការទទួលបានការជំនុំជម្រះដោយមានវត្តមានរបស់គាត់ និងរៀបចំការការពារក្តី ក្រៅតែពីការធ្វើកំណត់ហេតុពេញលេញមួយ ដែលអនុញ្ញាតឲ្យមេធាវីការពារក្តីរក្សាទុកកំហុសនានាដើម្បីធ្វើបណ្តឹងសាទុក្ខ។

---

[76] មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាចែងថា៖ "ជនគ្រប់រូបមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ"។ មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាចែងថា៖ "ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ"។ សិទ្ធិដើម្បីរៀបចំការការពារក្តី គឺជាសិទ្ធិមនុស្សដែលត្រូវបានទទួលស្គាល់ដោយមាត្រា ១៤(៣)(ខ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ICCPR")។ សិទ្ធិមានវត្តមាននៅសវនាការគឺជាសិទ្ធិមនុស្សដែលត្រូវបានទទួលស្គាល់ដោយមាត្រា ១១ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងមាត្រា ១៤(៣)(ឃ) នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលកម្ពុជាជាភាគី។

[77] កិច្ចព្រមព្រៀង, មាត្រា ១៣(១)។

[78] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក, មាត្រា ៣៥ ថ្មី (ខ), (ឃ)។

[79] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, មាត្រា ១៤(៣)(ខ) និង(ឃ), សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស, មាត្រា ១១(១)។

[80] នេះជាការតម្រូវរបស់វិធាន ២១ និងស្របជាមួយគោលការណ៍ *វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ* ដែលជាគោលការណ៍ជាសារវ័ន្តនៃច្បាប់ព្រហ្មទណ្ឌដែលត្រូវបានទទួលស្គាល់ដោយមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ អ្វីដែលជាបញ្ហាដែលនៅក្នុងបណ្តឹងសាទុក្ខនេះគឺសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ជាសារវ័ន្តរបស់លោក អៀង សារី ដើម្បីមានវត្តមាននៅតុលាការ និងរៀបចំការការពារក្តី។ ការបកស្រាយវិធាន ១០៤(៤) ដែលនាំទៅដល់ការមិនទទួលយកបញ្ហាទាំងនេះ នឹងមានតម្លៃស្មើទៅនឹង "ការល្មើសនិយាម" ដែលម្យ៉ាងគឺជាការបកស្រាយវិធាន ១០៤(៤) ក្នុងន័យចង្អៀត (ដែលនឹងប៉ះពាល់សិទ្ធិជាសារវ័ន្តក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់លោក អៀង សារី) និងម្យ៉ាងទៀតគឺ កាតព្វកិច្ចរបស់អង្គជំនុំជម្រះតុលាការកំពូលដើម្បីធានាបានថាសិទ្ធិក្នុងការមានវត្តមានរបស់លោក អៀង សារី នៅតុលាការ និងការរៀបចំការការពារក្តីពុំត្រូវបានរំលោភ។ *សូមមើល* សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្តីពីសំណើសុំដោះលែងជាបន្ទាន់, ថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០១១, ឯកសារ E50/3/1/4, កថាខណ្ឌ ៣០-៣២។

### ខ. សំណើសុំឲ្យមានសវនាការផ្ទាល់មាត់ជាសាធារណៈ

32. បណ្តឹងសាទុក្ខនេះលើកឡើងអំពីការរំលោភសិទ្ធិជាសារវ័ន្ត ក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌របស់លោក អៀង សារី។ ការរំលោភនេះត្រូវតែលើកឡើងដោយចំហរ និងដោយតម្លាភាព។ វិធាន ១០៩(១) គូសបញ្ជាក់ថា សវនាការលើបណ្តឹងសាទុក្ខ ជាទូទៅគួរត្រូវបានធ្វើជាសាធារណៈ[81]។ បញ្ហាដ៏មានសារៈសំខាន់ទាំងនេះ *ត្រូវតែ* លើកយកមកពិភាក្សាប្រកបដោយតម្លាភាពដើម្បីធានាបាននូវប្រយោជន៍សម្រាប់សាធារណជន ពិសេសនៅពេលដែលបញ្ហាទាំងនេះទំនងជាប៉ះពាល់ដល់ធម្មនុញ្ញភាព និងភាពអាចជឿជាក់បាននៃ អ.វ.ត.ក។ ក្នុងចំណោមបញ្ហាទាំងនេះ ពុំមានបញ្ហាណាមួយជាបញ្ហាសម្ងាត់ឡើយ[82]។

## V. ច្បាប់ និងអង្គហេតុ

### ក. អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសអង្គច្បាប់ តាមរយៈការបកស្រាយវិធាន ៨១(៥) ក្នុងន័យដើម្បីបង្ខំឲ្យលោក អៀង សារី តាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ជាជាងការមានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការ

#### ១. លោក អៀង សារី មានសិទ្ធិក្នុងការវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការ

33. លោក អៀង សារី មានសិទ្ធិជាសារវ័ន្តក្នុងការមានវត្តមានដោយផ្ទាល់នៅសវនាការ។ សិទ្ធិនេះត្រូវបានធានាចំពោះគាត់ ដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា[83] កិច្ចព្រមព្រៀង[84] ច្បាប់ស្តីពី

---

[81] វិធាន ១០៩(១) ចែងថា៖ "សវនាការនៃអង្គជំនុំជម្រះតុលាការកំពូលត្រូវធ្វើឡើងជាសាធារណៈ។ អង្គជំនុំជម្រះតុលាការកំពូលអាចធ្វើសេចក្តីសម្រេចពិចារណាលើបណ្តឹងសាទុក្ខភ្លាមៗ ដោយផ្អែកតែលើមូលដ្ឋាននៃសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរដែលដាក់ដោយភាគីតែប៉ុណ្ណោះ"។

[82] លិខិតយល់ព្រមរបស់ អៀង សារី ចំពោះការពិភាក្សាជាសាធារណៈអំពីបញ្ហាសុខភាពរបស់គាត់, ថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ២០១២, ឯកសារ E1/142.2។

[83] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, មាត្រា ៣១។

[84] មាត្រា ១៣(១) នៃកិច្ចព្រមព្រៀងចែងថា៖ "សិទ្ធិរបស់ជនជាប់ចោទ ដែលមានចែងនៅក្នុងមាត្រា ១៤ និង ១៥ នៃអនុសញ្ញាអន្តរជាតិឆ្នាំ ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ត្រូវតែបានគោរពនៅទូទាំងដំណើរការនៃការជំនុំជម្រះក្តី"។

ការបង្កើត អ.វ.ត.ក[85] វិធានផ្ទៃក្នុង[86] និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ[87]។ សិទ្ធិនេះពុំត្រូវបានបន្ធូរបន្ថយ ឡើយដោយហេតុថា គាត់ជាមនុស្សចាស់ និងមានសុខភាពទន់ខ្សោយ។ សិទ្ធិស្មើភាពគ្នាចំពោះមុខច្បាប់ មានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា[88] លិខិតុបករណ៍អន្តរជាតិ[89] និងថ្នាក់តំបន់មួយចំនួន[90] និងនៅក្នុងរដ្ឋធម្មនុញ្ញនៃរដ្ឋជាច្រើន[91]។ គណៈកម្មាធិការសិទ្ធិមនុស្ស ដែលជាស្ថាប័ននៃអ្នកជំនាញឯករាជ្យ ដែលតាមដានការអនុវត្តកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិ នយោបាយរបស់រដ្ឋភាគី (ដូចជា កម្ពុជា ជាដើម)[92]

---

[85] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក, មាត្រា ៣៥ ថ្មី (ឃ)។

[86] វិធាន ៨១(១)។

[87] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, មាត្រា ១៤(៣)(ឃ)។

[88] មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាចែងថា៖ "ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ ...."។

[89] មាត្រា ៧ នៃសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្សចែងថា "មនុស្សទាំងអស់មានភាពស្មើៗគ្នានៅចំពោះមុខច្បាប់ ហើយមានសិទ្ធិទទួលបាននូវកិច្ចការពារដោយច្បាប់ដោយស្មើៗគ្នាដោយគ្មានការរើសអើងណាមួយឡើយ។ មនុស្សគ្រប់រូបមានសិទ្ធិទទួលបាននូវកិច្ចការពារខ្លួនស្មើៗគ្នាប្រឆាំងទល់នឹងការរើសអើងណាមួយ ដែលជាការរំលោភនូវសេចក្តីប្រកាសនេះ និងប្រឆាំងទល់នឹងការញុះញង់ណាមួយដែលនាំទៅមានការរើសអើង"។ មាត្រា ១៤(១) នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយចែងថា "ជនគ្រប់រូបត្រូវមានភាពស្មើគ្នាចំពោះមុខតុលាការ និងសាលាជម្រះក្តី"។ មាត្រា ២៦ នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយចែងថា "ជនគ្រប់រូបមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ និងមានសិទ្ធិការពារពីច្បាប់ស្មើគ្នាដោយឥតរើសអើង"។

[90] *សូមមើល* ពិធីសារលេខ ១២ នៃអនុសញ្ញាអឺរ៉ុបសម្រាប់ការការពារសិទ្ធិមនុស្ស និងសេរីភាពជាសារវ័ន្ត, អនុសញ្ញាអន្តរអាមេរិកស្តីពីសិទ្ធិមនុស្ស, មាត្រា ២៤។

[91] *សូមមើល ឧទាហរណ៍* រដ្ឋធម្មនុញ្ញសហរដ្ឋអាមេរិក, វិសោធនកម្មលើកទី១៤, រដ្ឋធម្មនុញ្ញបារាំង ដែលត្រូវបានអនុម័តក្នុងឆ្នាំ ១៩៥៨, មាត្រា ១, សេចក្តីប្រកាសស្តីពីសិទ្ធិមនុស្ស និងសិទ្ធិពលរដ្ឋ ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៧៨៩, មាត្រា ៦, រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋសហព័ន្ធអូទ្រីស, មាត្រា ៧, New Zealand Bill of Rights Act (ច្បាប់សិទ្ធិមនុស្សនៃប្រទេសនូវែលសេឡង់) ឆ្នាំ ១៩៩០, ផ្នែក ២, កថាខណ្ឌ ២៧, រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប៉ូឡូញ, ថ្ងៃទី ២ ខែ មេសា ឆ្នាំ ១៩៩៧, មាត្រា ៣២, រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋសង្គមនិយមប្រជាធិបតេយ្យស្រីលង្កា, មាត្រា ១២, សេចក្តីព្រាងរដ្ឋធម្មនុញ្ញលើកទីមួយនៃសាធារណរដ្ឋហ្សាំប៊ី, ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១២, មាត្រា ៤៥។

[92] *សូមមើល* ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស, គណៈកម្មាធិការសិទ្ធិមនុស្ស, *នៅលើគេហទំព័រ* http://www2.ohchr.org/english/bodies/hrc/។ កម្ពុជាបានចុះហត្ថលេខាលើកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយកាលពីថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ១៩៨០ និងបានឯកភាពកាលពីថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ១៩៩២។ *សូមមើល* សមូហកម្មនៃសន្ធិសញ្ញាអង្គការសហប្រជាជាតិ, នៅលើគេហទំព័រ http://treaties.un.org/Pages/ViewDetails.aspx?src=TREATY&mtdsg_no=IV-4&chapter=4&lang=en#3 ។

បានគូសបញ្ជាក់ថា លក្ខខណ្ឌតម្រូវនៃការជំនុំជម្រះប្រកបដោយយុត្តិធម៌ ដូចមានចែងក្នុងមាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ "ពុំត្រូវបានគោរព នៅពេលដែល ... ជនជាប់ចោទត្រូវបានបដិសេធនូវឱកាសដើម្បី *ចូលរួមដោយផ្ទាល់* នៅក្នុងកិច្ចដំណើរការនីតិវិធី ឬនៅពេលដែលជនជាប់ចោទពុំមានសមត្ថភាព ដើម្បីពិគ្រោះឲ្យបានត្រឹមត្រូវជាមួយតំណាងផ្លូវច្បាប់របស់ខ្លួន"[93]។

34. វត្តមានរបស់លោក អៀង សារី ក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ពុំមានតម្លៃស្មើនឹងវត្តមានរបស់គាត់ដោយផ្ទាល់នៅ សវនាការឡើយ។ នៅឯតុលាការ ICTY និងតុលាការ ICTR ដែលមានលក្ខន្តិកៈស្រដៀងគ្នា/ការធានាសិទ្ធិមនុស្សនូវសិទ្ធិក្នុងការមានវត្តមាននៅសវនាការ សិទ្ធិក្នុងការមានវត្តមាននេះត្រូវបានបកស្រាយថាជាសិទ្ធិក្នុងការមានវត្តមាន*ដោយផ្ទាល់*នៅសវនាការ។

35. នៅឯតុលាការ ICTY, អង្គជំនុំជម្រះតុលាការឧទ្ធរណ៍ក្នុងសំណុំរឿង *Stanišić & Simatović* បានគូសបញ្ជាក់ថា "សិទ្ធិក្នុងការមានវត្តមានគឺជាសិទ្ធិជាសារវ័ន្ត" ហើយ "ការបដិសេធសិទ្ធិនេះពុំសមស្របឡើយ នៅពេលដែលមានជម្រើសសមហេតុផល"[94] ។ នៅឯតុលាការ ICTR អង្គជំនុំជម្រះតុលាការឧទ្ធរណ៍ក្នុងសំណុំរឿង *Zigiranyirazo ទល់នឹងរដ្ឋអាជ្ញា* អង្គជំនុំជម្រះតុលាការឧទ្ធរណ៍បានពិចារណាថាតើការយកសក្ខីកម្មរបស់សាក្សីរបស់អង្គជំនុំជម្រះសាលាដំបូង នៅប្រទេសហូឡង់ នៅខណៈពេលដែលជនជាប់ចោទ Zigiranyirazo ត្រូវបានភ្ជាប់តាមប្រព័ន្ធសោតទស្សន៍ពី Arusha បានរំលោភសិទ្ធិរបស់គាត់ក្នុងការមានវត្តមាននៅសវនាការដែរ ឬយ៉ាងណា[95]។ ដោយកត់

---

[93] ទស្សនៈរបស់គណៈកម្មាធិការសិទ្ធិមនុស្សដោយអនុលោមតាមមាត្រា ៥, កថាខណ្ឌ ៤, នៃពិធីសារបន្ថែមនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, ឯកសារលេខ 289/1988: ប៉ាណាម៉ា, ថ្ងៃទី ៨ ខែ មេសា ឆ្នាំ ១៩៩២, CCPR/C/44/289/1988 (យុត្តិសាស្ត្រ), កថាខណ្ឌ ៦៦ (សេចក្តីបញ្ជាក់បន្ថែម)។

[94] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការឧទ្ធរណ៍ក្នុងសំណុំរឿង *Stanišić*, កថាខណ្ឌ ១៩។

[95] Zigiranyirazo បានអះអាងថានីតិវិធីនេះបានរំលោភសិទ្ធិមានវត្តមានរបស់គាត់នៅសវនាការ ដែលអាចត្រូវបានបំពេញតាមរយៈការចូលរួមដោយផ្ទាល់ប៉ុណ្ណោះ, សំណុំរឿង *Zigiranyirazo ទល់នឹង រដ្ឋអាជ្ញា*, លេខសំណុំរឿង ICTR-2001-73-AR73, សាលដីកាលើបណ្តឹងសាទុក្ខបន្ទាន់បង្គំ, ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០០៦, កថាខណ្ឌ ២។ គាត់បានពន្យល់ថា "ឧបសគ្គពីធម្មជាតិក្នុងការតាមដានភស្តុតាង និងការធ្វើទំនាក់ទំនងដោយជាក់ស្តែងជាមួយចៅក្រម" ធ្វើឲ្យគាត់ពុំអាចអនុវត្តបានពេញលេញនូវសិទ្ធិក្នុងការមានវត្តមានដោយផ្ទាល់របស់គាត់។ *ដូចឯកសារយោងខាងលើ* កថាខណ្ឌ ១៦។ Zigiranyirazo បានកត់សម្គាល់ឃើញ

សម្គាល់ឃើញថា *"វត្តមានដោយផ្ទាល់របស់ជនជាប់ចោទនៅចំពោះមុខតុលាការ ក្នុងលក្ខណៈជាវិធានទូទៅមួយ គឺជាគោលការណ៍មួយ ក្នុងចំណោមគោលការណ៍រួមជាមូលដ្ឋានបំផុតនៃការជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌប្រកបដោយយុត្តិធម៌"*[96]។ អង្គជំនុំជម្រះតុលាការឧទ្ធរណ៍បានសម្រេចថា "ការចូលរួមតាមរយៈប្រព័ន្ធសោតទស្សន៍ពុំត្រូវបានចាត់ទុកថាជាវត្តមានឡើយ"[97]។

**២. វិធាន ៨១(៥) បានត្រឹមតែអនុញ្ញាតឲ្យមានការរិតត្បិតសិទ្ធិក្នុងការមានវត្តមានដោយផ្ទាល់ នៅក្នុងកាលៈទេសៈមួយចំនួនតូច ដែលពុំត្រូវបានបំពេញ**

36. វិធាន ៨១(៥) ទទួលស្គាល់អំពីសិទ្ធិជាសារវ័ន្តរបស់ជនជាប់ចោទ ក្នុងការមានវត្តមានដោយផ្ទាល់នៅក្នុងកិច្ចដំណើរការនីតិវិធី និងក្នុងការអនុវត្តតាមគោលការណ៍នៃភាពសមាមាត្រ[98] ដាក់កំហិតយ៉ាងតឹងតែងអំពីស្ថានភាពដែលសិទ្ធិនេះអាចត្រូវបានរិតត្បិត។ វិធាន ៨១(៥) ចែងថា អង្គជំនុំជម្រះសាលាដំបូងអាចបានត្រឹមតែបង្គាប់ឲ្យមានការចូលរួម តាមរយៈប្រព័ន្ធសោតទស្សន៍ក្នុងកាលៈទេសៈជាក់លាក់មួយចំនួនតូចប៉ុណ្ណោះ។ វិធាន ៨១(៥) ចែងត្រង់ផ្នែកពាក់ព័ន្ធថា៖

---

ថាការប្រើប្រាស់ប្រព័ន្ធសោតទស្សន៍មានន័យថាទាំងគាត់ និងមេធាវីនាំមុខរបស់គាត់ ដែលស្ថិតនៅ Arusha ដែរ ពុំអាចសង្កេត ឬស្តាប់ចៅក្រម ឬសាក្សីបានឡើយ លើកលែងតែម៉ាស៊ីនថតត្រូវបានតម្រង់ទៅរកពួកគាត់។ ជាលទ្ធផល ប្រព័ន្ធសោតទស្សន៍ "បានរារាំងពួកគេពីការធ្វើទំនាក់ទំនងដោយផ្ទាល់ជាធម្មតាជាមួយកិច្ចដំណើរការនីតិវិធី" *ដូចឯកសារយោងខាងលើ*។ អង្គជំនុំជម្រះតុលាការឧទ្ធរណ៍បានសម្រេចដោយគាំទ្រ Zigiranyirazo បន្ទាប់ពីខ្លួនបានសម្រេចក្នុងចំណោមការសម្រេចផ្សេងៗថាគ្មានវិធាននីតិវិធីណាមួយក្នុងចំណោមវិធាននីតិវិធីទាំងឡាយសម្រាប់តុលាការ ICTR, ICTY, តុលាការឧក្រិដ្ឋកម្មអន្តរជាតិ ឬតុលាការពិសេសសម្រាប់សៀរ៉ាឡេអូន ដើម្បីប្រៀបប្រដូចការមានវត្តមានដោយផ្ទាល់ ជាមួយនឹងការចូលរួមតាមរយៈប្រព័ន្ធសោតទស្សន៍ឡើយ, *ដូចឯកសារយោងខាងលើ,* កថាខណ្ឌ ១២។

[96] *ដូចឯកសារយោងខាងលើ,* កថាខណ្ឌ ១១ (សេចក្តីបញ្ជាក់បន្ថែម)។

[97] *ដូចឯកសារយោងខាងលើ,* កថាខណ្ឌ ១២។ អង្គជំនុំជម្រះតុលាការឧទ្ធរណ៍បានកត់សម្គាល់ថាសិទ្ធិនេះពុំមែនជាសិទ្ធិដាច់ខាតឡើយ ដែលចំណុចនេះពុំមានការតវ៉ាពីភាគីក្នុងសំណុំរឿងនោះឡើយ។ *ដូចឯកសារយោងខាងលើ* កថាខណ្ឌ ១៥។

[98] *ដូចឯកសារយោងខាងលើ,* កថាខណ្ឌ ១៤។ អនុលោមតាមគោលការណ៍សមាមាត្រ "ការរិតត្បិតណាមួយលើសិទ្ធិជាសារវ័ន្តត្រូវតែបម្រើដល់គោលដៅសំខាន់គ្រប់គ្រាន់ និងមិនត្រូវប៉ះពាល់សិទ្ធិឲ្យហួសពីភាពចាំបាច់ដើម្បីសម្រេចគោលដៅនេះឡើយ"។ *សូមមើល សំណុំរឿង រដ្ឋអាជ្ញា ទល់នឹង Milošević*, លេខសំណុំរឿង IT-02-54-AR73.7, សេចក្តីសម្រេចលើបណ្តឹងសាទុក្ខបន្ទាន់បង្ខំជំទាស់នឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើការតែងតាំងមេធាវីការពារក្តី, ថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២០០៤, កថាខណ្ឌ ១៧។ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការឧទ្ធរណ៍ក្នុងសំណុំរឿង *Stanišić*, កថាខណ្ឌ ១៦។

> នៅពេលដែលមានមូលហេតុសុខភាព ឬមូលដ្ឋានធ្ងន់ធ្ងរដទៃទៀត ជនជាប់ចោទ *មិនអាចចូលរួមដោយផ្ទាល់* ចំពោះមុខអង្គជំនុំជម្រះ ប៉ុន្តែរូបកាយ និងស្មារតីសមស្របអាចចូលរួមក្នុងដំណើរការនីតិវិធីបាន អង្គជំនុំជម្រះអាចបន្តនីតិវិធី ដោយមិនមានវត្តមានរបស់ជនជាប់ចោទ ដោយមានការយល់ព្រមពីជនជាប់ចោទ ឬ *នៅពេលដែលអវត្តមានរបស់ជនជាប់ចោទឈានដល់កម្រិតមួយ ដែលបណ្តាលឲ្យមានការពន្យារពេលយ៉ាងយូរ ហើយនៅពេលដែលផលប្រយោជន៍នៃយុត្តិធម៌តម្រូវ* អង្គជំនុំជម្រះបង្គាប់ថាការចូលរួមរបស់ជនជាប់ចោទនៅចំពោះមុខអង្គជំនុំជម្រះ ត្រូវតែធ្វើឡើងតាមមធ្យោបាយសោតទស្សន៍សមស្រប[99]។

ហេតុដូច្នេះ វិធាន ៨១(៥) មានលក្ខខណ្ឌតម្រូវចំនួន ៣ ដែលត្រូវតែបំពេញ នៅមុនការចូលរួមតាមរយៈមធ្យោបាយសោតទស្សន៍ អាចត្រូវបានបង្គាប់ចំពោះបុគ្គលដែលមានសម្បទាផ្លូវកាយ និងផ្នែកស្មារតីគ្រប់គ្រាន់ដើម្បីចូលរួមកិច្ចដំណើរការនីតិវិធី៖ **ក.** ជនជាប់ចោទ *មិនអាច* ចូលរួមដោយផ្ទាល់ **ខ.** ត្រូវតែមានការពន្យារពេលយ៉ាងយូរ *និង* **គ.** ការបង្គាប់ឲ្យមានការចូលរួមតាមមធ្យោបាយសោតទស្សន៍ត្រូវតែដើម្បីផលប្រយោជន៍នៃយុត្តិធម៌។

### ក. លោក អៀង សារី អាចមានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការ

37. អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ ដោយសារពុំបានរកឲ្យឃើញថាតើលោក អៀង សារី *អាច*ចូលរួម សវនាការបានដោយផ្ទាល់ដែរ ឬយ៉ាងណា។ វិធាន ៨១(៥) នៃវិធានផ្ទៃក្នុងតម្រូវឲ្យអង្គជំនុំជម្រះសាលាដំបូងពិចារណាជាបឋមថាតើលោក អៀង សារី *អាច*ចូលរួមសវនាការដោយផ្ទាល់ដែរ ឬយ៉ាងណា។ ក្នុងករណីដែលជនជាប់ចោទ*មិនអាច*ចូលរួមដោយផ្ទាល់ដោយមូលហេតុសុខភាព ឬ មូលហេតុធ្ងន់ធ្ងរដទៃទៀត ទើបវាចាំបាច់តម្រូវឲ្យពិចារណាលើបញ្ហាពន្យារពេលយូរ ឬ បញ្ហាផលប្រយោជន៍នៃយុត្តិធម៌។ លោក អៀង សារី *អាច*ចូលរួមក្នុងកិច្ចដំណើរការនីតិវិធីដោយផ្ទាល់បាន។ ដូច្នេះ បញ្ហានោះពាក់ព័ន្ធនឹងការនាំខ្លួនលោកមកក្នុងបន្ទប់

---

[99] សេចក្តីបញ្ជាក់បន្ថែម។

សវនាការខាងលើតែប៉ុណ្ណោះ។ ករណីនេះគឺខុសដាច់ស្រឡះពីករណី *Zigiranyirazo* ដែលពាក់ព័ន្ធនឹងការដឹកជញ្ជូនជនជាប់ចោទពីប្រទេសតង់ហ្សានីមកកាន់ប្រទេសហូឡង់ដ៏។

## ខ. គ្មានការពន្យារពេលយ៉ាងយូរ

38. អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ ដោយលើកឡើងមិនត្រឹមត្រូវចំពោះវាក្យខណ្ឌទីពីរនៅក្នុងវិធាន៨១(៥) នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះសាលាដំបូងគ្រាន់តែត្រឹមបានសន្និដ្ឋាន (ស្មានៗ) ថា "ការលំបាកដែលនឹងអនុញ្ញាតឲ្យគាត់ចូលមកបាននោះគឺថា*អាចនឹងធ្វើ*ឲ្យសវនាការនេះមានការពន្យារពេលយ៉ាងវែង។ ហេតុដូច្នេះ អង្គជំនុំជម្រះបង្គាប់ឲ្យលោក អៀង សារី តាមដានដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ"[100]។

39. វិធាន ៨១(៥) នៃវិធានផ្ទៃក្នុងចែងថា "អវត្តមានរបស់ជនជាប់ចោទឈានដល់កម្រិតមួយដែលបណ្តាលឲ្យមានការពន្យារពេលយ៉ាងយូរ"[101] ពោលគឺ មានន័យថា វាទាល់តែអវត្តមានពីតុលាការដែលបណ្តាលឲ្យមានការពន្យារពេលយ៉ាងយូរ។ ការបកស្រាយដោយមានកំហុសលើវិធាន ៨១(៥) នៃវិធានផ្ទៃក្នុង វាបានបណ្តាលឲ្យមានការរិតត្បិតសិទ្ធិមានវត្តមាននៅក្នុងពេលជំនុំជម្រះរបស់លោក អៀង សារី បើទោះជាវត្តមានរបស់លោកពុំបានបណ្តាលឲ្យមានការពន្យារពេលយ៉ាងយូរផងនោះ។ អង្គជំនុំជម្រះមានកំហុសនៅពេលខកខានក្នុងការរកឲ្យឃើញថាវាពិតជាមានការពន្យារពេលយ៉ាងយូរមែន ដោយសារលោក អៀង សារ មានសុខភាពមិនល្អ ដែលតម្រូវឲ្យបង្គាប់ឲ្យលោកចូលរួមពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។

40. អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ នៅពេលខ្លួនខកខានក្នុងការរកឲ្យឃើញថាតើលោក អៀង សារី អាច ឬ ពុំអាចមានវត្តមាននៅក្នុងបន្ទប់សវនាការ។ អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ថែមទៀត នៅពេលខ្លួនលើកឡើងដោយមិនត្រឹមត្រូវនៃវិធាន ៨១(៥) នៃវិធានផ្ទៃក្នុង ដោយអនុញ្ញាតឲ្យចូលរួមពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនការក្នុងករណីដែល

[100] ប្រតិចារឹក ថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០១២ ឯកសារលេខ E1/147.1 ទំព័រ ១៨។

[101] គូសបញ្ជាក់បន្ថែម។

បញ្ហាអវត្តមានរបស់ជនជាប់ចោទ*អាចបណ្តាល*ឲ្យមានការពន្យារពេលយ៉ាងយូរនោះ។ កំហុសទាំងនេះបានរំលោភលើសិទ្ធិមានវត្តមានដោយផ្ទាល់ក្នុងពេលជំនុំជម្រះលោក អៀង សារី។

**គ. អង្គជំនុំជម្រះមិនគួរពិចារណាលើផលប្រយោជន៍នៃយុត្តិធម៌ឡើយ**

41. លក្ខខណ្ឌនៃវិធាន ៨១(៥) នៃវិធានផ្ទៃក្នុងគឺជាលក្ខខណ្ឌភ្ជាប់គ្នា ពុំមែនជាលក្ខខណ្ឌដាច់ចេញពីគ្នានោះទេ។ ប្រសិនបើលក្ខខណ្ឌពីរដំបូងមិនបានបំពេញទេនោះ អង្គជំនុំជម្រះសាលាដំបូងមិនអាចពិចារណាលើលក្ខខណ្ឌទីបីបានឡើយ មិនថាការពិចារណានោះគឺដើម្បីផលប្រយោជន៍នៃយុត្តិធម៌សម្រាប់ជនជាប់ចោទក្នុងការចូលរួមពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនការនោះទេ។ នៅត្រង់នេះ អង្គជំនុំជម្រះសាលាដំបូងពុំបានរកឃើញអ្វីទាំងអស់ថាតើលោក អៀង សារី អាចមានវត្តមាននៅក្នុងបន្ទប់សវនាការ ឬក៏មិនអាច។ អង្គជំនុំជម្រះសាលាដំបូងពុំបានរកឃើញទៀតថា ការពន្យារពេលយ៉ាងយូរនៅក្នុងកិច្ចដំណើរការនីតិវិធីពិតជាបានកើតឡើងដែរ ឬក៏មិនបាន។ អង្គជំនុំជម្រះសាលាដំបូងមានកំហុសនៅពេលពិចារណាលើបញ្ហាផលប្រយោជន៍នៃយុត្តិធម៌ ក្នុងពេលដែលលក្ខខណ្ឌពីរដំបូងនៃវិធាន ៨១(៥) នៃវិធានផ្ទៃក្នុងពុំទាន់បានបំពេញផងនោះ។ ខ្លួនក៏មានកំហុសផងដែរនាពេលក្រោយមក នៅពេលដែលខ្លួនបដិសេធសំណើរបស់លោក អៀង សារី ស្នើសុំមានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការ ដោយបែរជាបង្គាប់ឲ្យនាំរូបលោកទៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការទៅវិញ។

**ខ. អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គហេតុ និងបានបំពានធន្មានុសិទ្ធិរបស់ខ្លួនដោយបានអនុវត្តវិធាន ៨១(៥) នៃវិធានផ្ទៃក្នុងដើម្បីចាប់បង្ខំលោក អៀង សារី ឲ្យតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ជាជាងឲ្យលោកមានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការ**

42. សេចក្តីសម្រេចដែលត្រូវបានជំទាស់ពុំបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឲ្យលោក អៀង សារី ចូលរួមពីបន្ទប់ឃុំខ្លួនខាងក្រោមដើម្បីផលប្រយោជន៍នៃយុត្តិធម៌នោះទេ។ ទោះបីជាយ៉ាងនេះក្តី នៅក្នុងសេចក្តីសម្រេចជាលាយលក្ខណ៍ដែលត្រូវបានធ្វើឡើងនៅមុនពេលចេញសេចក្តីសម្រេចដែលត្រូវបានជំទាស់នេះ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ការបង្គាប់ឲ្យ

លោក អៀង សារី ចូលរួមពីបន្ទប់ឃុំខ្លួនខាងក្រោមនឹងអាចផ្តល់ជាប្រយោជន៍នៃយុត្តិធម៌[102] ដោយបានលើកឡើងថាវាគឺដើម្បី៖ (១) ផលប្រយោជន៍ផ្នែកវេជ្ជសាស្ត្រចំពោះលោក អៀង សារី និង/ឬ ដើម្បីពន្លឿនការប្រព្រឹត្តទៅនៃកិច្ចដំណើរការនីតិវិធី[103]។

## ១. ផលប្រយោជន៍ផ្នែកវេជ្ជសាស្ត្រសម្រាប់លោក អៀង សារី ពុំចាំបាច់តម្រូវឲ្យលោកនៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនោះទេ

43. ផលប្រយោជន៍ផ្នែកវេជ្ជសាស្ត្រសម្រាប់លោក អៀង សារី គឺជាការព្រួយបារម្ភតាមផ្លូវច្បាប់របស់អង្គជំនុំជម្រះសាលាដំបូង ពីព្រោះថាផលប្រយោជន៍មួយនេះមានអានុភាពលើសម្បទារបស់លោកក្នុងការចូលរួមសវនាការ។ ទោះបីជាយ៉ាងនេះក្តី ផលប្រយោជន៍មួយនេះពុំមែនជាការព្រួយបារម្ភតាមផ្លូវច្បាប់របស់អង្គជំនុំជម្រះសាលាដំបូងនោះទេដែលថា ការនាំលោក អៀង សារី ចូលមកក្នុងបន្ទប់សវនាការអាច ឬ មិនអាចធ្វើឲ្យលោកមានអារម្មណ៍លំបាក។ អង្គជំនុំជម្រះសាលាដំបូងបានបង្ហាញនូវការព្រួយបារម្ភតិចតួចប៉ុណ្ណោះ នៅពេលដែលខ្លួនតម្រូវឲ្យលោក អៀង សារី អង្គុយលើកៅអីនៅក្នុងបន្ទប់សវនាការនៅក្នុងពេលជាក់លាក់មួយចំនួន (ឧទាហរណ៍ ក្នុងអំឡុងពេលការិយាល័យសហព្រះរាជអាជ្ញាធ្វើសេចក្តីសន្និដ្ឋានបើកការចោទប្រកាន់។ ដូចដែលយើងបានដឹងជ្រួតជ្រាបច្បាស់ហើយ សេចក្តីសន្និដ្ឋាននេះពុំមែនជាភស្តុតាង ហើយក៏ពុំមានតម្លៃជាភស្តុតាងផងដែរ) សូម្បីនៅក្រោយពេលលោក អៀង សារី បានបង្ហាញថា លោកមានការលំបាក និងបានស្នើសុំត្រឡប់ទៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការវិញក៏ដោយ[104]។ យើងអាចនិយាយបានគ្រប់គ្រាន់ថា ការព្រួយបារម្ភរបស់អង្គជំនុំជម្រះសាលាដំបូងចំពោះ "ភាពស្រណុកសុខស្រួល" របស់លោក អៀង សារី មិនអាចមានអនុភាពខ្លាំងជាងការបង្ហាញបំណង និងចេតនារបស់លោកនៅក្នុងការស្នើសុំតាមដានកិច្ចដំណើរការនីតិវិធីដោយផ្ទាល់នៅក្នុងបន្ទប់សវនាការ ដោយមិនចង់តាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។

---

[102] សេចក្តីសម្រេចស្តីពីសម្បទាជនជាប់ចោទ អៀង សារី ក្នុងការចូលរួមសវនាការ ចុះថ្ងៃថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ ឯកសារលេខ E238/9 កថាខណ្ឌ ៣៧។

[103] *ដូចខាងលើ*។

[104] *សូមមើល ឧ.* ប្រតិចារឹក ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារលេខ E1/13.1 ទំព័រ ៣៦-៣៧។ ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារលេខ E1/14.1 ទំព័រ ៣៦-៣៧។

44. នៅក្នុងសេចក្តីសម្រេចជាលាយលក្ខណ៍អក្សររបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងបានផ្អែកលើមតិយោបល់របស់លោកសាស្ត្រាចារ្យ Campbell ដែលបានលើកឡើងថា "ជនជាប់ចោទអាចផ្តោតអារម្មណ៍បានយ៉ាងល្អ នៅពេលដែលគាត់តម្រេតខ្លួនចុះ ដោយពិចារណាអំពីភាពទន់ខ្សោយកាន់តែដុនដាប តម្រូវការផ្នែកវេជ្ជសាស្ត្ររបស់ជនជាប់ចោទត្រូវបានផ្តល់ឲ្យស្មើរតែបានសមស្របទៅហើយនៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ"[105]។ ករណីដែលថា លោកសាស្ត្រាចារ្យ Campbell មិនបានបញ្ចូលអនុសាសន៍អំពីការតម្លើងគ្រែពេទ្យនៅក្នុងបន្ទប់សវនាការនៅក្នុងបញ្ជីអនុសាសន៍របស់លោកពុំមែនមានន័យថា និងពុំគួរត្រូវបានបកស្រាយថា (ដូចអង្គជំនុំជម្រះសាលាដំបូងបានធ្វើឡើង) ថា វិធានការបែបនេះមានលក្ខណៈងាយស្រួលតិចតួច ឬ សមស្របតិចបំផុតសម្រាប់លោក អៀង សារី នោះទេ[106]។

45. ទោះបីជាមានការពន្យារពេលតិចតួចអាចកើតឡើងនៅពេលនាំលោក អៀង សារី ចូលក្នុងបន្ទប់សវនាការក៏ដោយ វាពុំមានផលប៉ះពាល់ណាមួយបន្ថែមនោះទេ។ វត្តមានរបស់លោក អៀង សារី នៅក្នុងបន្ទប់សវនាការនឹងផ្តល់ឱកាសពេញលេញ និងយុត្តិធម៌ឲ្យអង្គជំនុំជម្រះសាលាដំបូង ភាគី និងសាធារណជនសង្កេតជាក់ស្តែងលើស្ថានភាពរបស់លោក អៀង សារី។ ក្រុមមេធាវីការពារក្តីសូមសន្និដ្ឋានថា សុខុមាលភាព*ជាក់ស្តែង*របស់លោក អៀង សារី អាចមានសារសំខាន់សម្រាប់ឲ្យអង្គជំនុំជម្រះសាលាដំបូងកំណត់ថាតើលោក អៀង សារី មានលទ្ធភាព*ពិតប្រាកដ*ក្នុងការចូលរួមនៅក្នុងការការពារក្តីរបស់លោក ដូចបានចែងនៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជា និងលិខិតុបករណ៍ច្បាប់ផ្សេងទៀតដែល អ.វ.ត.ក ត្រូវគោរពតាម។

46. នៅក្នុងរបាយការណ៍របស់លោក លោក សាស្ត្រាចារ្យ Campbell បានសង្កេតឃើញថា ការប្រើប្រាស់បន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនឹង "មានភាពងាយស្រួលសម្រាប់" លោក អៀង

---

[105] សេចក្តីសម្រេចស្តីពីសម្បទាជនជាប់ចោទ អៀង សារី ក្នុងការចូលរួមសវនាការ ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ ឯកសារលេខ E238/9 កថាខណ្ឌ ៣៦។

[106] *ដូចខាងលើ*។

សារី[107]។ លោកសាស្ត្រាចារ្យពុំបានលើកឡើងថា វាពុំជាផលប្រយោជន៍ផ្នែកវេជ្ជសាស្ត្រល្អប្រសើរបំផុតសម្រាប់លោក អៀង សារី ក្នុងការចូលរួមក្នុងបន្ទប់សវនាការនោះទេ។ នៅពេលលោកសាស្ត្រាចារ្យ Campbell ត្រូវបានសាកសួរថាតើវាមានលក្ខណៈសមស្របជាងនេះដែរ ឬយ៉ាងណា ប្រសិនបើឲ្យលោក អៀង សារី ចូលរួមនៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោម លោកសាស្ត្រាចារ្យបានឆ្លើយថា៖ "លោក អៀង សារី នឹងពុំមានភាពងាយស្រួលនោះទេ ប្រសិនបើឲ្យលោកអង្គុយ ហើយនៅពេលលោកទម្រេតខ្លួន លោកមានភាពងាយស្រួលជាង។ បន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការត្រូវបានរៀបចំបង្កើតឡើងបានល្អ ហើយខ្ញុំយល់ថា បន្ទប់នេះមានលក្ខណៈសមរម្យបំផុតសម្រាប់គាត់"[108]។ លោកសាស្ត្រាចារ្យ Campbell ពុំដែលធ្លាប់បានគេស្នើសុំឲ្យពិចារណាលើលទ្ធភាពក្នុងការយកគ្រែពេទ្យមកតម្លើងដាក់នៅក្នុងបន្ទប់សវនាការនោះទេ។

47. តម្រូវការផ្នែកវេជ្ជសាស្ត្រទាំងអស់សម្រាប់លោក អៀង សារី ដែលត្រូវបានផ្តល់ឲ្យនៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការអាចត្រូវបានផ្តល់ជូននៅក្នុងបន្ទប់សវនាការផងដែរ។ គ្រែពេទ្យអាចផ្តល់ជូនបានដោយងាយនៅក្នុងបន្ទប់សវនាការ។ អង្គជំនុំជម្រះអាចបង្គាប់ឲ្យវេជ្ជបណ្ឌិតមកអង្គុយនៅក្នុងបន្ទប់សវនាការនៅក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធី។ ការផ្គត់ផ្គង់ផ្នែកវេជ្ជសាស្ត្រដូចជា ខ្យល់អុកស៊ីហ្សែនក៏អាចធ្វើទៅបាននៅក្នុងបន្ទប់សវនាការ។

48. គ្មានសញ្ញាបញ្ជាក់ណាមួយដែលបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងបានពិចារណាថាតើអនុសាសន៍ទាំងឡាយអាច ឬ ពុំអាចធ្វើឡើងបានដែរ ឬយ៉ាងណា ដើម្បីអនុញ្ញាតឲ្យលោក អៀង សារី មានលទ្ធភាពអនុវត្តសិទ្ធិមូលដ្ឋានរបស់លោកក្នុងការចូលរួមនៅក្នុងបន្ទប់សវនាការ នៅមុនពេលបង្គាប់ឲ្យលោកចូលរួមតាមរយៈបន្ទប់ឃុំខ្លួនខាងក្រោម។ បន្ទប់សវនាការគឺជាកន្លែង*ប្រសើរ*ជាងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ សម្រាប់ការសម្រួលដល់តម្រូវការផ្នែកវេជ្ជសាស្ត្រជូនលោក អៀង សារី។ នៅក្នុងបន្ទប់សវនាការ អង្គជំនុំជម្រះ ក្រុមមេធាវីការពារក្តី និងវេជ្ជបណ្ឌិត

---

[107] របាយការណ៍អ្នកជំនាញស្តីអំពីលោក អៀង សារី ដែលត្រូវបានរៀបចំឡើងដើម្បីឆ្លើយតបទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារលេខ E238 ) ចុះថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ ឯកសារលេខ E238/4 កថាខណ្ឌ ២១។

[108] ប្រតិចារឹក ថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ២០១២ ឯកសារលេខ E1/142.1 ទំព័រ ២៦។

អាចតាមដានលើស្ថានភាពរបស់លោក អៀង សារី បានជាដរាប[109]។ នៅក្នុងបន្ទប់សវនាការ លោក អៀង សារី អាចនៅតែមានលទ្ធភាពមើលកិច្ចដំណើរការនីតិវិធីដដែល ប្រសិនបើលោកប្រែខ្លួន (ក្រោយពេលលោកឈប់មានអាការៈពីជំងឺវិលមុខ)។ នៅក្នុងបន្ទបស់សវនាការ សហមេធាវីការពារក្ដីអាចធ្វើកំណត់ហេតុភ្លាមៗអំពីស្ថានភាពរបស់លោក អៀង សារី និង ប្រសិនបើចាំបាច់សហមេធាវីអាចប្រតិកម្មបានទាន់ពេលវេលា។

49. អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់នៅពេលរកឃើញថា ស្ថានភាពសុខភាពរបស់លោក អៀង សារី តម្រូវឱ្យលោកចូលរួមពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។ កំហុសនេះបានធ្វើឱ្យប៉ះពាល់ដល់ដំណើរការស្វែងរកយុត្តិធម៌។ អង្គជំនុំជម្រះសាលាដំបូងបានរំលោភឆន្ទានុសិទ្ធិរបស់ខ្លួន ដោយសារខ្លួនបានផ្ដល់ទម្ងន់លើការពិចារណាត្រង់ចំណុចមិនពាក់ព័ន្ធ និងមិនចាំបាច់មួយចំនួន តែបែរជាខកខានក្នុងការផ្ដល់ទម្ងន់លើការពិចារណាត្រង់ចំណុចពាក់ព័ន្ធនានាទៅវិញ ដូចជា តើតម្រូវការផ្នែកវេជ្ជសាស្ត្ររបស់លោក អៀង សារី អាចផ្ដល់ជូនពីបន្ទប់សវនាការដែរ ឬយ៉ាងណា[110]។

### ២. ដំណើរការកិច្ចនីតិវិធីឱ្យបានឆាប់រហ័សពុំចាំបាច់ត្រូវការលោក អៀង សារី

---

[109] នៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោម វេជ្ជបណ្ឌិតគ្រាន់តែតាមដានលោក អៀង សារី មួយភ្លែតៗ និងពុំសូវញឹកញាប់នោះទេ។ ប្រសិនបើលោក អៀង សារី ចង់ទាក់ទងជាមួយនឹងមេធាវី លោកអាចទាក់ទងបានដោយផ្ទាល់ ប្រសិនបើគាត់នៅក្នុងបន្ទប់សវនាការ។ ទោះបីជានៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមមានទូរស័ព្ទសម្រាប់ទាក់ទងក៏ដោយ លោក អៀង សារី មិនអាចប្រើប្រាស់បានទេពីព្រោះដៃរបស់លោកទាំងពីរពុំមានកម្លាំងរឹងមាំនោះទេ ហើយម្រាមដៃ និងប្រអប់ដៃរបស់លោកស្ពឹក។ *សូមមើល ឧ.* ប្រតិចារឹក ថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ២០១២ ឯកសារលេខ E1/142.1 ទំព័រ ៧៥ “[សាស្ត្រាចារ្យ Campbell៖] ដូចខ្ញុំបានបញ្ជាក់នៅក្នុងរបាយការណ៍របស់ខ្ញុំ គាត់បានរអ៊ូអំពីបញ្ហាស្ពឹកស្រពន់ចាប់ពីខាងលើកដៃឡើងទៅ ស្ពឹកប្រអប់ដៃ ស្ពឹកស្មងជើងផ្នែកខាងក្រោមចុះទៅដល់ប្រអប់ជើង”។

[110] *សូមមើល* សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ឯកសារលេខ D164/3/6 កថាខណ្ឌ ២៥ *ដកស្រង់* រឿងក្ដី *Milošević ទល់នឹងរដ្ឋអាជ្ញា* IT-02-54-AR73.7 សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍បន្ទាន់បង្កំប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពីការចាត់តាំងក្រុមមេធាវីការពារក្ដី ចុះថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ដែលបានពន្យល់ថាការផ្ដល់ទម្ងន់លើចំណុចដែលមិនពាក់ព័ន្ធ និងមិនមានប្រយោជន៍ ឬ ការខកខានមិនបានផ្ដល់ទម្ងន់លើចំណុចដែលពាក់ព័ន្ធគឺជាការរំលោភបំពានលើឆន្ទានុសិទ្ធិ។

**ឲ្យនៅអង្គុយនៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមនោះទេ**

50. អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការផ្ដល់*ហេតុផល*នៅក្នុងសេចក្ដីសន្និដ្ឋានរបស់ខ្លួនថា វានឹងធ្វើឲ្យកិច្ចដំណើរការនីតិវិធីប្រព្រឹត្តទៅបានលឿនជាងមុន ប្រសិនបើទុកលោក អៀង សារី ឲ្យចូលរួមនៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ជាជាងឲ្យលោកមានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការ។ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចរួចហើយថា អង្គជំនុំជម្រះត្រូវផ្ដល់សំអាងហេតុឲ្យបានត្រឹមត្រូវ[111]។

51. លោក អៀង សារី បានស្នើសុំចូលរួមពីបន្ទប់សវនាការ។ នៅក្នុងដំណាក់កាលនេះ ពុំមានបញ្ហាបាត់បង់ពេលវេលាសម្រាប់ការជំនុំជម្រះនោះទេ។ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ជារៀងរាល់ថ្ងៃ វានឹងចំណាយពេលបន្ថែមលើសនេះបន្តិចនៅពេលនាំខ្លួនលោក អៀង សារី ចូលក្នុងបន្ទប់សវនាការ បើធៀបទៅនឹងការនាំខ្លួនលោកទៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ អង្គជំនុំជម្រះអាចបង្គាប់ឲ្យនាំខ្លួនលោក អៀង សារី ចូលក្នុងបន្ទប់សវនាការឲ្យបានមុនជាងនេះបន្តិច។ បន្ថែមលើចំណុចនេះ ទោះបីជាពុំបានលើកឡើងក៏ដោយ អង្គជំនុំជម្រះសាលាដំបូងមានការព្រួយបារម្ភថា វាអាចមានការពន្យារពេលការជំនុំជម្រះប្រសិនបើលោក អៀង សារី ត្រូវប្រើប្រាស់បន្ទប់ទឹកក្នុងពេលជំនុំជម្រះ ឬ អាចត្រូវការប្រែខ្លួនទម្រេតលើគ្រែ ដែលវាអាចធ្វើឲ្យរួបលោកវិលមុខ និងមិនអាចតាមដានកិច្ចដំណើរការនីតិវិធីមួយរយៈពេលខ្លី[112]។ សំអាងហេតុនេះពុំសមស្របក្នុងការបង្គាប់ឲ្យលោក អៀង សារី ចូលរួមនៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនោះឡើយ។

---

[111] សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំឲ្យចាត់វិធានការបន្ទាន់តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ចុះថ្ងៃថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១២ ឯកសាលេខ E176/2/1/4 កថាខណ្ឌ ២៤-៣០។

[112] របាយការណ៍អ្នកជំនាញស្ដីអំពីលោក អៀង សារី ដែលត្រូវបានរៀបចំឡើងដើម្បីឆ្លើយតបទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារលេខ E238 ) ចុះថ្ងៃថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ ឯកសាលេខ E238/4៖ "លោក អៀង សារី មានអាការៈវិលមុខនៅពេលធ្វើចលនាក្បាល និងផងខ្លួន ដូចជា ប្រែខ្លួនឡើងចុះលើគ្រែ ដើបអង្គុយ និងក្រោកឈរ។ ពេលខ្លះ ការធ្វើចលនានេះធ្វើឲ្យគាត់វិលមុខ ឬ ធីងធោង និងក្អួត ហើយពេលខ្លះទៀត គាត់មានអាការៈឈឺក្បាលតិចៗ។ គាត់និយាយថា វាបានធ្វើឲ្យគាត់ហត់ផងដែរ"។

52. នៅក្នុងសេចក្តីសម្រេចដែលត្រូវបានជំទាស់ អង្គជំនុំជម្រះសាលាដំបូងពុំបានរកឃើញថា វត្តមានរបស់លោក អៀង សារី នៅក្នុងបន្ទប់សវនាការបានបណ្តាលឲ្យមានការពន្យារពេលយ៉ាងយូរនោះទេ។ នៅក្នុងសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរមុនៗ អង្គជំនុំជម្រះសាលាដំបូង "កត់សម្គាល់" ថា "សុខភាពមិនល្អរបស់លោក អៀង សារី បានបណ្តាលឲ្យមានថ្ងៃសវនាការចំនួន ១២ ថ្ងៃ ត្រូវផ្អាកដោយផ្នែក ឬ ទាំងស្រុង"[113] ប៉ុន្តែ អង្គជំនុំជម្រះសាលាដំបូងពុំបានរកឃើញថាតើករណីនេះបានបណ្តាលឲ្យមានការពន្យារពេលយ៉ាងយូរដែរ ឬក៏យ៉ាងណានោះឡើយ។ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងបានពិចារណាឃើញថា ការខាតបង់រយៈពេល ១២ ថ្ងៃនៃថ្ងៃជំនុំជម្រះគឺធ្វើឲ្យមានការពន្យារពេលយ៉ាងយូរនោះ អង្គជំនុំជម្រះនឹងមានកំហុសអង្គហេតុ។ បើធៀបទៅនឹងរយៈពេលប្រហែលជា ១៥០ ថ្ងៃ នៃថ្ងៃជំនុំជម្រះ ដែលនឹងត្រូវចំណាយពេលប្រហែលជាជាងមួយឆ្នាំនោះ រយៈពេល ១២ ថ្ងៃ គឺជាចំនួនតិចតួចមួយប៉ុណ្ណោះ។ សេចក្តីសម្រេចក្នុងពេលថ្មីៗរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការកាត់បន្ថយថ្ងៃធ្វើសវនាការមកត្រឹម ៣ ថ្ងៃក្នុងមួយសប្តាហ៍នៅក្នុងសប្តាហ៍ បន្ទាប់នឹងធ្វើឲ្យខាតបង់ពេលវេលាកាន់តែច្រើនជាងនេះ ហើយសូម្បីហេតុផលសមស្របក៏ពុំបានពន្យល់ប្រាប់ថាតើការអូសបន្លាយកិច្ចដំណើរការនីតិវិធីបែបនេះ នឹងផ្តល់តម្លៃដល់ផលប្រយោជន៍នៃយុត្តិធម៌ដោយរបៀបណាដែរ[114]។

53. នៅសាលាក្តី ICTY ដែលបានដោះស្រាយលើករណីទាំងឡាយដែលត្រូវការរយៈពេលយូរ និងដែលមានភាពស្មុគស្មាញស្រដៀងគ្នានឹងសំណុំរឿង ០០២/០១ ការពន្យារពេលពី ៣ ទៅ ៦ ខែ ដោយសារជំងឺរបស់ជនជាប់ចោទពុំបានបណ្តាលឲ្យមានការពន្យារពេលយ៉ាងយូរនោះទេ។ នៅក្នុងរឿងក្តី *Stanišić* និង *Simatović* អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃសាលាក្តី ICTY បានពិចារណាថាតើការបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូងឲ្យជនជាប់ចោទ *Stanišić* ចូលរួមក្នុងការជំនុំជម្រះរបស់គេតាមរយៈមធ្យោបាយវីដេអូបានរំលោភលើគោលការណ៍សមមាត្រាដែរ ឬយ៉ាងណា។

---

[113] សេចក្តីសម្រេចស្តីពីសម្បទាជនជាប់ចោទ អៀង សារី ក្នុងការចូលរួមសវនាការ ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ ឯកសារលេខ E238/9 កថាខណ្ឌ ៣៥។

[114] *សូមមើល*ប្រតិចារឹក ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១២ ឯកសារលេខ E1/137.1 ទំព័រ ៤៩-៥០។ អនុស្សារណៈរបស់អង្គជំនុំជម្រះសាលាដំបូង "កាលបរិច្ឆេទដែលអង្គជំនុំជម្រះមិនធ្វើសវនាការក្នុងឆ្នាំ ២០១៣" ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១២ ឯកសារលេខ E253។

សុខភាពឈឺដុនដាបរបស់ *Stanišić* បានពន្យារពេលការចាប់ផ្តើមការជំនុំជម្រះពី ៣ ទៅ ៦ សប្តាហ៍ ហើយវេជ្ជបណ្ឌិតមួយរូបបានផ្តល់អនុសាសន៍ថា កិច្ចដំណើរការនីតិវិធីគួរពន្យារពេលពី ៣ ទៅ ៦ ខែបន្ថែមទៀត។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានរកឃើញថា អង្គជំនុំជម្រះសាលាដំបូងពុំបានផ្តល់ទម្ងន់ឲ្យបានគ្រប់គ្រាន់លើសិទ្ធិមានវត្តមានរបស់ជនជាប់ចោទ *Stanišić* ហើយបានផ្តល់ទម្ងន់ដោយមិនត្រឹមត្រូវលើគោលបំណងនៃការចាប់ផ្តើមកិច្ចដំណើរការនីតិវិធីទៅវិញ។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ "ពុំបានរកឃើញថា ការពន្យារពេលនៅក្នុងកាលៈទេសៈនៃរឿងក្តីនេះបានឈានដល់កម្រិតមួយដែលបណ្តាលឲ្យមានការអូសបន្លាយពេលយ៉ាងយូរ ដូច្នេះតម្រូវឲ្យដកហូតសិទ្ធិមូលដ្ឋានរបស់ជនជាប់ចោទក្នុងការមានវត្តមាននៅក្នុងពេលជំនុំជម្រះនោះទេ"[115]។

54. ប្រសិនបើលោក អៀង សារី មិនមានលទ្ធភាពចូលរួម មិនថានៅក្នុងបន្ទប់សវនាការ *ឬ* នៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនការទេនោះ កិច្ចដំណើរការនីតិវិធីត្រូវបញ្ឈប់រហូតទាល់តែលោកមានលទ្ធភាពចូលរួមឡើងវិញ។ ការបន្តកិច្ចដំណើរការនីតិវិធីក្នុងពេលលោក អៀង សារី ពុំមានលទ្ធភាពចូលរួមនោះនឹងជាការរំលោភលើសិទ្ធិទទួលការជំនុំជម្រះ ដោយយុត្តិធម៌របស់លោក។ ប្រសិនបើគ្រាន់តែធ្វើពើថាលោកកំពុងតាមដានកិច្ចដំណើរការនីតិវិធី នៅក្នុងខណៈពេលដែលយើងពុំអាចមើលឃើញរូបលោកដោយផ្ទាល់ផងនោះ ហើយពុំអនុញ្ញាតឲ្យបានធ្វើកំណត់ហេតុថាលោកបាន ឬ មិនបានតាមដានកិច្ចដំណើរការ ការធ្វើពើដូច្នេះនឹងគឺគ្រាន់តែជាការលេងល្ខិនខ្នែកមួយតែប៉ុណ្ណោះ។

55. អង្គជំនុំជម្រះសាលាដំបូងមានកំហុងអង្គហេតុ នៅពេលខ្លួនរកឃើញដោយប្រយោលថា វានឹងធ្វើឲ្យកិច្ចដំណើរការនីតិវិធីដំណើរការបានឆាប់រហ័សជាងនេះប្រសិនបើលោក អៀង សារី បានចូលរួមនៅក្នុងការជំនុំជម្រះពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ជាជាងពីបន្ទប់សវនាការ។

---

[115] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍លើរឿងក្តី *Stanišić* កថាខណ្ឌ ១៨។ *សូមមើលផងដែរ រដ្ឋអាជ្ញា ទល់នឹង Karemera និងជនផ្សេងទៀត* ICTR-98-44-AR73.10 សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្គំរបស់ Nzirorera ពាក់ព័ន្ធនឹងសិទ្ធិមានវត្តមាននៅក្នុងពេលជំនុំជម្រះ ចុះថ្ងៃទី ៥ ខែ តុលា ឆ្នាំ ២០០៧ កថាខណ្ឌ ១៥ ដែលនៅក្នុងនោះ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃសាលាក្តី ICTR បានរកឃើញថា អង្គជំនុំជម្រះសាលាដំបូងពុំបានអនុវត្តគោលការណ៍សមមាត្រឲ្យបានត្រឹមត្រូវ ហើយបានរំលោភសិទ្ធិមានវត្តមានរបស់ជនជាប់ចោទនៅក្នុងពេលជំនុំជម្រះដោយសារបានកំណត់កាលបរិច្ឆេទឲ្យសាក្សីមួយរូបមកផ្តល់សក្ខីកម្ម ខណៈពេលដែលជនជាប់ចោទមានជំងឺ និងមិនអាចចូលរួមសវនាការរយៈពេល ៣ ថ្ងៃ។

កំហុសនេះបានបន្តធ្វើឱ្យប៉ះពាល់នៅក្នុងដំណើរការស្វែងរកយុត្តិធម៌។ លើសពីនេះ អង្គជំនុំជម្រះសាលាដំបូងបានបំពានឆន្ទានុសិទ្ធិរបស់ខ្លួន ដោយសារខ្លួនបានផ្តល់ទម្ងន់លើការពិចារណាត្រង់ចំណុចមិនពាក់ព័ន្ធ និងមិនចាំបាច់មួយចំនួន តែបែរជាខកខានក្នុងការផ្តល់ទម្ងន់លើការពិចារណាត្រង់ចំណុចពាក់ព័ន្ធនានាទៅវិញ ដូចជា តើវត្តមានក្នុងបន្ទប់សវនាការរបស់លោក អៀង សារី ពិតជានឹងអាចប៉ះពាល់ដល់ដំណើរការដ៏ឆាប់រហ័សនៃកិច្ចដំណើរការនីតិវិធីដែរដែរ ឬយ៉ាងណា។

**គ. អង្គជំនុំជម្រះសាលាដំបូងមានកំហុស ដោយសារបានបំពានឆន្ទានុសិទ្ធិរបស់ខ្លួនធ្វើការហាមឃាត់ក្រុមមេធាវីការពារក្តីធ្វើកំណត់ហេតុលើស្ថានភាពរបស់លោក អៀង សារី តាមមធ្យោបាយថតវីដេអូក្នុងខណៈពេលដែលលោកស្ថិតនៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោម**

56. លោក អៀង សារី មានសិទ្ធិជាមូលដ្ឋានទទួលបានការត្រៀមរៀបចំការការពារខ្លួន។ សិទ្ធិនេះត្រូវបានធានាដល់រូបលោកនៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជា[116] កិច្ចព្រមព្រៀង[117] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[118] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ[119] និងសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស[120]។ សិទ្ធិនេះក៏ត្រូវបានចែងបញ្ចូលនៅក្នុងអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានផងដែរ[121]។ ចំណុចស្នូលនៃការរៀបចំការការពារក្តីគឺត្រូវធ្វើឡើងតាមរយៈការធ្វើកំណត់ហេតុ ពោលគឺ ប្រសិនបើគ្មានកំណត់ហេតុ ក្រុមមេធាវីការពារក្តីនឹងពុំមានអ្វីទាំងអស់សម្រាប់យកមកធ្វើជាមូលដ្ឋាននៅពេលធ្វើបណ្តឹងឧទ្ធរណ៍ ឬ បណ្តឹងសាទុក្ខ[122]។

---

[116] រដ្ឋធម្មនុញ្ញកម្ពុជា មាត្រា ៣៨។

[117] កិច្ចព្រមព្រៀង មាត្រា ១៣(១)។

[118] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ៣៥ ថ្មី (ខ)។

[119] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ១៤(៣)(ខ)។

[120] សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស មាត្រា ១១(១)។

[121] មាត្រា ៦(៣)(ខ) នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានចែងថា៖ “ជនទាំងឡាយដែលត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌណាមួយនោះត្រូវមានសិទ្ធិអប្បបរមា ដូចតទៅនេះ៖...(ខ) មានពេលវេលា និងសម្ភារៈមធ្យោបាយគ្រប់គ្រាន់សម្រាប់ការការពារក្តីរបស់ខ្លួន...”។

[122] នៅក្នុងការពិភាក្សាអំពីគោលការណ៍ទូទៅស្តីពីការណែនាំ និងការអនុវត្តវិធានការកាត់បន្ថយបន្ថយសិទ្ធិ និងស្ថានភាពបន្ទាន់សម្រាប់សាធារណជននៅក្នុងកតិកាសញ្ញា ICCPR គណៈកម្មាការសិទ្ធិមនុស្សបានលើកឡើងថា៖ “ទោះបីជាការការពារប្រឆាំង

57. អង្គជំនុំជម្រះសាលាដំបូងបានបំពានឆន្ទានុសិទ្ធិរបស់ខ្លួន ដោយបានរំលោភដោយផ្ទាល់លើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលត្រូវបានចែងធានានៅក្នុងរដ្ឋធម្មនុញ្ញ នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងបដិសេធមិនអនុញ្ញាតឲ្យគេថតវីដេអូលោក អៀង សារី នៅក្នុងពេលជំនុំជម្រះ។ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងថា លោក អៀង សារី មិនអាចឲ្យគេថតខ្សែវីដេអូ មិនថាដោយអង្គភាពសោតទស្សន៍ ឬ ក្រុមមេធាវីការពារក្តី គឺជាការបដិសេធសិទ្ធិរបស់លោក អៀង សារី ក្នុងការធ្វើកំណត់ហេតុ និងការពារក្តីខ្លួន។ លោក អៀង សារី មិនត្រូវបានកម្រិតសិទ្ធិតិចជាងមុន ដោយគ្រាន់តែលោកត្រូវបានបង្គាប់ឲ្យទៅចូលរួមក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនោះទេ[123]។ ដើម្បីបន្តភារកិច្ចការពារក្តីលោក អៀង សារី[124] ក្រុមមេធាវីការពារក្តី

---

នឹងការចាប់ខ្លួន និងឃុំខ្លួនតាមទំនើងចិត្ត (មាត្រា ១៤) និងសិទ្ធិទទួលបានសវនាការជាសាធារណៈដោយយុត្តិធម៌នៅក្នុងការសម្រេចអំពីបទល្មើសព្រហ្មទណ្ឌ (មាត្រា ១៤) អាចត្រូវបានកំហិតតាមផ្លូវច្បាប់ក៏ដោយប្រសិនបើតម្រូវការនៃស្ថានភាពបន្ទាន់ចាំបាច់ឲ្យមានការកំហិតដូច្នេះមែននោះ *ការបដិសេធសិទ្ធិមូលដ្ឋានមួយចំនួនពាក់ព័ន្ធនឹងសេចក្តីថ្លៃថ្នូររបស់មនុស្សមិនអាចធ្វើទៅបាននោះទេ ទោះក្នុងស្ថានភាពបន្ទាន់ណាមួយក៏ដោយ ហើយការគោរពសិទ្ធិមនុស្សមានសារសំខាន់ដើម្បីធានាទូវសិទ្ធិមិនទទួលរងការបន្ទាបបន្ថោក និងដើម្បីផ្តល់ដំណោះស្រាយដ៏មានប្រសិទ្ធភាពមួយចំពោះការរំលោភបំពានទាំងនេះ*”។ គណកម្មការសិទ្ធិមនុស្ស *Note Verbale ចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ១៩៨៤ ផ្ញើមកពីមន្ត្រីតំណាងអចិន្ត្រៃយ៍នៃប្រទេសហូឡង់ដ៏ជូនទៅអគ្គលេខាធិការនៃការិយាល័យសហរដ្ឋអាមេរិកនៅទីក្រុងហ្សឺណែវ* ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ១៩៨៤ ឯកសា អ.ស.ប លេខ E/CN.4/1985/4 កថាខណ្ឌ ៧០ (គូសបញ្ជាក់បន្ថែម)។

[123] ប្រសិនបើលោក អៀង សារី នៅក្នុងបន្ទប់សវនាការ អង្គជំនុំជម្រះសាលាដំបូង និងក្រុមមេធាវីការពារក្តីអាចតាមដានការចូលរួមរបស់គាត់នៅក្នុងកិច្ចដំណើរការនីតិវិធីបាន និងអាចផ្អាកកិច្ចដំណើរការនីតិវិធី នៅពេលណាដែលគាត់មិនមានលទ្ធភាពចូលរួម។ ឧទាហរណ៍ ប្រសិនបើលោក អៀង សារី ត្រូវបានសង្កេតឃើញថាកំពុងសម្រានលក់នៅក្នុងបន្ទប់សវនាការ អង្គជំនុំជម្រះប្រហែលជាទំនងចង់កំណត់ថាតើគាត់ពិតជាបានចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីដែរ ឬយ៉ាងណា។ ប្រសិនបើគាត់នៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោម យើងពុំអាចកំណត់ដូចខាងលើនេះបានទេ។ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងបានទទួលយក និងឯកភាពជាមួយនឹងវិធីសាស្ត្ររបស់លោកសាស្ត្រាចារ្យ Campbell ហើយសម្រេចថា ប្រសិនបើលោក អៀង សារី ងោកងុកប្រាកដណាស់ថាប្រហែលជាគាត់ធុញ ឬ ចង់ធ្វើដូច្នេះ។ *ដូចបានលើកឡើងខាងលើ* លោកសាស្ត្រាចារ្យ Campbell យល់ឃើញថា “នាពេលនេះ ខ្ញុំបានងោកងុយក្នុងការស្តាប់បកថាកន្លងមក ហើយវាមិនមានន័យថាខ្ញុំមិនមានសមត្ថភាពផ្តង់អារម្មណ៍នោះទេ។ ហើយតាមការពិនិត្យលោក អៀង សារី ខ្ញុំរកមិនឃើញភស្តុតាងថា គាត់មិនអាចផ្តង់អារម្មណ៍បាននោះទេ។ ការលើកឡើងដូច្នេះពុំមានន័យថា [sic] គាត់មិនងោកងុយម្តងម្កាលនោះទេ ដូចខ្ញុំបាននិយាយខាងដើមហើយថា ពួកយើងជាច្រើននាក់សុទ្ធតែធ្លាប់ងោកងុយ ប្រសិនបើនៅពេលណាមួយ វាគ្មានអ្វីច្រើនដែលគួរឲ្យយើងចាប់អារម្មណ៍ចង់ស្តាប់នោះ”។ ប្រតិចារឹក ថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ២០១២ ឯកសារលេខ E1/142.1 ទំព័រ ៥៦។ ចៅក្រម Cartwright បានបង្ហាញថាលោកស្រីពុំសូវខ្វល់ចំពោះ

មានកាតព្វកិច្ចយកចិត្តទុកដាក់ដើម្បីធ្វើយ៉ាងណាកុំឲ្យកិច្ចដំណើរការនីតិវិធីជំនុំជម្រះបន្តទៅមុខបាន ក្នុងខណៈពេលដែលលោក អៀង សារី ពុំមានលទ្ធភាពចូលរួមបានពេញលេញផងនោះ[125]។

58. ប្រសិនបើពុំអាចធ្វើកំណត់ហេតុលើលោក អៀង សារី ក្រុមមេធាវីការពារក្តីលោក អៀង សារី មិនអាចកត់ត្រាពេញលេញ និងត្រឹមត្រូវថាតើលោក អៀង សារី បានរាយការណ៍អ្វីខ្លះជូនដល់គ្រូពេទ្យព្យាបាលលោក និងថាតើគ្រូពេទ្យព្យាបាលលោកបានរាយការណ៍អ្វីខ្លះជូនក្រុមមេធាវីការពារក្តីដោយផ្ទាល់មាត់។ សហមេធាវីនឹងពុំមានមធ្យោបាយណាអាចតាមដានភ្លាមៗលើស្ថានភាពរបស់លោក អៀង សារី ឬ ធានាថា លោក អៀង សារី កំពុងតាមដានកិច្ចដំណើរការនីតិវិធីខណៈពេលដែលក្រុមមេធាវីការពារក្តីស្ថិតនៅក្នុងបន្ទប់សវនាការ។ ដោយសារមានតែ

---

លោក អៀង សារី ដែលពុំអាចទប់ខ្លួនកុំឲ្យគេ ឬ ពុំខ្វល់នូវហេតុដែលបណ្តាលឲ្យកើតបញ្ហាដូច្នេះនោះទេ ដោយលោកស្រីចៅក្រមបានលើកឡើងថា៖ "យើងមានដំណោះស្រាយសាមញ្ញមួយ។ មន្ត្រីគ្រប់គ្រងសំណុំរឿងរបស់លោកអាចដាច់គាត់ឲ្យភ្ញាក់ឡើងវិញបាន...[ដក់] អាចគ្រាន់តែបង្ហាញថា លោក អៀង សារី ពុំចាប់អារម្មណ៍ដោយផ្ទាល់នៅក្នុងការផ្តល់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីនេះតែប៉ុណ្ណោះ" ប្រតិចារឹក ថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០១២ ឯកសារលេខ E1/148.1 ទំព័រ ៣៧-៣៨។

[124] *សូមមើល* គោលការណ៍មូលដ្ឋាននៃអង្គការសហប្រជាជាតិស្តីពីតួនាទីរបស់មេធាវី អនុម័តនៅក្នុងពេលសន្និបាតនៃអង្គការសហប្រជាជាតិលើកទី៨ ស្តីពីការទប់ស្កាត់ឧក្រិដ្ឋកម្ម និងការប្រព្រឹត្តរបស់ជនល្មើស ថ្ងៃទី ២៧ ខែ សីហា - ថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ១៩៩០ គោលការណ៍ទី ១៣ (ក) លើកឡើងថា ក្រុមមេធាវីការពារក្តីមានភារកិច្ចតំណាងផលប្រយោជន៍តាមផ្លូវច្បាប់របស់កូនក្តីខ្លួន ដោយផ្តល់ការជួយជ្រោមជ្រែងកូនក្តីនៅក្នុង "វិធីសមស្រប" និងដោយចាត់វិធានការការងារផលប្រយោជន៍របស់[កូនក្តី]"។ *សូមមើលផងដែរ* វិធាន ២២(៤) នៃវិធានផ្ទៃក្នុង ដែលចែងនៅក្នុងខប្បញ្ញត្តិពាក់ព័ន្ធថា "[មេធាវី] មានកាតព្វកិច្ចលើកកម្ពស់យុត្តិធម៌ និងដំណើរការនៃកិច្ចដំណើរការនីតិវិធីដោយយុត្តិធម៌ និងដោយប្រសិទ្ធភាព"។ ក្រមសីលធម៌សម្រាប់មេធាវីកម្ពុជាដែលបានចុះបញ្ជីជាមួយនឹងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ ២០០៤) មាត្រា ៦៖ "នៅគ្រប់កាលៈទេសៈទាំងអស់ មេធាវីត្រូវគោរពកាតព្វកិច្ចទៅតាមសម្បថ និងគោលការណ៍មនសិការ មនុស្សធម៌ និងភាពប៉ិនប្រសប់"។ មេធាវីកម្ពុជាដែលទើបត្រូវបានទទួលស្គាល់ថ្មីៗត្រូវធ្វើសម្បថថានឹង "អនុវត្តវិជ្ជាជីវៈ[របស់ខ្លួន]ដោយសេចក្តីថ្លៃថ្នូរ ដោយសតិសម្បជញ្ញៈ ដោយស្មោះត្រង់ ដោយមនុស្សធម៌ ដោយស្មារតីឯករាជ្យ និងដោយគោរពរដ្ឋធម្មនុញ្ញ និងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា"។ *សូមមើលផងដែរ* ច្បាប់កម្ពុជាស្តីពីលក្ខន្តិកៈនៃគណៈមេធាវី (ឆ្នាំ ១៩៩៥) មាត្រា ៣៤។

[125] ក្រុមមេធាវីការពារក្តីត្រូវបំពេញការងារដោយយកចិត្តទុកដាក់ដើម្បីធានាផលប្រយោជន៍កូនក្តីរបស់ខ្លួន។ សាលាក្តី ICTY បានលើកឡើងថា គោលបំណងនៃការផ្តល់សិទ្ធិដល់ជនជាប់ចោទអនុលោមតាមលក្ខន្តិកៈនៃសាលាក្តី ICTY "គឺដើម្បីឲ្យជនជាប់ចោទអនុវត្តការយកចិត្តទុកដាក់ឲ្យបានត្រឹមត្រូវនៅក្នុងការប្រើប្រាស់សិទ្ធិទាំងនេះ" ចៅក្រម Richard May និងចៅក្រម Marieke Weird, International Criminal Evidence 306 (Transnational Publishers Inc., 2002)។

វេជ្ជបណ្ឌិត អ.វ.ត.ក ជាអ្នកពិនិត្យលោក អៀង សារី មួយភ្លែតៗ ពីរ ឬ បីដងក្នុងមួយថ្ងៃ ដូច្នេះ យើង*ពុំមានកំណត់ហេតុ*បង្ហាញថាតើលោក អៀង សារី មិនបានគេងលក់ កំពុងងោកងុយ កំពុងមានអារម្មណ៍វិលមុខ ឬ ពុំអាចមើលអេក្រង់ទូរទស្សន៍ ឬ តាមដានកិច្ចដំណើរការនីតិវិធីបាន ឬក៏យ៉ាងណានោះទេ។ (ដោយសារខ្លួនជាអ្នកចង់ដឹងចង់ឮ) អង្គជំនុំជម្រះសាលាដំបូងនឹងពុំបានដឹងថាតើលោក អៀង សារី មាន ឬ ពុំមានលទ្ធភាពតាមដានកិច្ចដំណើរការនីតិវិធី។ អង្គជំនុំជម្រះតុលាការកំពូលនឹងពុំមានកំណត់ហេតុសម្រាប់ជាមូលដ្ឋានសម្រេចថាតើអង្គជំនុំជម្រះសាលាដំបូងបានរំលោភសិទ្ធិទទួលការជំនុំជម្រះរបស់លោក អៀង សារី ដែរឬយ៉ាងណា។

59. អង្គជំនុំជម្រះសាលាដំបូងមិនបានផ្អែកលើឯកសារមូលដ្ឋានផ្លូវច្បាប់*ណាមួយ* សម្រាប់ធ្វើសេចក្តីសម្រេចក្នុងការហាមឃាត់ការថតវីដេអូ ហើយពុំបានផ្តល់សំអាងហេតុលើសេចក្តីសម្រេចរបស់ខ្លួនទៀតផង ក្រៅតែពីអះអាងថា៖ "អង្គជំនុំជម្រះសង្ឃឹមទៅលើគ្រូពេទ្យព្យាបាលដែលអាចនឹងជម្រាបមកអង្គជំនុំជម្រះនូវការកែប្រែណាមួយជាបន្ទាន់នៃស្ថានភាពសុខភាពរបស់លោក អៀង សារី។ ហើយអង្គជំនុំជម្រះក៏សូមបញ្ជាក់ផងដែរថា ការតាមដានផ្នែកសុខភាពនេះគឺថាដោយសារមិនមានមេធាវី ឬក៏ចៅក្រម មិនបានតាមដានដោយផ្ទាល់ ឬក៏ដោយសាធារណជននោះទេ ត្រូវតែតាមដានដោយគ្រូពេទ្យ។ *ដោយហេតុផលនេះឯង* អង្គជំនុំជម្រះបដិសេធថាមិនឲ្យថតជាវីដេអូបញ្ចាំងចូលមកក្នុងបន្ទប់សវនាការ"[126]។ ក្រុមមេធាវីការពារក្តីយល់ស្របថា លោក អៀង សារី តម្រូវឲ្យពេទ្យតាមដាន ប៉ុន្តែនេះពុំមែនជាសំអាងហេតុសម្រាប់ហាមឃាត់ការថតវីដេអូនោះឡើយ។

60. វិធាន ២១(២) នៃវិធានផ្ទៃក្នុងចែងថា "[វិធានការ]ចាប់បង្ខំទាំងឡាយណាចំពោះ[ជនជាប់ចោទ] ត្រូវធ្វើឡើងដោយ ឬ ស្ថិតនៅក្រោមការត្រួតពិនិត្យដោយយកចិត្តទុកដាក់ពីអាជ្ញាធរមានសមត្ថកិច្ចរបស់អង្គជំនុំជម្រះវិសាមញ្ញ។ *វិធានការនេះត្រូវតែកម្រិតតឹងរឹងបំផុតសម្រាប់តែតម្រូវការនៃដំណើរការនីតិវិធី...*"[127]។ គណៈកម្មាធិការសិទ្ធិមនុស្សក៏បានលើកឡើងដូចគ្នាថា "[មេធាវី]ត្រូវមានលទ្ធភាពផ្តល់យោបល់ និងតំណាងជនជាប់ចោទស្របតាមក្រមវិជ្ជាជីវៈដែលត្រូវបានទទួលស្គាល់ជាទូទៅ*ដោយគ្មានលក្ខខណ្ឌកម្រិត* គ្មានឥទ្ធិពលអូសទាញ ដោយគ្មានសម្ពាធ ឬ *ដោយគ្មាន*

[126] ប្រតិចារឹក ថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០១២ ឯកសារលេខ E1/147.1 ទំព័រ ១៩ (គូសបញ្ជាក់បន្ថែម)។

[127] គូសបញ្ជាក់បន្ថែម។

*ការសន្និដ្ឋានមិនត្រឹមត្រូវពីបុគ្គលណាមួយឡើយ*[128]។ វិធានការទាំងឡាយណាដែលរិតត្បិតសិទ្ធិមូលដ្ឋានរបស់លោក អៀង សារី ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌នោះគឺជាវិធានការចាប់បង្ខំ[129]។

61. ការថតវីដេអូលោក អៀង សារី នឹងពុំបង្កផលប៉ះពាល់អ្វីឡើយ ពោលគឺ វាពុំបានបង្អាក់កិច្ចដំណើរការនីតិវិធី ឬ បណ្តាលឲ្យប៉ះពាល់ដល់ភាគីណាមួយនោះទេ។ វានឹងពុំមានអានុភាពអវិជ្ជមានអ្វីទាល់តែសោះ។ វាគ្រាន់តែជួយឲ្យយើងអាចធ្វើកំណត់ហេតុ។ អង្គជំនុំជម្រះសាលាដំបូងពុំបានបង្ហាញគោលបំណងចាំបាច់គ្រប់គ្រាន់តម្រូវឲ្យកាត់បន្ថយសិទ្ធិរបស់លោក អៀង សារី នៅក្នុងការត្រៀមរៀបចំការការពារក្តីឡើយ[130]។ ហេតុដូច្នេះ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងគឺជាការរំលោភលើគោលការណ៍សមាមាត្រ[131]។

62. អង្គបុរេជំនុំជម្រះបានសម្រេចលើបញ្ហានៃការថតខ្សែអាត់សំឡេងលោក អៀង សារី។ ក្រុមមេធាវីការពារក្តីបានស្នើសុំថតខ្សែអាត់សំឡេងនៅក្នុងពេលខ្លួនជួបជាមួយនឹងលោក អៀង សារី នៅក្នុងមន្ទីរឃុំឃាំង[132]។ ក.ស.ច.ស បានហាមឃាត់ការអនុវត្តបែបនេះ ដោយបានរកឃើញថាវាគ្មាន

---

[128] គណៈកម្មាធិការសិទ្ធិមនុស្ស មតិយោបល់ទូទៅលេខ ៣២៖ មាត្រា ១៤៖ សិទ្ធិសមភាពចំពោះមុខតុលាការ និងសាលាក្តី និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៧ ឯកសារ អ.ស.ប CCPR/C/GC/32 កថាខណ្ឌ ៣៤ ពិភាក្សាអំពីសិទ្ធិធ្វើទំនាក់ទំនងជាមួយនឹងមេធាវី។

[129] *សូមមើល* សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចបដិសេធសំណើសុំអនុញ្ញាតថតសំឡេង/រូបភាពវីដេអូនៃការជួបជាមួយលោក អៀង សារី នៅក្នុងមន្ទីរឃុំឃាំង ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១០ A371/2/12 កថាខណ្ឌ ៣៧៖ "វិធានការទាំងឡាយដែលត្រូវបានអនុវត្តជាការហាមឃាត់ទៅលើសិទ្ធិរបស់ជនត្រូវចោទដូចមានចែងក្នុងវិធាន ២១(១) នៃវិធានផ្ទៃក្នុង "ត្រូវកម្រិតតឹងរ៉ឹងបំផុតសម្រាប់តែដំណើរការនីតិវិធីប៉ុណ្ណោះ"។ *សូមមើលផងដែរ* សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធទៅនឹងការប្រាស្រ័យទាក់ទងគ្នារវាងជនត្រូវចោទ និងប្រឹក្សារបស់គាត់ ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៨ A104/II/7 កថាខណ្ឌ ១៤-១៥។

[130] *សូមមើល* សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍លើរឿងក្តី *Stanišić* កថាខណ្ឌ ១៨ ដែលលើកឡើងអំពីគោលការណ៍សមាមាត្រ។

[131] *សូមមើល*លេខយោង ៨៨ ខាងលើ។

[132] សំណើសុំដីកាបង្គាប់ឲ្យមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក អនុញ្ញាតឲ្យមេធាវីការពារក្តីថតយកសម្លេង/រូបភាពវីដេអូកូនក្តីរបស់ពួកយើងនៅមន្ទីរឃុំឃាំង ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១០ A371។

មូលដ្ឋានផ្លូវច្បាប់ណាមួយបើកឱ្យមានសិទ្ធិធ្វើការថតខ្សែអាត់សំឡេងនៃកិច្ចសម្ភាសន៍នោះទេ[133]។ ក្រុមមេធាវីការពារក្តីបានធ្វើបណ្តឹងឧទ្ធរណ៍នាពេលនោះ[134]។ អង្គបុរេជំនុំជម្រះបានទទួលយកបណ្តឹងឧទ្ធរណ៍នេះ ហើយបានរកឃើញថា ដោយសារនៅក្នុងកិច្ចព្រមព្រៀង ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ឬ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ពុំមានខប្បញ្ញត្តិ ឬ ចំណុចយោងជាមូលដ្ឋានច្បាស់លាស់អនុញ្ញាតឱ្យមានសិទ្ធិថតខ្សែអាត់សម្លេងដូច្នេះ វាពុំមានន័យថា សិទ្ធិនេះស្ថិតនៅក្រៅវិសាលភាពនៃកិច្ចនានាដែលពុំត្រូវបានអនុញ្ញាតដោយប្រយោលនោះឡើយ[135]។ អង្គបុរេជំនុំជម្រះបានរកឃើញថា ការបកស្រាយតាមន័យចង្អៀតអំពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់លោក អៀង សារី គឺជាការធ្វើឡើងផ្ទុយនឹងកម្មវត្ថុ និងគោលបំណងនៃសិទ្ធិធានាការជំនុំជម្រះដោយយុត្តិធម៌[136]។ អង្គបុរេជំនុំជម្រះបានបង្គាប់ឱ្យប្រធានមន្ទីរឃុំឃាំងអនុញ្ញាតឱ្យក្រុមមេធាវីការពារក្តីថតខ្សែអាត់សំឡេងលោក អៀង សារី ពីព្រោះ ថាការធ្វើដូច្នេះនឹងធានាថា លោក អៀង សារី មានសម្ភារៈគ្រប់គ្រាន់សម្រាប់យកមកប្រើប្រាស់ក្នុងការការពារក្តីរបស់លោក[137]។ សេចក្តីសម្រេចនេះអាចយកមកធ្វើជាបទដ្ឋានណែនាំបាន ដោយសារវាបានសម្រេចលើបញ្ហាដូចគ្នាដែលត្រូវបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍នាពេលនោះ ពោលគឺ សិទ្ធិរបស់លោក អៀង សារី នៅក្នុងការត្រៀមរៀបចំការការពារក្តីតាមរយៈការថតវីដេអូ។

63. អង្គជំនុំជម្រះសាលាដំបូងខកខានមិនបានអនុវត្តតាមលក្ខខណ្ឌកំហិតនៅក្នុងវិធាន ២១(២) នៃវិធានផ្ទៃក្នុងស្តីពីវិធានការចាប់បង្ខំ ហើយក៏ខកខានមិនបានផ្តល់ទម្ងន់លើសិទ្ធិជាមូលដ្ឋានរបស់

---

[133] លិខិតពាក់ព័ន្ធនឹង៖ សំណើរបស់លោកសុំថតវីដេអូ/ខ្សែអាត់សំឡេងរបស់ អៀង សារី នៅក្នុងមន្ទីរឃុំឃាំង ចុះថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០១០ A371/1។

[134] បណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងការសម្រេចបដិសេធរបស់ ក.ស.ច.ស ទៅនឹងសំណើសុំរបស់មេធាវីការពារក្តីថតសំឡេង/រូបភាពវីដេអូនៃការជួបជាមួយលោក អៀង សារី នៅក្នុងមន្ទីរឃុំឃាំង ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១០ A371/2/12។

[135] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចបដិសេធសំណើសុំអនុញ្ញាតថតសំឡេង/រូបភាពវីដេអូនៃការជួបជាមួយលោក អៀង សារី នៅក្នុងមន្ទីរឃុំឃាំង ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១០ A371/2/12 កថាខណ្ឌ ៣១។

[136] *ដូចខាងលើ* កថាខណ្ឌ ៣១។

[137] *ដូចខាងលើ* កថាខណ្ឌ ៣៥ ទំព័រ ១៩។

លោក អៀង សារី នៅក្នុងការត្រៀមរៀបចំការពារក្ដីរបស់ខ្លួនផងដែរ។ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងបានបំពានឆន្ទានុសិទ្ធិរបស់ខ្លួន ដោយបានហាមឃាត់ក្រុមមេធាវីការពារក្ដីមិនឲ្យថតវីដេអូលោក អៀង សារី។ ការរំលោភបំពានឆន្ទានុសិទ្ធិរបៀបនេះបានធ្វើឲ្យអន្តរាយដល់លោក អៀង សារី ពីព្រោះវាជាការរំលោភសិទ្ធិជាមូលដ្ឋានរបស់លោកក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដើម្បីត្រៀមរៀបចំការការពារក្ដី។

## VI. សំណើសុំ

**ហេតុដូច្នេះ** យោងតាមហេតុផលទាំងអស់ដូចបានរៀបរាប់ខាងលើ ក្រុមមេធាវីការពារក្ដីសូមស្នើសុំដោយគោរពឲ្យអង្គជំនុំជម្រះតុលាការកំពូលចាត់ទុកសេចក្ដីសម្រេចដែលត្រូវបានជំទាស់នេះជា **មោឃៈ** ហើយ**បង្គាប់**ឲ្យអង្គជនុំជម្រះសាលាដំបូងអនុញ្ញាតឲ្យលោក អៀង សារី មានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការ។ ប្រសិនបើអង្គជំនុំជម្រះតុលាការកំពូលមិនព្រមអនុញ្ញាតឲ្យលោក អៀង សារី មានវត្តមាននៅក្នុងបន្ទប់សវនាការទេនោះ អង្គជំនុំជម្រះតុលាការកំពូលគួរៈ

ក. **បង្គាប់**ឲ្យអង្គជំនុំជម្រះសាលាដំបូងបញ្ចាំងរូបភាពលោក អៀង សារី នៅតាមកញ្ចក់ទូរទស្សន៍ក្នុងបន្ទប់សវនាការ ក្នុងករណីដែលលោកត្រូវបានបង្គាប់ឲ្យនៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ **ឬ**

ខ. **បង្គាប់**ឲ្យអង្គជំនុំជម្រះសាលាដំបូងអនុញ្ញាតឲ្យក្រុមមេធាវីការពារក្ដីថតវីដេអូលោក អៀង សារី នៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ក្នុងករណីលោក អៀង សារី ត្រូវបានបង្គាប់ឲ្យនៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោម និង**បង្គាប់**បន្ថែមទៀតឲ្យអង្គជំនុំជម្រះសាលាដំបូងទទួលយកឯកសារខ្សែរូបភាពវីដេអូ ដាក់បញ្ចូលទៅក្នុងសំណុំរឿងដើម្បីរក្សាជាកំណត់ហេតុមិនលម្អៀង និងសម្រាប់ទុកក្រែងលោមានកំហុសណាមួយសម្រាប់ធ្វើបណ្ដឹងសើរើនាពេលអនាគត។

សូមអង្គជំនុំជម្រះតុលាការកំពូលទទួលយកបណ្តឹងសាទុក្ខនេះ ដោយក្តីគោរពពីក្រុមមេធាវីការពារក្តី។

ធ្វើនៅរាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី **១៨ ខែ ធ្នូ ឆ្នាំ ២០១២**។

| | |
|---|---|
| **អាង ឧត្តម** | Michale G. KARNAVAS |

**សហមេធាវីការពារក្តីលោក អៀង សារី**